សម្រាប់លក់

ក្រសួងអប់រំ យុវជន និងកីឡា

# វិទ្យាសាស្ត្រ

## ជីវវិទ្យា





៨





គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

# បញ្ជីខ្ចីសៀវភៅ

សាលារៀន : ..............................................................................

កំរងសាលារៀន : ..............................................................................

ស្រុក / ខណ្ឌ : ..............................................................................

ខេត្ត / ក្រុង : ..............................................................................

ថ្ងៃ ខែ ឆ្នាំ ដែលសាលារៀនទទួលបានសៀវភៅ : ..............................

| ឈ្មោះសិស្ស ខ្ចីសៀវភៅ | ថ្ងៃ ខែ ឆ្នាំ ខ្ចីសៀវភៅ | សភាពលក្ខណៈ សៀវភៅ | ថ្ងៃ ខែ ឆ្នាំ សងសៀវភៅ | សភាពលក្ខណៈ សៀវភៅ |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

## ចំពោះគ្រូបង្រៀន

សូមសរសេរឈ្មោះសិស្សឱ្យបានច្បាស់នៅក្នុងខ្ទង់ "ឈ្មោះសិស្សខ្ចីសៀវភៅ" ។ សូមប្រើអក្សរខាងក្រោមនេះ ដើម្បីបញ្ជាក់សភាពលក្ខណៈរបស់សៀវភៅ :

ក. (សៀវភៅថ្មី)

ខ. (សៀវភៅប្រើហើយ ដែលនៅមានសភាពល្អ)

គ. (សៀវភៅប្រើហើយ ដែលនៅមានសភាពមធ្យម)

ឃ. (សៀវភៅប្រើហើយ ដែលនៅមានសភាពអន់ឬចាស់)

សូមលើកទឹកចិត្តសិស្សនិងជួយសិស្សក្នុងការថែរក្សាសៀវភៅដែលបានខ្ចី ។

ក្រសួងអប់រំ យុវជន និងកីឡា

# វិទ្យាសាស្ត្រ

## ថ្នាក់ទី ៨

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៥៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

| | | |
|---|---|---|
| **គណៈកម្មការនិពន្ធ** | លោក សូ គន្ធី | លោក ហែម សាលី |
| | លោក សួន សុជាតិ | លោកស្រី យឹម យីហ៊ុប |
| | លោកស្រី ហ៊ុយ ចន្ធូ | លោក នី ពុទ្ធី |
| **អ្នកវាយអត្ថបទ** | លោក ហៃ វីរៈ | លោក ប៉ាន់ ជាតិ |
| **វិចិត្រករ** | លោក តន់ ជាតិ | |
| **អ្នករៀបរៀង** | លោក ស៊ឹម ចាន់ធី | លោក ចាន់ ខេង |
| | លោក វ៉ា វុទ្ធី | លោក ជួន វណ្ណា |
| **អ្នករចនាទំព័រ** | លោក គង់ ចិត្រា | |
| **អ្នកឯកទេស** | លោក អ៊ឹង ហេង | |
| **គណៈកម្មការពិនិត្យ** | លោកស្រី អៀម ចាន់ឌី | លោកស្រី អន កិត្យាស៊ុ |
| | លោកស្រី ភោគ សុទ្ធារី | លោកស្រី ណារ៉េត ប៉ូលីវីន |

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី **ក្រសួងអប់រំ យុវជន និងកីឡា** តាមប្រកាសលេខ ២២២៧ អយក.ប្រក. ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០១០ ដើម្បីប្រើប្រាស់នៅតាមសាលារៀន ។

ហាមថតចម្លងសៀវភៅនេះ

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពលើកទី៨ ឆ្នាំ២០១៧ ចំនួន ៨៥ ០០០ច្បាប់

ISBN 9-789-995-001-230

# អារម្ភកថា

សៀវភៅវិទ្យាសាស្ត្រថ្នាក់ទី ៨ នេះ គណៈកម្មការនិពន្ធបានរៀបចំចងក្រងឡើងដោយផ្អែកលើកម្មវិធីសិក្សាថ្មី (2009) របស់ក្រសួងអប់រំ យុវជន និងកីឡា ។ នៅក្នុងកម្មវិធីសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រមានមុខវិជ្ជារងចំនួនបួន រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា ។

រាល់ខ្លឹមសារមេរៀនដែលមានក្នុងសៀវភៅនេះ អ្នកនិពន្ធបានរៀបចំពីកម្រិតងាយទៅកម្រិតលំបាក ហើយស្របតាមកម្មវិធីសិក្សាថ្មីនិងស្របតាមវិធីវិទ្យាសាស្ត្រ ។

គណៈកម្មការនិពន្ធសង្ឃឹមថា សៀវភៅវិទ្យាសាស្ត្រថ្នាក់ទី ៨ នេះនឹងក្លាយជាមិត្តដ៏ល្អរបស់ប្អូនៗសិស្សានុសិស្សជាក់ជាមិនខាន ។ ទន្ទឹមគ្នានោះដែរគណៈកម្មការនិពន្ធរីករាយនឹងទទួលយកមតិកែលំអពីសំណាក់ លោកគ្រូ អ្នកគ្រូនិងគ្រប់មជ្ឈដ្ឋាន ។

**គណៈកម្មការនិពន្ធ**

ជំពូក 1 : រុក្ខជាតិនិងសត្វល្អិត (ជីវវិទ្យា)
1. សត្វល្អិតនិងជំងឺរុក្ខជាតិ......................154
2. វិធីថែរក្សាដំណាំ......................160
ជំពូក 2 : បរិស្ថានធម្មជាតិ
1. ស្ថានប្រព័ន្ធតាមមូលដ្ឋាន......................170
2. ទំនាក់ទំនងអាហារក្នុងបរិស្ថាន......................176
ជំពូក 3 : ដំណឹកនាំក្នុងរុក្ខជាតិ
1. បន្សាយ......................182
2. ដំណឹកនាំក្នុងរុក្ខជាតិមានសរសៃនាំ......................188
ជំពូក 4 : ដង្ហើមនិងដំណឹកនាំ
1. ប្រដាប់ដង្ហើម......................196
2. ដង្ហើម......................200
3. ដង្ហើមកោសិកា......................206
4. ប្រព័ន្ធដំណឹកនាំ......................210
ជំពូក 5 : ការថែរក្សាសុខភាព
1. អាហារ......................220
2. របបអាហារនិងថាមពល......................226
3. អាហារមានសុវត្ថិភាព......................232
ជំពូក 6 : គ្រឿងញៀន
1. គ្រឿងញៀន......................238
2. ឥទ្ធិពលនៃគ្រឿងញៀន......................242

# ជំពូកទី 1 រុក្ខជាតិនិងសត្វល្អិត




*វដ្តជីវិតដង្កូវឆ្អកបំផ្លាញដំណាំស្រូវ*

ការការពាររុក្ខជាតិមានសារៈសំខាន់ណាស់។ នៅក្នុងធម្មជាតិក្រៅពីការកាប់បំផ្លាញដោយមនុស្ស រុក្ខជាតិក៏ត្រូវបានបំផ្លាញដោយសត្វល្អិតចង្រៃផងដែរ។ សត្វល្អិតមួយចំនួនបំផ្លាញរុក្ខជាតិដោយផ្ទាល់ និងខ្លះទៀតបង្កជំងឺដល់រុក្ខជាតិ(មិនផ្ទាល់)។

មេរៀនទី

# 1 សត្វល្អិតនិងជំងឺរុក្ខជាតិ

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីប្រភេទនីមួយៗនៃសត្វល្អិតដែលមានប្រយោជន៍
- ❑ ពណ៌នាពីសត្វល្អិតមានប្រយោជន៍កំចាត់សត្វល្អិតចង្រៃដែលបំផ្លាញដំណាំ
- ❑ រាប់ឈ្មោះសត្វល្អិតចង្រៃបំផ្លាញដំណាំ
- ❑ ពណ៌នាពីសកម្មភាពរបស់សត្វល្អិតចង្រៃនិងការបង្កជំងឺរបស់វាទៅលើផ្នែកផ្សេងៗរបស់ដំណាំ
- ❑ បង្ហាញពីបច្ចេកទេសក្នុងការកំចាត់សត្វល្អិតចង្រៃបំផ្លាញដំណាំឱ្យទទួលបានជោគជ័យ ដោយកុំឱ្យមានផលប៉ះពាល់ទៅលើបរិស្ថាន ។

ជាទូទៅដំណាំតែងតែទទួលនូវការបំផ្លាញពីសត្វល្អិតចង្រៃនិងជំងឺផ្សេងៗ ។ ប៉ុន្តែការបំផ្លាញមានកម្រិតខុសគ្នា ។ បញ្ហាទាំងនេះជាកត្តាយ៉ាងសំខាន់ដែលជំរុញឱ្យទិន្នផលដំណាំថយចុះ ។ ដូចនេះ តើសត្វល្អិតទាំងអស់ជាសត្វចង្រៃមែនឬទេ ?

## 1. សត្វល្អិតមានប្រយោជន៍

សត្វល្អិតមានប្រយោជន៍មានច្រើនសន្ធឹកសន្ធាប់ ។ ប្រសិនបើគ្មានសត្វល្អិតមានប្រយោជន៍ សត្វល្អិតចង្រៃនឹងកើតច្រើនសន្ធឹកសន្ធាប់ ហើយបំផ្លាញផលដំណាំបានទាំងស្រុង ។ ប្រភេទសត្វល្អិតមានប្រយោជន៍ដែលយើងតែងជួបប្រទះជាញឹកញាប់មាន សត្វរំពា បរាសិត និងសត្វបង្កជំងឺលើសត្វល្អិតបំផ្លាញដំណាំ ។

### 1.1. សត្វរំពា

សត្វរំពា ជាសត្វដែលស៊ីសត្វដទៃទៀតជាអាហារ ។ សត្វរំពាភាគច្រើនមានសកម្មភាពនៅពេលយប់ ។ សត្វរំពាខ្លះជាសត្វល្អិតដូចជា ពីងពាង អណ្តើកមាស និងខ្មូតដីស៊ីពួកមមាចមេអំបៅ និងដង្កូវស៊ីរូងដើម ព្រមទាំងដង្កូវស៊ីបំផ្លាញស្លឹក ។



ស្រឹងកំពុងជញ្ជក់សារធាតុទឹកពីខ្លួនដង្កូវរុយ

ពីងពាងចូលចិត្តស៊ីសត្វរស់ ប៉ុន្តែមានខ្លះស៊ីពងសត្វល្អិត។ សត្វរំពាមួយចំនួនទៀត ដូចជាពីងពាងទឹក ឬស្រឹងទឹកស៊ីមមាច កូនដង្កូវរូងដើម និងកូនដង្កូវមូរស្លឹកដែលធ្លាក់មកលើផ្ទៃទឹក។

តាមធម្មតា សត្វរំពាស៊ីតែប្រភេទសត្វណាដែលកើតច្រើន ដូចជាសត្វចង្រៃ។ ប្រសិនបើសត្វចង្រៃកើតមានតែបន្តិចបន្តួចនិងមិនទាន់ដល់កម្រិតដែលយើងសន្មតថា វាបំផ្លាញឱ្យខូចខាតដំណាំយើងទេ យើងគប្បីថែទាំវាទុកគ្រាន់ជាចំណីអាហារដល់សត្វមានប្រយោជន៍ឱ្យវាបន្តពូជបានច្រើន។

## 1.2. បរាសិត

បរាសិត មានសារៈសំខាន់ណាស់សម្រាប់កម្រិតនូវបរិមាណសត្វល្អិតស៊ីដំណាំកុំឱ្យឈានដល់ការបាត់បង់ទិន្នផល។ សត្វរំពាត្រូវការរស់នៅកន្លែងណាដែលមានសត្វល្អិតចង្រៃច្រើន។ ចំណែកបរាសិតវិញអាចរស់នៅជាមួយសត្វល្អិតចង្រៃតែមួយក៏បាន។ *ឧទាហរណ៍* ឪម៉ាល់ រុយក្បាលធំ។




*ពិកដៀឪម៉ាល់នៅជុំវិញនិងនៅខាងក្រោមសាកសពដង្កូវមូរស្លឹក*

ខុសពីសត្វរំពា បរាសិតអាចស្វែងរកសត្វល្អិតចង្រៃឃើញ សូម្បីតែសត្វល្អិតចង្រៃមានតែបន្តិចបន្តួចក៏ដោយ។ ជាទូទៅបរាសិតឆាប់ទទួលរងឥទ្ធិពលរបស់ថ្នាំបំពុលកសិកម្មជាងសត្វរំពា។

## 1.3. សត្វបង្កជំងឺលើសត្វចង្រៃ

មានមីក្រូសារពាង្គកាយជាច្រើនដែលអាចសម្លាប់សត្វចង្រៃដែលបំផ្លាញដំណាំដូចជា ពួកផ្សិត និងវីរុស។

### ក. ពួកផ្សិត

ពួកផ្សិត ដើរតួសំខាន់ណាស់ក្នុងការសម្លាប់មមាចគ្រប់ប្រភេទ។ គេសំគាល់ឃើញមានប្រភេទផ្សិតខ្លះកើតលើដង្កូវបំផ្លាញស្លឹក ប្រភេទផ្សិតខ្លះទៀតបង្កជំងឺលើសត្វល្អិតច្រើនប្រភេទទៀត ដូចជាសត្វល្អិត ពពួកស្លាបរឹង (ខ្ទុង ខ្មូត កញ្ចែ អណ្តើកមាស រុយស ចៃ)។ ជាទូទៅវាច្រើនបង្កជំងឺលើសត្វល្អិតរស់នៅក្នុងដី។ *ឧទាហរណ៍* ដង្កូវទឹក កញ្ចែរស់នៅក្នុងដី។



*ផ្សិតដែលបង្កជំងឺលើសត្វមមាចជញ្ជក់ដើមពោត*



*ផ្សិតបង្កជំងឺទៅលើរុយសពេញវ័យ។ សាកសពរុយសភ្ជាប់ទៅនឹងផ្ទៃស្លឹក។*

### ៣. វីរុស




វីរុសភាគច្រើនត្រូវបានរកឃើញនៅលើដង្កូវមេអំបៅ។ វីរុសទាំងនោះជាភ្នាក់ងារធម្មជាតិដ៏មានប្រសិទ្ធភាព ជាពិសេសនៅពេលបរិមាណដង្កូវមានកម្រិតខ្ពស់។ ដង្កូវនឹងកើតជំងឺនៅពេលវាស៊ីស្លឹកដំណាំដែលមានវីរុស។ នៅពេលដែលដង្កូវងាប់ដោយជំងឺ គេឃើញមានធាតុរាវហូរចេញពីខ្មោចដង្កូវ ក៏អាចជាកត្តាបន្តជំងឺវីរុសដល់ដង្កូវដទៃទៀត។

## 2. សត្វល្អិតចង្រៃ




ដំណាំច្រើនទទួលរងការបំផ្លាញយ៉ាងធ្ងន់ធ្ងរពីសត្វល្អិតចង្រៃមួយចំនួនដូចជា ពពួករុយ ពពួកដង្កូវ ពពួកចៃ ពពួកមមាច ពពួករុយស ពពួកខ្ទួត អណ្ដើកមាសស៊ីស្លឹក ខ្ទុងបន្លាស៊ីស្លឹក សត្វល្អិតស្លាបរឹង សត្វទាកគួ ឬចៀកគូបំផ្លាញស្លឹក។

ក្រៅពីបំផ្លាញដំណាំដោយផ្ទាល់ សត្វល្អិតចង្រៃមួយចំនួនក៏ជាភ្នាក់ងារចម្លងជំងឺដល់រុក្ខជាតិយ៉ាងខ្លាំងក្លាដែរដូចជា ពពួករុយស ពពួកចៃជាដើម។

# 3. ជំងឺរុក្ខជាតិ

ផ្នែកផ្សេងៗនៃដំណាំដែលត្រូវបានបំផ្លាញដោយសត្វល្អិតនិងជំងឺមានដូចជា

## 3.1. ឫស

បើឫសរុក្ខជាតិទទួលរងការបំផ្លាញពីជំងឺ រុក្ខជាតិនោះនឹងឈប់លូតលាស់ ជ្រុះស្លឹក ហើយជាទូទៅវាស្វិតស្រពោនយ៉ាងលឿន។ ភ្នាក់ងារបង្កជំងឺដល់ឫសមានច្រើនដូចជា ផ្សិត ដង្កូវស្លាបរឹង និងបញ្ញើក្អែក។

## 3.2. គល់ដំណាំ

នៅពេលដំណាំរងការបំផ្លាញពីជំងឺ គល់ដំណាំមានពណ៌ក្រមៅប្រផេះ ឫសដាច់ត្រឹមគល់ ហើយមានផ្សិតនៅគល់។ ប៉ុន្តែស្លឹកនៅស្រស់ នេះគឺជារោគសញ្ញារបស់ជំងឺក្ដួចក ឬស្វិតដើម។ ជាទូទៅរោគសញ្ញាដែលបង្ហាញពីការបំផ្លាញពីសត្វល្អិតមានដូចជា កូនដើមត្រូវកាត់ផ្ដាច់ត្រឹមដី កូនដើមត្រូវកកេរជុំវិញ កូនដើមត្រូវចោះរូងចូលក្នុង និងធ្វើឱ្យប៉ោងកំពឹកកំពក។

## 3.3. ដើមមែក

នៅពេលដើមមែករងការបំផ្លាញពីសត្វល្អិត ឬជំងឺដែលបង្កដោយផ្សិត វីរុស វាធ្វើឱ្យប្រព័ន្ធដឹកនាំរុក្ខរសត្រូវរាំងស្ទះ ហើយរោគសញ្ញាឃើញមាននៅលើស្លឹក ផ្កា និងផ្លែ។



*ដង្កូវចោះរូងដើមសណ្ដែកបាយ*



*ដង្កូវមេអំបៅយោលទោងស៊ីរូងដើមស្រូវ*

## 3.4. ស្លឹក



*រុយពងដាក់នៅក្នុងជាលិកាស្លឹក*



*ដង្កូវរុយស៊ីរូងស្លឹកលូតលាស់ពេញវ័យ*



*ដង្កូវរុយស៊ីរូងស្លឹកដែលបង្កើតជាស្នាមរនោតរនូត*

ស្លឹករុក្ខជាតិច្រើនទទួលរងការបំផ្លាញពីសត្វល្អិតនិងជំងឺផ្សេងៗដូចជា ជំងឺរលាក ជំងឺអុជ ឬជំងឺច្រេះដែក និងជំងឺក្រាភ្លើង ។

- ជំងឺរលាកបង្កឱ្យមានការបែកញើសក្រោមស្លឹក ហើយកន្លែងដែលបែកញើសប្រែជាស្នោក ចាក់រលួយ ។
- ជំងឺអុជ ជាជំងឺដែលធ្វើឱ្យមានអុជៗ ពណ៌ច្រេះលើផ្ទៃស្លឹកខាងក្រោម រួចឆ្លងមកដល់ផ្ទៃស្លឹកផ្នែកខាងលើ ។
- ជំងឺក្រាភ្លើង រុក្ខជាតិមានស្លឹកក្រហម(រួញដូចនំក្រៀប)និងឆ្លងរាលដាលយ៉ាងលឿននៅពេលអាកាសធាតុស្ងួត ។

# 4. វិធីកំចាត់សត្វល្អិតលើដំណាំ

ការកំចាត់សត្វល្អិតចង្រៃមានវិធីច្រើនយ៉ាងណាស់ ។ ប៉ុន្តែជាដំបូងត្រូវសិក្សាឱ្យស៊ីជម្រៅពីជីវិតរបស់វា ដើម្បីកំណត់ពីពេលវេលាដែលសត្វល្អិតនោះងាយងាប់និងអនុវត្តវិធីមានប្រសិទ្ធភាព ។

## 4.1. វិធីមេកានិច

- ស្ទាក់ចាប់សត្វល្អិតក្នុងដំណើរចររបស់វា ។ *ឧទាហរណ៍* ហ្វូងកណ្ដូប
- ប្រើល្បាយអាហារដែលមានជាតិពុល ចំពោះសត្វល្អិតដែលទិចផ្លែ ។
- ដាក់ក្រវាត់នេះនៅលើដងដើមរុក្ខជាតិ ដើម្បីស្ទាក់ស្រមោច ។
- ប្រមូលចាប់សត្វល្អិត ។

## 4.2. វិធីរូប

- បំភ្លឺភ្លើងសម្រាប់ត្រួតពិនិត្យសត្វល្អិតចង្រៃ ឬដុតរុក្ខជាតិដែលមានសត្វល្អិតបំផ្លាញ ។
- ត្រាំគ្រាប់ពូជក្នុងទឹកក្ដៅ(ចំហាយទឹកក្ដៅ) ដើម្បីសម្លាប់មីក្រុបលើគ្រាប់ពូជ ។
- ពន្លិចដំណាំខ្លះ ដើម្បីសម្លាប់សត្វល្អិតចង្រៃ ។
- រក្សាគ្រាប់ពូជទុកនៅក្នុងដបកែវបិទជិត ដើម្បីឱ្យសត្វល្អិតត្រូវថប់ដង្ហើមងាប់ ។

## 4.3. វិធីគីមី

**វិធីគីមី** ជាវិធីមួយដែលផ្ដល់លទ្ធផលបានយ៉ាងឆាប់រហ័ស ។ វិធីនេះទប់ស្កាត់សត្វល្អិតចង្រៃមិនឱ្យបំផ្លាញដំណាំបានទាន់ពេលវេលា ។ ប៉ុន្តែអាចបំផ្លាញដល់សុខភាពមនុស្សនិងបំពុលបរិស្ថានផងដែរ ប្រសិនបើយើងមិនបានយល់ពីរបៀបប្រើប្រាស់ថ្នាំពុលកសិកម្មដោយសុវត្ថិភាព ។

### 4.4. វិធីជីវៈ

ក្នុងវិធីនេះ គេប្រើសត្វល្អិតមានប្រយោជន៍ដូចជា បក្សី អំបូរកង្កែប សត្វរំពា បាក់តេរី វីរុស ទៅបំផ្លាញសត្វល្អិតចង្រៃ ។ ដូចនេះគប្បីការពារសត្វល្អិតមានប្រយោជន៍ ដែលច្រើនតែត្រូវបំផ្លាញដោយកត្តាផ្សេងៗ ។

### 4.5. វិធីដាំដុះ

- ដំណាំឆ្លាស់ ៖ អាចផ្តាច់វដ្តបំផ្លាញរបស់សត្វល្អិតនិងជំងឺផ្សេងៗ ។
- ការភ្ជួររាស់ជ្រៅ ៖ អាចបំផ្លាញ សម្លាប់កូនញាស់របស់សត្វល្អិតចង្រៃ ។
- ការសាប ៖ មុន ឬក្រោយពេលកំណត់តាមប្រភេទដំណាំ គឺគេជ្រើសរើសពេលសាបដោយធ្វើយ៉ាងណាឱ្យដំណាំលូតលាស់មុនពេលសត្វល្អិតចង្រៃកើតច្រើន ។
- ប្រមូលផលមុនពេលកំណត់ ៖ កុំឱ្យសត្វល្អិតចង្រៃកើតមានច្រើននៅចុងបញ្ចប់នៃការលូតលាស់នៃដំណាំ ។

**មេរៀនសង្ខេប**

- ជាទូទៅដំណាំរបស់យើងច្រើនតែរងនូវការបំផ្លាញពីសត្វល្អិតនិងជំងឺផ្សេងៗ ។
- ក្នុងការកំចាត់សត្វល្អិតចង្រៃបំផ្លាញដំណាំ គេអាចជ្រើសរើសប្រភេទសត្វល្អិតមានប្រយោជន៍ដូចជា ពួកសត្វរំពា ពួកបរាសិត និងពួកបង្កជំងឺលើសត្វល្អិតបំផ្លាញដំណាំ ។
- ការបំផ្លាញដោយសត្វល្អិតចង្រៃនិងជំងឺលេចចេញលើផ្នែកផ្សេងៗរបស់ដំណាំដូចជា នៅលើឫស នៅលើគល់ដំណាំ នៅលើដើម មែក ស្លឹក ផ្កា និងផ្លែ ។
- វិធីផ្សេងៗក្នុងការកំចាត់សត្វល្អិតចង្រៃបំផ្លាញដំណាំមាន វិធីមេកានិច វិធីរូប វិធីគីមី វិធីជីវៈ និងវិធីដាំដុះ ។

### សំណួរ

1. តើសត្វល្អិតមានប្រយោជន៍ដែលកំចាត់សត្វល្អិតចង្រៃបំផ្លាញដំណាំមានប៉ុន្មានប្រភេទ ? ចូររាប់ឈ្មោះប្រភេទនីមួយៗ ។
2. ចូររាប់ឈ្មោះសត្វល្អិតចង្រៃដែលបំផ្លាញដំណាំ ។
3. ចូរពណ៌នាពីសកម្មភាពរបស់សត្វល្អិតចង្រៃនិងជំងឺដែលបំផ្លាញទៅលើផ្នែកផ្សេងៗរបស់ដំណាំ ។
4. ចូរពណ៌នាពីវិធីកំចាត់សត្វល្អិតបំផ្លាញដំណាំ ។ តើវិធីណាមួយដែលយកទៅអនុវត្ត ហើយធ្វើឱ្យមានផលប៉ះពាល់ដល់សុខភាពមនុស្សនិងបរិស្ថាន ? ពីព្រោះអ្វី ?

មេរៀនទី

# 2 វិធីថែរក្សាដំណាំ

**ចប់មេរៀននេះ សិស្សអាច**

- រៀបរាប់ពីគោលការណ៍ក្នុងការការពារដំណាំ
- ពណ៌នាពីបច្ចេកទេស ការពារដំណាំប្រឆាំងនឹងសត្វល្អិតចង្រៃនិងជំងឺ
- បង្ហាញពីបច្ចេកទេស រក្សាគ្រាប់ពូជដំណាំ
- កំណត់បានពីរបៀបថែរក្សាបរិស្ថាននៅពេលប្រើប្រាស់ថ្នាំពុលគីមីនៅលើដំណាំ
- រៀបរាប់ពីប្រភេទសរីរាង្គពិសេសនិងសារធាតុពិសេសសម្រាប់ការពារខ្លួនរបស់រុក្ខជាតិ
- បង្ហាញពីលក្ខណៈស្វ័យការពារខ្លួនរបស់រុក្ខជាតិទប់ទល់នឹងសត្រូវ ។

ដំណាំតែងជួបប្រទះនូវការបំផ្លាញពីសត្វល្អិតចង្រៃនិងជំងឺផ្សេងៗ ដែលបង្កដោយមេរោគមួយចំនួនដូចជា ផ្សិត និងបាក់តេរីជាដើម ប៉ុន្តែការខូចខាតមានកម្រិតខុសៗគ្នា ។ ក្រៅពីសត្វល្អិតនិងជំងឺ ដំណាំក៏អាចជួបបញ្ហាផ្សេងៗទៀតដូចជា ដីខ្វះជីជាតិ ឬសារធាតុចិញ្ចឹម ដីជាំទឹកពេក ។

ដើម្បីចៀសវាងបញ្ហាដូចខាងលើនេះ កសិករគួរតែអនុវត្តតាមគោលការណ៍ធម្មជាតិ ។ តើគេត្រូវអនុវត្តគោលការណ៍ធម្មជាតិនេះយ៉ាងដូចម្ដេចក្នុងការថែរក្សាដំណាំ ?

## 1. គោលការណ៍ធម្មជាតិក្នុងការថែរក្សាដំណាំ

កសិករគួរតែអនុវត្តតាមវិធានការខាងក្រោមឱ្យបានត្រឹមត្រូវ ដើម្បីកាត់បន្ថយការខូចខាតនៃដំណាំបណ្ដាលពីសត្វល្អិតចង្រៃនិងជំងឺផ្សេងៗ ។



ក

- កែលម្អដីឱ្យមានជីជាតិល្អប្រសើរ ។
- ជ្រើសរើសនិងទុកដាក់ពូជឱ្យបានល្អ ។
- គ្រប់គ្រងនិងថែរក្សាកូនដំណាំឱ្យបានល្អ ។
- ជ្រើសរើសដំណាំសម្រាប់ដាំឱ្យសមស្របទៅនឹងរដូវកាល និងប្រភេទដី ។




*គោលការណ៍សំខាន់ក្នុងការជ្រើសរើសគ្រាប់ពូជនិងកូនដំណាំ*

- យកចិត្តទុកដាក់ការពារកុំឱ្យសត្វល្អិតបំផ្លាញដំណាំ ។
- ដកស្មៅ បំផុសដីឱ្យបានល្អ ។
- កុំដាំដំណាំកៀកគ្នាពេក ឬបើកៀកពេកត្រូវដកចោលខ្លះ ។
- ដកចោលដំណាំណាដែលត្រូវបានបំផ្លាញដោយជំងឺ ដើម្បីកុំឱ្យឆ្លងដល់ដំណាំដទៃទៀត ។
- អនុវត្តនូវប្រព័ន្ធដាំដុះចម្រុះ (រូប. ក) ។
- បង្ហូរទឹកបានគ្រប់គ្រាន់ ចៀសវាងកុំឱ្យដីមានភាពជាំទឹកយូរ ។
- បង្កលក្ខខណ្ឌសមស្របសម្រាប់សត្វល្អិតមានប្រយោជន៍ ដើម្បីបំផ្លាញសត្វល្អិតចង្រៃដែលធ្វើឱ្យខូចដំណាំ ។
- ដាំដំណាំដែលបណ្ដេញសត្វល្អិតចង្រៃ (ដំណាំដែលមានក្លិនក្រពុលដូចជា ជី ស្លឹកគ្រៃ ផ្កាស្បៃរឿង ...) ។
- ការជ្រើសរើសគ្រាប់ពូជនិងកូនដំណាំ : រើសគ្រាប់ពូជដែលបាក់បែក គ្រាប់ដែលមានការបំផ្លាញពីសត្វល្អិតនិងគ្រាប់ប្រេះស្រាំដាក់ដោយឡែកពីគ្រាប់ដែលល្អ (រូប. ខ) ។
- ជ្រើសរើសយកគ្រាប់ពូជដែលមានគុណភាពល្អ គឺគ្រាប់នៅផ្នែកកណ្ដាលនៃផ្លែ ចំពោះពពួកសណ្ដែកនិងពោត (រូប. គ) ។
- ជ្រើសរើសយកតែគ្រាប់ពូជដំណាំដែលធ្ងន់លិចក្នុងទឹកយកទៅដាំ (រូប. ឃ) ។
- ជ្រើសរើសតែកូនរុក្ខជាតិណាដែលដុះត្រង់និងរឹងមាំសម្រាប់យកទៅដាំបន្តទៀត (រូប. ង) ។

## 2. ការការពារដំណាំទប់ទល់នឹងសត្វល្អិតចង្រៃ

ប្រទេសកម្ពុជា ជាប្រទេសកសិកម្ម ។ ដំណាំសំខាន់ៗដែលកសិករនិយមដាំ មានដំណាំផ្កានិងផ្លែ ដំណាំមើមនិងឫស និងដំណាំដើមស្លឹកនិងត្រួយ ... ។ ផលិតផលដំណាំទាំងនោះត្រូវបានបំផ្លាញដោយសត្វល្អិតនៅតាមដំណាក់កាលនៃវដ្តជីវិតរបស់វា ។ ប៉ុន្តែមានសត្វល្អិតប្រភេទខ្លះ មិនបំផ្លាញដំណាំរបស់យើងឡើយ ផ្ទុយទៅវិញវាជួយបង្កើនទិន្នផលដំណាំដូចជា នាំលំអងផ្កានិងបំផ្លាញសត្វល្អិតចង្រៃ

ដទៃទៀត ។ ដូចនេះដើម្បីការពារផលដំណាំ ការកំចាត់សត្វល្អិត គប្បីស្គាល់ប្រភេទសត្វល្អិតបំផ្លាញ និងកម្រិតនៃការបំផ្លាញរបស់វា ព្រោះយើងងាយស្រួលការពារនិងកំចាត់ ។ គោលបំណងនៃការថែរ-ក្សាដំណាំមិនមែនបំផ្លាញសត្វចង្រៃឱ្យអស់ទេ គឺគ្រាន់តែកាត់បន្ថយត្រឹមកម្រិតមួយដែលវាមិនអាចបំផ្លាញផលដំណាំអស់ច្រើន ។

ថ្នាំគីមីសម្លាប់សត្វល្អិតភាគច្រើន ច្រើនសម្លាប់សត្វល្អិតជាទូទៅ ទាំងសត្វល្អិតមានប្រយោជន៍ និងសត្វល្អិតចង្រៃ ហើយជារឿយៗ វាច្រើនជួយដល់ការកកើតសត្វល្អិតចង្រៃផ្សេងៗទៀតផង ។ ដូច្នេះយើងមិនត្រូវប្រើថ្នាំសម្លាប់សត្វល្អិតឡើយ ។ ការធ្វើរបាំងការពារ ការបញ្ឆោតរុយ ដាក់អន្ទាក់ ជាវិធីសាស្ត្រមួយក្នុងការការពារទល់ជាមួយសត្វល្អិតដែលបំផ្លាញដំណាំ ។ ជួនកាលគេដាំដំណាំមួយចំនួន ដែលអូសទាញសត្វល្អិតកុំឱ្យស៊ីដំណាំដែលគេយកផល (រូប.ក) ។ ជួនកាលគេដោតឈើរឹងជិតដើមឱ្យរួចផុតពីការបំផ្លាញរបស់ដង្កូវស៊ីស្លឹក (រូប.ខ) ។ គេអាចយកសំបកពងមាន់បែកដាក់ជុំវិញគល់ដំណាំ ដើម្បីការពារការបំផ្លាញពីសត្វខ្យង (រូប.គ) ។



ក ខ គ

ការបង្កលក្ខខណ្ឌសមស្របសម្រាប់បរាសិតនិងសត្វរំពា គឺជាផ្នែកមួយនៃការការពារនិងកំចាត់សត្វល្អិតចង្រៃដែរ ។ ប្រសិនបើដំណាំខ្លះបង្ហាញចេញនូវការខូចខាតធ្ងន់ធ្ងរ យើងអាចប្រើថ្នាំសម្លាប់សត្វល្អិតដែលផលិតពីរុក្ខជាតិ ឬសារធាតុគីមីងាយៗដូចជា ល្បាយសាប៊ូ ប្រេងកាតជាដើម ។ ប៉ុន្តែប្រភេទថ្នាំសម្លាប់សត្វល្អិតផ្សំពីស្លឹករុក្ខជាតិដូចជា ថ្នាំជក់ក៏បង្កផលអាក្រក់ដល់ពួកឃ្មុំ និងពួកសត្វល្អិតមានប្រយោជន៍ដទៃទៀតដែរ ។

## ៣. ការការពារដំណាំទប់ទល់នឹងជំងឺ

ជំងឺភាគច្រើនកើតចេញពីគ្រាប់ពូជ ឬពីដី ។ ដូចនេះយើងត្រូវដកគ្រាប់ខូច និងគ្រាប់មិនល្អចេញ ។ មុននឹងយកគ្រាប់ពូជទៅរក្សាទុកត្រូវហាលវាឱ្យស្ងួតជាមុនសិន ។ បន្ទាប់មកយើងត្រូវដាក់វានៅកន្លែងស្ងួតដូចជា ក្នុងកែវ ឬកំប៉ុងបិទជិតកុំឱ្យខ្យល់ចូល ប៉ុន្តែមិនត្រូវដាក់វាក្នុងថង់ប្លាស្ទិចឡើយ ។




*របៀបថែរក្សាទុកគ្រាប់ពូជ*

*ឧទាហរណ៍ :* គ្រាប់សណ្ដែកត្រូវហាលឱ្យស្ងួតល្អហើយប្រឡាក់ប្រេងឆា(ប្រេងរុក្ខជាតិ) មុននឹងយកទៅរក្សាទុកក្នុងដបកែវដែលបិទជិត ។

ចំណែកក្នុងដីមានមីក្រូសារពាង្គកាយមានប្រយោជន៍ជាច្រើន មីក្រូសារពាង្គកាយបំផ្លាញដំណាំមានតិចតួចណាស់ ។ ដីជាំទឹក ឬដីហាប់មានអុកស៊ីសែនតិចតួចបង្កលក្ខណៈសមស្របសម្រាប់មីក្រូសារពាង្គកាយ ដែលអាចបង្កជំងឺដល់រុក្ខជាតិ (ផ្សិតនិងបាក់តេរី) កើតឡើងច្រើន ។ ដូចនេះ យើងត្រូវធ្វើឱ្យដីធូរដោយកាប់បំផុស ឬជ្រោយវា ជាពិសេសសម្រាប់ដំណាំដែលមានឫសជ្រៅ ។ យើងត្រូវត្រួតពិនិត្យមើល ឬដុតចោលដំណាំមានជំងឺឱ្យបានទាន់ពេល ដើម្បីការពារកុំឱ្យវាឆ្លងជំងឺដល់ដំណាំដទៃទៀតតាមរយៈសត្វល្អិត ឬដៃមនុស្សដែលប៉ះពាល់ដំណាំទាំងនោះ ។

ជានិច្ចកាល យើងគួរចងចាំថាប្រសិនបើយើងមានដីដែលមានជីជាតិល្អនិងដាំដំណាំបានតាមរដូវត្រឹមត្រូវ ការបំផ្លាញដោយសត្វល្អិតនិងជំងឺត្រូវកាត់បន្ថយយ៉ាងច្រើន ។

## 4. ការថែរក្សាបរិស្ថាន

ថ្នាំគីមី ទោះបីជាទំនើបនិងមានកម្រិតជាតិពុលទាបបំផុតសម្រាប់មនុស្សនិងសត្វក៏ដោយ វាអាចប៉ះពាល់ដល់បរិស្ថាននិងជីវិតក្នុងធម្មជាតិ ប្រសិនបើមានការធ្វេសប្រហែសក្នុងការប្រើប្រាស់វា ។

នៅពេលប្រើប្រាស់ថ្នាំគីមី យើងអាចការពារបរិស្ថានដោយអនុវត្តដូចតទៅ

- កុំប្រើប្រាស់ថ្នាំដែលមានស្លាកថា "គ្រោះថ្នាក់ដល់ឃ្មុំក្នុងដំណាក់កាលរុក្ខជាតិចេញផ្កា" ។
- បាញ់ថ្នាំនៅពេលព្រឹកព្រលឹម ឬល្ងាចត្រជាក់ ។
- មិនត្រូវបាញ់ថ្នាំបញ្ច្រាស់ខ្យល់ខ្លាំង ព្រោះចំហាយជាតិថ្នាំអាចហើរដល់ទីកន្លែងឆ្ងាយៗបាន ។
- ផ្ដល់ដំណឹងដល់អ្នកជិតខាងពីការបាញ់ថ្នាំនិងទីកន្លែងដែលត្រូវបាញ់ថ្នាំ ដើម្បីចៀសវាងការឆ្លងកាត់ពីសំណាក់មនុស្សនិងសត្វ ។
- ចៀសវាងកុំឱ្យថ្នាំដែលប៉ះពាល់ដល់រុក្ខជាតិដទៃដែលជាជំរកនៃសត្វមានប្រយោជន៍ ។

- ជ្រើសរើសថ្នាំ ដែលមានប្រសិទ្ធភាពខ្ពស់និងមានកម្រិតជាតិពុលទាប ។
- គ្រាប់ពូជដែលលាយថ្នាំមិនត្រូវឱ្យជ្រុះឡើយ ។
- មិនត្រូវបាញ់ថ្នាំនៅក្បែរប្រភពទឹក ទីចិញ្ចឹមសត្វ ឬព្រៃឡើយ ។
- មិនត្រូវបោះចោលកញ្ចប់ ឬធុងដាក់ថ្នាំនៅក្នុងប្រភពទឹកឡើយ ។
- ត្រូវយល់ព័ត៌មានផ្សេងៗដែលមានសរសេរនៅលើស្លាកថ្នាំនីមួយៗឱ្យបានច្បាស់មុនប្រើប្រាស់ ។
- ចូរចងចាំថា ការប្រើថ្នាំពុលកសិកម្មអាចនាំមកនូវបញ្ហាជាច្រើនប្រភេទដល់ជីវិត សុខភាព និងបរិស្ថាន... ។



*ការប្រើថ្នាំពុលកសិកម្មអាចនាំមកនូវបញ្ហាជាច្រើនប្រភេទដល់យើងនិងគ្រួសារយើង ។*

## 5. ស្វ័យការពារខ្លួនរបស់រុក្ខជាតិ

រុក្ខជាតិច្រើនតែរងគ្រោះដោយការបំផ្លាញពីសត្វ ជាពិសេសពពួករុក្ខជាតិស្មៅ ។ ដូចនេះ រុក្ខជាតិត្រូវមានសរីរាង្គពិសេសនិងសារធាតុពិសេសសម្រាប់ការពារខ្លួនទប់ទល់នឹងសត្រូវ ។

### 5.1. សរីរាង្គពិសេសរបស់រុក្ខជាតិ

ផ្នែកផ្សេងៗនៃរុក្ខជាតិអាចមានសរីរាង្គពិសេសសម្រាប់ការពារខ្លួនរបស់វាទល់នឹងការបំផ្លាញរបស់សត្រូវ ។ សរីរាង្គពិសេសមានដូចខាងក្រោម


*ដើមដំបងយក្ស*

- **បន្លាមែក** : បន្លាមានលក្ខណៈដូចមែកនិងមានប្រភពមកពីជាលិកាផ្នែកខាងក្នុងរបស់រុក្ខជាតិ ។ បន្លាមែកមានរាងត្រង់រឹង ស្រួច ។ បន្លាមែកអាចមាននៅគល់ស្លឹក ជួនកាលនៅផ្នែកខាងចុងនៃដងដើមនិងមែក ។
  ***ឧទាហរណ៍ :*** បន្លាក្រូច បន្លាទទឹម ... ។
- **បន្លាស្លឹក** : បន្លាមានលក្ខណៈដូចស្លឹក ឬបំណែកនៃស្លឹកដែលមាននាទីសម្រាប់ការពារ ។
  ***ឧទាហរណ៍ :*** បន្លាម្នាស់ ។

- **បន្លាដើម :** បន្លាមានរាងកោងរឹង ហើយស្រួច ។ វាដុះឥតសណ្តាប់ធ្នាប់ពាសពេញលើដងដើម លើមែកនិងស្លឹក ។

  *ឧទាហរណ៍ :* បន្លាផ្តៅ បន្លាកូលាប ... ។

- **បន្លារោម :** រោមរឹង ខ្លីៗមានរាងដូចម្ជុល ដែលដុះជាកញ្ចុំ ។

  *ឧទាហរណ៍ :* បន្លាដើមដំបងយក្ស ... ។

- **រោមទិច (រោមពិស) :** រោមនៅលើស្លឹកនិងផ្លែ ឬលើដងដើមទាំងមូលតែម្តង ។ វាមានចុងស្រួច ហើយពេលប៉ះវាតែបន្តិចវានឹងបាក់ចូលក្នុងស្បែក ។ ផ្នែកខាងចុងនៃបន្លាមានជាតិពុលដែលធ្វើឱ្យរមាស់ ឬឈឺចុកចាប់ ។ *ឧទាហរណ៍* ដើមខ្ញែ ... ។

- **រោមក្លិនមិនល្អ (រោមពុល) :** រោមដុះយ៉ាងច្រើន ហើយក្រាស់នៅលើស្លឹកនិងដងដើម ជួនកាលដុះពាសពេញរុក្ខជាតិទាំងមូល ។ រោមនេះមានក្លិនមិនល្អ បើសត្វស៊ីអាចធ្វើឱ្យរមាស់ក ឬមានអារម្មណ៍មិនល្អ ។ *ឧទាហរណ៍* ដើមថ្នាំជក់ ។

## 5.2. សារធាតុពិសេសរបស់រុក្ខជាតិ

រុក្ខជាតិតែងតែបញ្ចេញសារធាតុផ្សេងៗ ។ រុក្ខជាតិខ្លះបញ្ចេញសារធាតុពុល ហើយរុក្ខជាតិខ្លះទៀតធ្វើឱ្យរមាស់ជាដើម ។ ប៉ុន្តែដោយសារសារធាតុទាំងនេះហើយ ទើបសត្វអាចធ្វើការបែងចែកបានយ៉ាងច្បាស់លាស់រវាងរុក្ខជាតិដែលអាចស៊ីបាននិងរុក្ខជាតិដែលមិនអាចស៊ីបាន ។ សារធាតុពិសេសទាំងនោះមាន

- **សារធាតុទឹកដោះ :** ជាជ័រដូចទឹកដោះ មានចំពោះប្រភេទរុក្ខជាតិមួយចំនួនដូចជា ដើមកៅស៊ូ ដើមចំប៉ី ដើមទឹកដោះគោ ល្មុត ... ។



*ល្មុត* *ផ្លែទឹកដោះគោ* *កៅស៊ូ* *ដើមចំប៉ី*

- **សារធាតុរោល :** ជាជ័រមានពណ៌ថ្លា មានចំពោះប្រភេទរុក្ខជាតិមួយចំនួនដូចជាស្វាយ ក្រូច ល្ហុង ជ័រប្រភេទនេះអាចបណ្តាលឱ្យរោលកាលណាប៉ះជាមួយស្បែក ។



*ល្ហុង* *ស្វាយ* *ក្រូច*

- **សារធាតុហឹរ** ៖ ជាសារធាតុឆួល មានចំពោះរុក្ខជាតិមួយចំនួន ដូចជាម្ទេស ខ្ទឹម ... ដែលធ្វើឱ្យសត្វមិនចូលចិត្តស៊ីនិងមិនហ៊ានមកក្បែរ ។
- **សារធាតុពណ៌** ៖ ជាសារធាតុរបស់រុក្ខជាតិមួយចំនួនមានពណ៌ផ្សេងៗដូចជា ព្រីង ជន្លង់ ... ដែលធ្វើឱ្យសត្វមិនហ៊ានចូលជិត ។
- **សារធាតុល្វីង** ៖ ជាសារធាតុរបស់ប្រភេទរុក្ខជាតិមួយចំនួន មានរសជាតិល្វីង ...ដែលធ្វើឱ្យសត្វមិនចូលចិត្តស៊ី ។


ម្ទេស


ខ្ទឹម


ជន្លង់


ព្រីង


ម្រះ


ស្ដៅ

## មេរៀនសង្ខេប

- ទោះបីថ្នាំគីមីមានកម្រិតជាតិពុលទាបបំផុតសម្រាប់មនុស្សនិងសត្វ ក៏វាអាចប៉ះពាល់ដល់បរិស្ថាននិងជីវិតនៅក្នុងធម្មជាតិ បើសិនជាយើងធ្វេសប្រហែសក្នុងការប្រើប្រាស់វា ។
- រុក្ខជាតិជាច្រើនតែងទទួលរងគ្រោះដោយការបំផ្លាញពីសត្វ ជាពិសេសចំពោះពពួករុក្ខជាតិស្មៅ ។ ដូចនេះរុក្ខជាតិត្រូវមានសរីរាង្គពិសេសនិងសារធាតុពិសេសសម្រាប់ការពារខ្លួនរបស់វាទប់ទល់នឹងសត្រូវ ។
- ផ្នែកផ្សេងៗនៃរុក្ខជាតិអាចមានសរីរាង្គពិសេស សម្រាប់ការពារខ្លួនរបស់វាដូចជា បន្លាមែក បន្លាស្លឹក បន្លាដើម បន្លារោម រោមទិច រោមមានក្លិនមិនល្អជាដើម ។
- រុក្ខជាតិខ្លះមានជាតិពុល ឬសារធាតុធ្វើឱ្យរមាស់ ដែលធ្វើឱ្យសត្វស៊ីមិនបាន ។ សារធាតុទាំងនេះមានជ័រ សារធាតុពុល សារធាតុរោល រសជាតិល្វីងនិងក្លិនមិនល្អ ពួករុក្ខជាតិដែលមាន-ពណ៌ប្លែកៗ ។

## សំណួរ

1. ចូររៀបរាប់ពីគោលការណ៍ធម្មជាតិក្នុងការថែរក្សាដំណាំពីការបំផ្លាញរបស់សត្វចង្រៃនិងជំងឺ ។
2. ចូររៀបរាប់ពីគោលការណ៍សំខាន់ៗក្នុងការជ្រើសរើសគ្រាប់ពូជនិងកូនដំណាំសម្រាប់យកទៅដាំបន្ត ។
3. ចូរនិយាយពីរបៀបរក្សាទុកគ្រាប់ពូជ ។
4. ដើម្បីកុំឱ្យមានផលប៉ះពាល់ នៅពេលយើងប្រើថ្នាំពុលគីមីនៅលើដំណាំ តើត្រូវការពារបរិស្ថាននិងជីវិតធម្មជាតិដូចម្ដេច ?
5. ដើម្បីការពារខ្លួនមិនឱ្យសត្វស៊ី តើរុក្ខជាតិមានលក្ខណៈអ្វីខ្លះ ?
6. ចូរពណ៌នាពីលក្ខណៈពិសេសនីមួយៗរបស់រុក្ខជាតិ ដោយឱ្យឧទាហរណ៍ ។
7. ចំពោះសត្វចតុប្បាទ (គោ ក្របី ចៀម) ដែលគេប្រលែងវាឱ្យដើររកស៊ីនៅតាមវាលស្រែ ឬចំការ (ក្រោយរដូវទទួលផលរួច) ឬព្រៃភ្នំ។ ចូរលើកឧទាហរណ៍ពីលក្ខណៈរបស់រុក្ខជាតិដែលប្អូនបានឃើញសត្វចតុប្បាទទាំងនោះស៊ីមិនបាន ។

## សំណួរបញ្ចប់ជំពូកទី១

**I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវ**

1 សត្វល្អិតមានប្រយោជន៍ដូចជា

☐ក. ពួករំពា ☐ខ. ពួកបរាសិត

☐គ. ពួកបង្កជំងឺលើសត្វល្អិតចង្រៃ ☐ឃ. ចម្លើយ ក ខ គ ត្រូវ ។

2. អំណះអំណាងដែលមិនមែនជាគោលការណ៍ធម្មជាតិក្នុងការការពារដំណាំទប់ទល់នឹងការបំផ្លាញពីសត្វល្អិតចង្រៃនិងជំងឺមាន

☐ក. ការប្រើថ្នាំពុលគីមី ☐ខ. ការជ្រើសរើសនិងទុកដាក់គ្រាប់ពូជឱ្យបានល្អ

☐គ. ការដកស្មៅបំផុសដីបានល្អ ☐គ. ការបង្ហូរទឹក ចៀសវាងកុំឱ្យដីមានភាពជាំទឹក

3 សរីរាង្គពិសេសសម្រាប់ការពារខ្លួនរបស់រុក្ខជាតិទប់ទល់នឹងសត្រូវមាន

☐ក. ស្លឹក ☐ខ. ដងដើម

☐គ. មែក ☐ឃ. បន្លា ។

## II. សំណួរត្រិះរិះ

1. ក្នុងការកំចាត់សត្វល្អិតចង្រៃបំផ្លាញដំណាំមានការចូលរួមពីប្រភេទសត្វល្អិតមានប្រយោជន៍ ដែលយើងតែងតែជួបប្រទះជាញឹកញាប់មាន ពួក ........ ពួក ........ និងពួក ........... ។
2. ស្លឹករុក្ខជាតិច្រើនរងនូវជំងឺផ្សេងៗដូចជា ជំងឺ ........ ជំងឺ .......... និងជំងឺ .............. ។
3. ជំងឺបង្កឱ្យមានការបែកញើសក្រោមស្លឹក ហើយកន្លែងដែលបែកញើសទៅជាស្លោកបាក់រលួយ គឺជាជំងឺ ................ ។
4. ជំងឺដែលធ្វើឱ្យមានអុជៗពណ៌ច្រែះលើផ្ទៃស្លឹកខាងក្រោម រួចឆ្លងមកដល់ផ្ទៃស្លឹកផ្នែកខាងលើ គឺជាជំងឺ ................ ។
5. រុក្ខជាតិមានស្លឹកក្រហមរួញដូចនំក្រៀបនិងជំងឺនេះរាលដាលយ៉ាងលឿននៅពេលអាកាសធាតុស្ងួត គឺជាជំងឺ ........... ។

## III. សំណួរ

1. តើនៅក្នុងតំបន់ដែលប្អូនរស់នៅ គេច្រើនអនុវត្តវិធីអ្វីក្នុងការប្រយុទ្ធនឹងសត្វចង្រៃបំផ្លាញដំណាំស្រូវ ? ចូរនិយាយពីវិធីនេះ ។
2. ហេតុអ្វីបានជាយើងមិនគួរបំផ្លាញសត្វល្អិតចង្រៃឱ្យអស់ យើងគ្រាន់តែកាត់បន្ថយត្រឹមកម្រិតដែលវាមិនបំផ្លាញដំណាំបានច្រើនប៉ុណ្ណោះ ?
3. ហេតុអ្វីបានជាយើងមិនគួរគប្បីបំផ្លាញបក្សី អំបូរកង្កែប ដែលនៅក្នុងស្រែចំការ ?
4. ហេតុអ្វីនៅពេលដាំដំណាំ យើងត្រូវកាប់បំផុសដីឱ្យធូរឬផ្លាស់ដីសម្រាប់ដំណាំដែលមានឫសក្រៅ ?
5. ហេតុអ្វីបានជាការថែរក្សាដំណាំកុំឱ្យមានការបំផ្លាញពីសត្វល្អិតចង្រៃនិងជំងឺ គេយកវិធីដាំដុះមកប្រើ ?

# ជំពូកទី 2 បរិស្ថានធម្មជាតិ



តំបន់ដីសើមនៃបឹងទន្លេសាបសម្បូរទៅដោយព្រៃលិចទឹកដែលជាជំរករបស់ហ្វូងសត្វស្លាបទឹកធ្វើសំបុកស្នាក់នៅ

នៅក្នុងស្ថានប្រព័ន្ធមួយមានភាវៈមានជីវិតនិងភាវៈគ្មានជីវិត ។ ភាវៈមានជីវិតដូចជា សត្វរុក្ខជាតិនិងមីក្រូសារពាង្គកាយដែលមានអំពើលើគ្នាទៅវិញទៅមក និងជាមួយភាវៈគ្មានជីវិតផងដែរ ។ ភាវៈគ្មានជីវិតដូចជាសីតុណ្ហភាព ពន្លឺព្រះអាទិត្យ សំណើម ទឹក ដី ... អាចមានឥទ្ធិពលទៅលើភាវៈមានជីវិត ។

មេរៀនទី

# 1 ស្ថានប្រព័ន្ធតាមមូលដ្ឋាន

**ចប់មេរៀននេះ សិស្សអាច**

- រាប់ឈ្មោះប្បូមដីគោកនិងប្បូមទឹកសំខាន់ៗនៅលើផែនដី
- ពណ៌នាពីលក្ខណៈពិសេសរបស់ប្បូមដីគោកនិងប្បូមទឹកនីមួយៗ
- បង្ហាញពីស្ថានប្រព័ន្ធបឹងទន្លេសាបដែលជាប្រព័ន្ធទឹកសាបមួយប្រភេទ ។

គេចែកស្ថានប្រព័ន្ធនៅលើផែនដីជា ប្បូមដីគោកនិងប្បូមទឹក ។ ប្បូម ជាតំបន់ភូមិសាស្ត្រធំទូលាយជាមួយអាកាសធាតុពិសេស ព្រមទាំងសហគមន៍សត្វ និងប្រភេទរុក្ខជាតិ ។

## 1. ប្បូមដីគោក

ប្បូមដីគោកសំខាន់ៗមាន ទុនដ្រា ព្រៃតៃកា ព្រៃឈើជ្រុះស្លឹកតំបន់ត្រជាក់បង្គួរ វាលស្មៅ វាលលំហខ្សាច់ និងព្រៃរងទឹកភ្លៀងតំបន់ត្រូពិច ។

### 1.1. ទុនដ្រា



ទុនដ្រាជាប្បូម ដែលមានភ្លៀងតិចតួច ប៉ុន្តែសីតុណ្ហភាពត្រជាក់ខ្លាំងស្ទើរពេញមួយឆ្នាំធ្វើឱ្យផ្ទៃដីគ្របដណ្តប់ដោយទឹកកក ។ រដូវដាំដុះនិងរដូវក្តៅមានរយៈពេលខ្លី ។ ទុនដ្រាជាជំរកសត្វល្អិតដូចជា មូស សុច និងសត្វស្លាប (សត្វទាក្ងាន...) ជាច្រើនលានក្បាល ។ សត្វដទៃទៀតមាន ទន្សាយស្លឹក ក្តាន់ កញ្ជ្រោង ចចកជាដើម ។ រុក្ខជាតិរួមមាន លីកែន ស្លែ ស្មៅ ចុល្លព្រឹក្ស និងរុក្ខជាតិឈើទាបៗ ។

### 1.2. វាលស្មៅ



ប្រហែលមួយភាគបួននៃផ្ទៃផែនដី គ្របដណ្តប់ដោយប្បូមវាលស្មៅដែលមាន សីតុណ្ហភាពក្តៅហួតហែងនៅរដូវក្តៅ និងត្រជាក់ក្រោមសូន្យនៅរដូវរងា ។ ថនិកសត្វរស់នៅតំបន់

នោះមាន ក្របីអាមេរិច សេះបង្កង់ ស៊ីវ៉ាប់ សត្វល្អិតច្រើនប្រភេទ និងបក្សី ។ វាលស្មៅមានសារៈសំខាន់ណាស់ចំពោះមនុស្ស ។ ព្រោះសម្បូរទៅដោយកសិដ្ឋាន ដែលជាកន្លែងផលិតអាហារច្រើនជាងគេសម្រាប់ប្រជាជនលើពិភពលោក ។

## 1.3. ព្រៃតៃកា

ព្រៃតៃកាមានរដូវត្រជាក់វែង ហើយផ្ទៃដីគ្របដណ្ដប់ដោយទឹកកកយ៉ាងក្រាស់ ។ រដូវរងាំដុះមានរយៈពេលវែងជាងនៅទុនដ្រា ។ នៅរដូវក្ដៅអាកាសធាតុក្ដៅជាងនៅទុនដ្រា ។ នៅទីនោះមានបឹង និងវាលល្បប់ភក់សម្បូរសត្វល្អិត ត្រី និងសត្វស្លាប ។ ពពួករុក្ខជាតិមានស្រល់ បណ្ណង្គជាតិនិងស្លែ ។ ថនិកសត្វមានចចក ខ្លាឃ្មុំ ក្ដាន់ កញ្ជ្រោង ប្រមា និងសត្វកកេរផ្សេងៗ ។

## 1.4. ព្រៃឈើជ្រុះស្លឹកនៅតំបន់ត្រជាក់បង្គួរ



រុក្ខជាតិដុះជាស្រទាប់ឬថ្នាក់

នៅតំបន់នេះមាន សីតុណ្ហភាពនៅរដូវក្ដៅមានប្រហែល 35°C ។ ដើមឈើតែងតែជ្រុះស្លឹកធំៗរៀងរាល់រដូវស្លឹកឈើជ្រុះ ។ អាកាសធាតុក្ដៅហើយសើមព្រមទាំងដីសម្បូរជីជាតិ ។ រុក្ខជាតិនៅទីនោះច្រើនដុះលូតលាស់ជាស្រទាប់ឬថ្នាក់ ។ ចំពោះបណ្ណង្គជាតិស្មៅ ស្លែគ្របដណ្ដប់លើជាកម្រាលព្រៃ ។ សត្វនៅទីនោះរួមមានសត្វល្អិតបក្សីល្មូនកង្កែប និងថនិកសត្វមានខ្លាឃ្មុំ ចចកកញ្ជ្រោង កំប្រុកក្ដាន់ ឈ្លូសប្រើស... ។

## 1.5. វាលលំហខ្សាច់



រុក្ខជាតិដុះនៅវាលលំហខ្សាច់

វាលលំហខ្សាច់មានសីតុណ្ហភាពខ្ពស់និងភ្លៀងតិច ។ សីតុណ្ហភាពក្ដៅខ្លាំងនៅពេលថ្ងៃ ត្រជាក់ខ្លាំងនៅពេលយប់ ។ រុក្ខជាតិភាគច្រើននៅវាលលំហខ្សាច់ស្តុកទឹកដូចជាដើមដំបងយក្សនិងប្រភេទរុក្ខជាតិដែលមានប្រព័ន្ធឫសជ្រៅស្លឹកល្អិត ឬរាងម្ជុល (ចុល្លព្រឹក្ស) ។ សត្វថ្លែន បង្គួយ ពស់ ស្បែករបស់វាមានស្រកាសម្រាប់ការពារកុំឱ្យបាត់បង់ជាតិទឹក ។ ជាធម្មតាសត្វច្រើនធ្វើសកម្មភាពនៅពេលយប់ ហើយលាក់ខ្លួននៅពេលថ្ងៃ ។

### 1.៦. ព្រៃរងទឹកភ្លៀងតំបន់ត្រូពិច



*រុក្ខជាតិព្រៃរងទឹកភ្លៀង*

ព្រៃរងទឹកភ្លៀងតំបន់ត្រូពិចសើមហើយក្តៅជាប់ជានិច្ច ។ វាទទួលបានពន្លឺពេញមួយឆ្នាំ ហើយអាកាសធាតុមានបម្រែបម្រួលតិចណាស់ក្នុងរដូវនីមួយៗ ។ ព្រៃនេះមានប្រភេទសារពាង្គកាយច្រើនជាងនៅប្រូមដីគោកដទៃទៀតដូចជា បណ្តុំជាតិ ស្លែ វល្លិ និងរុក្ខជាតិដទៃទៀត ។ ក្រៅពីរុក្ខជាតិព្រៃរងទឹកភ្លៀងតំបន់ត្រូពិចជាជំរកដ៏ធំធេងសម្រាប់សត្វផ្សេងៗដូចជាសត្វល្អិត បក្សីច្រើនប្រភេទនិងថនិកសត្វមានស្វា ខ្លាដំបងប្រជៀវ ជ្រូង... ។

## ២. ប្រូមទឹក

ភាគច្រើននៃផ្ទៃផែនដីគ្របដណ្តប់ដោយទឹក ។ ប្រូមទឹកសំខាន់មានពីរ ប្រូមសមុទ្រ និងប្រូមទឹកសាប ។

### ២.១. ប្រូមសមុទ្រ

ប្រូមសមុទ្រគ្របដណ្តប់ប្រហែល 70% នៃផ្ទៃផែនដី ។ មហាសមុទ្រចែកជាតំបន់ផ្សេងៗដោយផ្អែកទៅលើជម្រៅទឹកនៅក្នុងតំបន់មួយចំនួនដូចជា

#### ក. តំបន់ឆ្នេរ

តំបន់ឆ្នេរជាតំបន់នៅតាមបណ្តោយមាត់សមុទ្រដែលគ្របដណ្តប់ដោយទឹកនៅពេលជំនោរ និងនៅក្រោមខ្យល់ពេលលំនាច ។ នៅតំបន់នេះមានខ្យងតូចៗ លៀស ក្តាម និងរុក្ខជាតិសមុទ្រតូចៗមានសារាយជាដើម ... ។

#### ខ. តំបន់ក្បែរឆ្នេរ

ផ្នែកនៃមហាសមុទ្រដែលចោតចុះក្រោមជាស្រទាប់ទ្វីប ។ តំបន់ឆ្នេរជាកន្លែងទឹករាក់ដែលនៅខាងលើស្រទាប់ទ្វីប ។ ទឹកមានជានិច្ចគ្របដណ្តប់តំបន់នេះ ។ ទីនេះមានពន្លឺគ្រប់គ្រាន់និងសារធាតុចិញ្ចឹមដែលជួយទ្រទ្រង់សារពាង្គកាយច្រើនប្រភេទដូចជា ងាវ និងត្រីអណ្តែតលើផ្ទៃទឹក ។

## គ. តំបន់លំហសមុទ្រ

តំបន់លំហសមុទ្រស្ថិតនៅបន្ទាប់តំបន់ក្បែរឆ្នេរ។ តំបន់នេះងងឹតជានិច្ច ហើយត្រជាក់ខ្លាំងនិងសម្ពាធទឹកភ្លៀងខ្ពស់ ព្រោះពន្លឺនិងសីតុណ្ហភាពថយចុះនៅពេលដែលជម្រៅទឹកកើនឡើងនិងសម្ពាធទឹកកើនឡើងជាមួយជម្រៅទឹក។ ស្រទាប់ខាងលើនៃតំបន់នេះមានប្លង់តុងរុក្ខជាតិ ឆ្លាម បាឡែន មឹក។ នៅក្នុងជម្រៅបាតសមុទ្រមានសត្វស៊ីគំរង់ វាចិញ្ចឹមជីវិតដោយសាកសពដែលធ្លាក់ចុះពីលើ។




*តំបន់ផ្សេងៗនៃមហាសមុទ្រ*

## 2.2. ប្រព័ន្ធទឹកសាប

ប្រព័ន្ធទឹកសាបមាន ស្ទឹង ទន្លេ ជ្រោះ អូរ បឹងត្រពាំង និងដីសើម។

## ក. បឹងនិងត្រពាំង



*ស្ថានប្រព័ន្ធបឹងទន្លេសាប*



ប្លង់តុងសត្វ



ប្លង់តុងរុក្ខជាតិ

បឹងនិងត្រពាំងជាកន្លែងទឹកស្ងប់ ។ តាមធម្មតាបឹងច្រើនមានទំហំធំហើយជ្រៅជាងត្រពាំង ។

*ឧទាហរណ៍ :* ស្ថានប្រព័ន្ធបឹងទន្លេសាបឬបឹងធំដែលជាអាងទឹកធម្មជាតិធំជាងគេបង្អស់នៅប្រទេសកម្ពុជានិងនៅភូមិភាគអាស៊ីអាគ្នេយ៍មាន

- ភាវៈស្វ័យជីពជាសារពាង្គកាយដែលធ្វើរស្មីសំយោគយកថាមពលពីព្រះអាទិត្យ ដូចជានៅជុំវិញមាត់បឹងមានដើមកន្ទុយឆ្មានិងប្របុស ។ ក្នុងជម្រៅទឹករុក្ខជាតិអណ្តែតលើផ្ទៃទឹកដូចជា ព្រលិត និងរំចង់ដុះនៅទីនោះ និងហួសឆ្ងាយពីមាត់បឹង ទីលំហទឹកមានប្លង់តុងរុក្ខជាតិ ។
- ភាវៈបរជីពមានរុក្ខាសីនិងមំសាសី ។ ក្រុមរុក្ខាសីមានប្លង់តុងសត្វនិងសារពាង្គកាយដែលរស់នៅបាតបឹង ។ រីឯមំសាសីអាចជាប្លង់តុងសត្វឬសត្វដែលរស់នៅបាតបឹងនៃកន្លែងទឹករាក់ដូចជាសត្វល្អិត បង្កង កំពិស ដង្កូវ លៀស ខ្យង... ។ អណ្តើកមាស មូស ត្រី កង្កែប ត្រកួត ថ្លែន អណ្តើក និងពស់ហែលដោយសេរី ។
- អ្នកបំបែកអាចជាសារពាង្គកាយប្លែកៗពីគ្នាជាច្រើនដូចជាបាក់តេរី ពពួកផ្សិត សត្វល្អិត ដង្កូវ... ដែលចិញ្ចឹមជីវិតដោយសាកសពរុក្ខជាតិឬសត្វ ។ សារពាង្គកាយទាំងនេះរស់នៅក្នុងកម្ទេចកំណបាតបឹង ។
- ភាវៈគ្មានជីវិតមានពន្លឺព្រះអាទិត្យ សីតុណ្ហភាព ទឹកភ្លៀង ខ្យល់... ដែលធ្វើឱ្យជីវិតងាយក្នុងការរស់នៅ ។

ជារួមស្ថានប្រព័ន្ធបឹងទន្លេសាបសម្បូរទៅដោយសារពាង្គកាយរស់ ។

## ១. ដីសើម (តំបន់ទឹកនិងដីរលាយចូលគ្នា)

ដីសើមជាតំបន់គ្របដណ្តប់ដោយទឹកយ៉ាងហោចណាស់មួយរយៈពេលដែរក្នុងមួយឆ្នាំ ។ បឹងទន្លេសាបជាតំបន់ដីសើមមួយយ៉ាងសំខាន់ ។ ដីប្រហែល 70% នៃតំបន់ដីសើមបឹងទន្លេសាបនេះជាព្រៃលិចទឹកដែលមានដុះរុក្ខជាតិជាច្រើនប្រភេទ ។ ស្ថានប្រព័ន្ធនេះជាសំបុកនិងជាជំរកយ៉ាងសំខាន់សម្រាប់បក្សីទឹកនិងប្រភេទត្រីផ្សេងៗ ។ ម្យ៉ាងទៀតដោយសារស្ថានប្រព័ន្ធបឹងទន្លេសាបសម្បូរព្រៃលិចទឹកដូចនេះវាអាចចៀសផុតពីព្យុះនានា អាកាសធាតុពុំសូវប្រែប្រួល ព្រមទាំងទប់ស្កាត់ការហូរច្រោះដីបានទៀតផង ។



*តំបន់ដីសើមបឹងទន្លេសាប សម្បូរទៅដោយព្រៃលិចទឹក*

វាអាចបំបាត់សារធាតុពុលចេញពីទឹកនិងបង្ការទឹកជំនន់ដោយការស្រូបទឹកនៅសល់ពីស្ទឹងនិងទន្លេដែលជន់លិច ។ ជាពិសេសទៅទៀតបឹងទន្លេសាបជាតំបន់ដីសើមដែលផ្ដល់ទិន្នផលត្រីច្រើនជាងគេបំផុតនៅលើពិភពលោក ។

## មេរៀនសង្ខេប

- ប្រូម ជាតំបន់ភូមិសាស្ត្រធំទូលាយជាមួយអាកាសធាតុពិសេស ព្រមទាំងសហគមន៍សត្វនិងប្រភេទរុក្ខជាតិនៅតំបន់នោះ ។
- ប្រូមចែកជាពីរក្រុមធំៗ គឺប្រូមដីគោកនិងប្រូមទឹក ។
- ប្រូមទឹកមានពីរបែប : ប្រូមទឹកប្រៃ និងប្រូមទឹកសាប ។
- មហាសមុទ្រចែកទៅជាបីតំបន់: តំបន់ឆ្នេរ តំបន់ក្បែរឆ្នេរ និងតំបន់វាលលំហសមុទ្រ ។
- ប្រូមទឹកសាបមាន : ទឹកហូរ ទឹកស្ងប់ និងដីសើម ។ ទឹកហូររួមមាន ជ្រោះ ទន្លេ ទឹកស្ងប់មានបឹង ត្រពាំង និងដីសើមមានទឹកនិងដីរលាយចូលគ្នា ។

## សំណួរ

1. ចូរពន្យល់ពាក្យ "ប្រូម" ។
2. តើប្រូមដីគោកនីមួយៗមានអាកាសធាតុយ៉ាងដូចម្ដេច ?
3. តើហេតុអ្វីបានជាតំបន់វាលស្មៅមានសារៈសំខាន់ចំពោះមនុស្ស ?
4. តើនៅពេលដែលជម្រៅទឹកកើនឡើង ពន្លឺ សីតុណ្ហភាព និងសម្ពាធទឹកប្រែប្រួលយ៉ាងដូចម្ដេច ?
5. តើមហាសមុទ្រចែកជាប៉ុន្មានតំបន់ ? អ្វីខ្លះ ?
6. ចូររៀបរាប់ឈ្មោះប្រូមទឹកសាបនៅប្រទេសកម្ពុជាដែលប្អូនបានស្គាល់ ?
7. តើព្រៃលិចទឹកនៅតំបន់ដីសើមបឹងទន្លេសាបមានសារប្រយោជន៍អ្វីខ្លះ ?

មេរៀនទី

# 2 ទំនាក់ទំនងអាហារក្នុងបរិស្ថាន

**ចប់មេរៀននេះ សិស្សអាច**

- ពន្យល់ពាក្យសត្វរំពា រំពា និងការចាប់រំពា
- ឱ្យឧទាហរណ៍ពីការប្រកួតប្រជែងដើម្បីតម្រូវការធនធានក្នុងការរស់នៅ
- ពណ៌នាពីខ្សែអាហារ បណ្ដាញអាហារ និងបន្ទេរថាមពលក្នុងស្ថានប្រព័ន្ធ
- ពណ៌នាពីការបាត់បង់ថាមពលក្នុងបរិស្ថាន
- សង់ខ្សែអាហារ បណ្ដាញអាហារ នៅក្នុងបរិស្ថានណាមួយ ។

សារពាង្គកាយនីមួយៗមិនអាចរស់នៅដាច់តែឯងបានទេ ។ សារពាង្គកាយទាំងនេះមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមកតាមវិធីច្រើនបែបដូចជា សហប្រាណ ការប្រកួតប្រជែង ការចាប់រំពា ។

## 1. ការចាប់រំពា

សត្វរំពា ជាសត្វដែលសម្លាប់សត្វដទៃទៀតជាអាហារ ។ សត្វដែលត្រូវគេសម្លាប់ហៅថា រំពា ។ ទំនាក់ទំនងរវាងសត្វទាំងពីរហៅថា ការចាប់រំពា ។ *ឧទាហរណ៍* សត្វខ្លែងស្រាកតាមប្រមាញ់សត្វកណ្ដុរធ្វើជាអាហារ ។ ខ្លែងស្រាកជាសត្វរំពា ។ កណ្ដុរជារំពា ។ នៅពេលពពួកសត្វខ្លែងស្រាក់កើនចំនួន ពពួកសត្វកណ្ដុរថយចុះ ។ សត្វរំពានិងរំពាមានឥទ្ធិពលលើគ្នាទៅវិញទៅមក ។



*បក្សីចាប់រំពា*

## 2. ការប្រកួតប្រជែង

ការប្រកួតប្រជែងជាទំនាក់ទំនងដែលក្នុងនោះសារពាង្គកាយពីរប្រយុទ្ធគ្នា ដើម្បីតម្រូវការធនធានដូចជាពន្លឺ អាហារ ទឹក ដី ចាំបាច់ក្នុងការរស់នៅ ។

*ឧទាហរណ៍* : ក្នុងព្រៃ រុក្ខជាតិខ្ពស់ៗប្រជែងស្រូបយកពន្លឺ ឧស្ម័នកាបូនិច សារធាតុខនិជ និងទឹកបានច្រើនជាងរុក្ខជាតិតូចៗ ។ ចំណែករុក្ខជាតិតូចៗត្រូវការកត្តារូបទាំងនេះដែរមិនអាចរស់នៅក្រោមម្លប់ឈើធំៗបានទេ ។ ដូចនេះរុក្ខជាតិតូចៗមិនអាចសម្របខ្លួនទៅក្នុងនិងលក្ខខណ្ឌនេះនឹងត្រូវបាត់បង់ ។

# 3. បន្ទេរថាមពលក្នុងបរិស្ថាន

នៅក្នុងបរិស្ថានថាមពលត្រូវបានផ្ទេរពីសារពាង្គកាយមួយទៅសារពាង្គកាយមួយទៀតតាមរយៈអាហារ ។ សារពាង្គកាយនីមួយៗមានទំនាក់ទំនងផ្នែកអាហារនិងគ្នាជា**ខ្សែអាហារនិងបណ្តាញអាហារ** ។

## 3.1. ខ្សែអាហារ




នៅក្នុងស្ថានប្រព័ន្ធចំការសណ្តែកសៀងមួយដែលក្នុងនោះរុក្ខជាតិបៃតង(សណ្តែកសៀង)ជាអ្នកផលិត ហើយត្រូវដង្កូវបាក់ខ្នងស៊ី ។ បន្ទាប់មកពីងពាងស៊ីដង្កូវបាក់ខ្នង ។ ទំនាក់ទំនងនៃសារពាង្គកាយបែបនេះហៅថា **ខ្សែអាហារ** ។

ខ្សែអាហារខ្លះទៀតមានចំនួនសារពាង្គកាយច្រើនដូចជា




*ខ្សែអាហារ*

## 3.2. បន្ទេរថាមពលក្នុងខ្សែអាហារ




*បន្ទេរថាមពលតាមខ្សែអាហារ*

រាល់ពេលដែលអាហារត្រូវគេស៊ីថាមពលក៏ត្រូវបានផ្ទេរពីអាហារទៅអ្នកស៊ីនោះដែរ ។ ដូចនេះខ្សែអាហារមួយគឺជាស៊េរីមួយនៃសារពាង្គកាយ ដែលតាមរយៈនោះថាមពលត្រូវផ្ទេរក្រោមរូបភាពជាអាហារ ។ ខ្សែអាហារបង្ហាញពីទំនាក់ទំនងផ្នែកអាហាររវាងសារពាង្គកាយនិងថាមពលនៃអាហារដែលត្រូវផ្ទេរពីសារពាង្គកាយមួយទៅសារពាង្គកាយមួយទៀត ។

## 3.3. ការបាត់បង់ថាមពល



*ការបាត់បង់ថាមពលតាមខ្សែអាហារ*

គំនូសបំព្រួញនេះបង្ហាញពីការបាត់បង់ថាមពលដែលត្រូវផ្ទេរតាមច្រវាក់នីមួយៗនៃខ្សែអាហារ ។

នៅពេលដែលកណ្ដូបមួយស៊ីស្លឹករុក្ខជាតិថាមពលត្រូវផ្ទេរទាំងអស់ពីស្លឹករុក្ខជាតិទៅកណ្ដូប ប៉ុន្តែថាមពលត្រូវបាត់បង់ជាច្រើនតាមកាកសំណល់ ព្រោះកណ្ដូបមិនអាចរំលាយអាហារទាំងអស់ដែលវាស៊ីនោះទេ និងថាមពលខ្លះទៀតកណ្ដូបប្រើប្រាស់ក្នុងបំលាស់ទី រំលាយអាហារនិងដកដង្ហើម ដូចនេះនៅសល់តែបរិមាណថាមពលតិចតួចដែលស្ដុកទុកនៅក្នុងខ្លួនកណ្ដូបសម្រាប់ការលូតលាស់ធំធាត់របស់វា ។ ថាមពលនៅសល់តិចតួចប៉ុណ្ណោះទេដែលត្រូវផ្ទេរទៅសត្វមាន់ដែលជាអ្នកស៊ីបន្ទាប់ក្នុងខ្សែអាហារ ។ នៅទីបញ្ចប់នៅសល់តែបរិមាណតិចតួចប៉ុណ្ណោះ ដែលត្រូវផ្ទេរទៅអ្នកស៊ីបន្ទាប់ក្នុងខ្សែអាហារ ។ ដូចនេះ តាមខ្សែអាហារ ថាមពលស្ដុកទុកកាន់តែថយចុះ ។

## 3.4. បណ្ដាញអាហារ



*បណ្ដាញអាហារ*

នៅក្នុងស្ថានប្រព័ន្ធធម្មជាតិ តែងតែមានខ្សែអាហារច្រើនជាងមួយ ។ ខ្សែអាហារច្រើនដែលមានទំនាក់ទំនងយ៉ាងសាំញ៉ាំហៅថា **បណ្ដាញអាហារ** ។ នៅក្នុងបណ្ដាញអាហារ ប្រភេទនីមួយៗនៃអ្នកផលិតនិងអ្នកស៊ីត្រូវស៊ីដោយសារពាង្គកាយអ្នកស៊ីច្រើនប្រភេទទៀត ។

*ឧទាហរណ៍ :* សារាយជាអ្នកផលិតត្រូវស៊ីដោយសារពាង្គកាយអ្នកស៊ីច្រើនប្រភេទមាន ខ្យង ក្តាម ត្រី និងកង្កែប ។ ចំណែកអ្នកស៊ីវិញមានក្តាមត្រូវស៊ីដោយមាន់និងកង្កែប ។ រីឯអ្នកបំបែកមានផ្សិតនិងបាក់តេរីជាអ្នកស៊ីចុងក្រោយបង្អស់នៅក្នុងខ្សែអាហារនិងបណ្តាញអាហារ ដោយវាធ្វើឱ្យសាកសពនៃសារពាង្គកាយរលួយ ។

## មេរៀនសង្ខេប

- សារពាង្គកាយនីមួយៗមិនអាចរស់នៅតែឯងបានទេ ត្រូវតែមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមកតាមវិធីច្រើនបែបដូចជាសហប្រាណ ការប្រកួតប្រជែង ការចាប់រំពា ... ។
- ទំនាក់ទំនងរវាងសត្វរំពា និងរំពាហៅថាការចាប់រំពា ។
- ទំនាក់ទំនងរវាងសារពាង្គកាយដែលប្រយុទ្ធគ្នាដើម្បីតម្រូវការធនធានដូចជាពន្លឺ អាហារ ទឹក ដី ចាំបាច់ក្នុងការរស់នៅ ហៅថាការប្រកួតប្រជែង ។
- ខ្សែអាហារមួយជាទំនាក់ទំនងផ្នែកអាហាររវាងសារពាង្គកាយនៅក្នុងស្ថានប្រព័ន្ធ ហើយខ្សែអាហារក៏ជាស៊េរីមួយនៃសារពាង្គកាយដែលតាមរយៈនោះថាមពលត្រូវផ្ទេរក្រោមរូបភាពជាអាហារ ។

## ? សំណួរ

1. តើទំនាក់ទំនងរវាងសត្វខ្លានិងទន្សាយដែលរស់នៅក្នុងព្រៃជាទំនាក់ទំនងអ្វី ?
2. តើស្មៅនិងសត្វខ្លាដែលរស់នៅក្នុងព្រៃមានទំនាក់ទំនងអ្វីរវាងគ្នា ?
3. តើសារពាង្គកាយពីរប្រភេទខុសគ្នា ដណ្តើមអាហារ ជំរក និងលក្ខខណ្ឌសម្រាប់រស់ គឺជាលក្ខណៈពិសេសរបស់ទំនាក់ទំនងអ្វី ?
4. សារពាង្គកាយប្រាំប្រភេទខុសគ្នា ពស់ថ្លាន់ ស្មៅ កណ្តុប មាន់ព្រៃ និងមីក្រូសារពាង្គកាយ ។ ចូរគូសគំនូរបំព្រួញពីទំនាក់ទំនងអាហាររវាងសារពាង្គកាយទាំងនោះ ។ តើទំនាក់ទំនងអាហាររវាងសារពាង្គកាយទាំងប្រាំនេះហៅថាអ្វី ?
5. ក្នុងខ្សែអាហារមួយបានបង្ហាញសារពាង្គកាយដែលស្ថិតនៅក្នុងច្រវាក់ដំបូងជារុក្ខជាតិ តើសារពាង្គកាយនៅច្រវាក់បន្ទាប់ជាអ្វី ?

## ? សំណួរបញ្ចប់ជំពូកទី២

**I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវ**

1. កត្តាមានជីវិត និងកត្តាគ្មានជីវិតដែលស្ថិតនៅជុំវិញសារពាង្គកាយមួយ បង្កើតបានជា

☐ក. បរិស្ថាន ☐ខ. ពពួក ☐គ. លំនៅឋាន ☐ឃ. ខ្សែអាហារ ។

2. ប្រភេទរុក្ខជាតិនៅក្នុងប្លុមមួយកំណត់ដោយ

☐ក. សត្វ ☐ខ. រុក្ខជាតិដទៃទៀត ☐គ. អាកាសធាតុ ☐ឃ. រុក្ខជាតិនិងសត្វ ។

3. បណ្ដាញអាហារគឺជា

☐ក. ខ្សែអាហារមួយចំនួនដែលមានទំនាក់ទំនងគ្នា

☐ខ. សារពាង្គកាយច្រើនប្រភេទមានទំនាក់ទំនងផ្នែកអាហារជាមួយគ្នា

☐គ. ខ្សែអាហារជាច្រើនដែលមានច្រវាក់អាហាររួមច្រើន

☐ឃ. ខ្សែអាហារចំនួនពីរយ៉ាងតិច ។

**II. ចូរបំពេញចន្លោះនៅក្នុងលំដាប់នៃខ្សែដូចខាងក្រោម**

1. ......... ⟶ ស្មៅ ......... ⟶ មនុស្ស ។
2. សារាយ ⟶ ខ្យង ⟶ ......... ⟶ មនុស្ស ។
3. .........ក្ដាម ⟶ ......... ⟶ ......... ⟶ ......... ។
4. ......... ⟶ ដង្កូវ ⟶ បក្សី ។

**III. សំណួរ**

1. តើសារពាង្គកាយណាដែលស្ថិតនៅក្នុងច្រវាក់រួមរបស់បណ្ដាញអាហារដែលមានគំនូសបំព្រួញខាងក្រោមនេះ ?

ស្ពៃ ⟶ ដង្កូវមេអំបៅ ⟶ បក្សីស៊ីដង្កូវ ⟶ បក្សីស៊ីសត្វ ⟶ មីក្រូសារពាង្គកាយ
ស្មៅ ⟶ កណ្ដូប ⟶ (បក្សីស៊ីដង្កូវ)

2. តើជាទូទៅសារពាង្គកាយណាដែលស្ថិតនៅក្នុងច្រវាក់ក្រោយបង្អស់របស់ខ្សែអាហារ ?
3. តើហេតុអ្វីបានជាគេចែកសមុទ្រជាតំបន់ ?
4. ចូរពន្យល់ពាក្យតំបន់ដីសើម ។ រកឧទាហរណ៍ ។
5. នៅក្នុងកសិដ្ឋានមួយ កសិករប្រើថ្នាំសម្លាប់សត្វល្អិតដេដេតេ ។ ដេដេតេជាថ្នាំមានសញ្ញាក្បាលខ្មោចដើម្បីសម្លាប់សត្វល្អិតចង្រៃដែលបំផ្លាញដំណាំរបស់គាត់ ។ ដោយសារថ្នាំនេះសត្វល្អិតជាច្រើនងាប់ ក្រោយមកបក្សីជាច្រើនក៏ងាប់ ។ ហេតុអ្វីបានជាបក្សីក៏ងាប់ដែរ ?

# ជំពូកទី 3 ដំណើរនាំក្នុងរុក្ខជាតិ




រុក្ខជាតិបៃតងជាភាវៈរស់មួយមានលក្ខណៈខុសពីភាវៈរស់ដទៃទៀត ព្រោះវាអាចផលិតអាហារបានដោយខ្លួនឯង គឺជាអាហារដែលភាវៈរស់ផ្សេងទៀតពុំអាចផលិតបាន។ រូបធាតុដែលរុក្ខជាតិបៃតងត្រូវការចាំបាច់ក្នុងការផលិតអាហារមាននៅមជ្ឈដ្ឋានក្រៅសារពាង្គកាយរបស់វា។ តើវាត្រូវធ្វើយ៉ាងដូចម្តេច ដើម្បីយកសារធាតុទាំងនោះមកផលិតអាហាររបស់វា ? នៅពេលផលិតអាហារបាន តើវាត្រូវធ្វើយ៉ាងដូចម្តេច ដើម្បីឱ្យអាហារទាំងនេះបានទៅដល់គ្រប់ផ្នែកផ្សេងៗទៀតរបស់វា ?

មេរៀនទី

# 1 បន្សាយ

**ចប់មេរៀននេះ សិស្សអាច**

- ពន្យល់ពីបន្សាយ ព្រមទាំងអាចរកឧទាហរណ៍
- ពណ៌នាពីបន្សាយអាចឆ្លងកាត់តាមរយៈភ្នាស
- ពណ៌នាពីបន្សាយចំពោះកោសិការុក្ខជាតិ
- ពន្យល់ពីភ្នាសកោសិកាជាភ្នាសអឌ្ឍជ្រាប
- ពន្យល់ពីអូស្មូស ទួសេសង់ ប្លាស្មូលីស ដេប្លាស្មូលីស
- ប្រៀបធៀបបន្សាយ និងអូស្មូស ។

ទឹក គឺជាសារធាតុរំលាយសំខាន់មួយសម្រាប់ដំណើរជីវិតរបស់រុក្ខជាតិ ។ មុននឹងរោមជញ្ជក់ស្រូបចូលទៅក្នុងរុក្ខជាតិ អំបិលខនិជដែលជាអាហារសំខាន់សម្រាប់រុក្ខជាតិមានភាពជាសូលុយស្យុង ។ តើរោមជញ្ជក់ស្រូបអាហារទាំងនេះ ដែលមាននៅក្នុងដីតាមរបៀបណា ?

អាហារត្រូវបានស្រូបទៅក្នុងសារពាង្គកាយរបស់រុក្ខជាតិតាម *បន្សាយ* ។

## 1. តើបន្សាយជាអ្វី ?

កាលណាគេចាក់ម្សៅកាហ្វេទៅក្នុងកែវទឹក មួយរយៈក្រោយមកយើងសង្កេតឃើញទឹកក្នុងកែវកាហ្វេប្តូរជាពណ៌កាហ្វេទាំងអស់ ។ ម៉ូលេគុលម្សៅកាហ្វេសាយពេញក្នុងកែវទាំងអស់ ។




*បន្សាយនៃម្សៅកាហ្វេ*

ឧទាហរណ៍នីមួយៗខាងលើនេះបង្ហាញថា ម៉ូលេគុលនៃសារធាតុមួយមានចលនានិងបែងចែកស្មើៗគ្នាទៅគ្រប់កន្លែងជាខ្សែត្រង់ទៅគ្រប់ទិស ។ កាលណាម៉ូលេគុលបែងចែកស្មើៗគ្នាទៅគ្រប់ទីកន្លែង ហើយពុំមានបម្រែបម្រួលកំហាប់ទៀតនោះ មានន័យថា ម៉ូលេគុលឈប់ធ្វើចលនា ។ យើងឃើញថាម៉ូលេគុលនៃសារធាតុនេះមានដំណើរពីតំបន់ដែលមានកំហាប់ខ្ពស់ទៅតំបន់ដែលមានកំហាប់ទាប ។

ដូចនេះបន្សាយ គឺជាចលនារបស់ម៉ូលេគុលពីតំបន់ដែលមានកំហាប់ខ្ពស់ទៅតំបន់កំហាប់ទាប ។

## ក. បន្សាយតាមរយៈភ្នាស




*បន្សាយតាមរយៈភ្នាស*

ទុកពិសោធន៍ដូចរូបខាងលើនៅស្ងៀម ។ មួយរយៈក្រោយមក ទឹកបានសាយពីកែវទៅក្នុងថង់កំណាត់បណ្ដាលឱ្យគ្រាប់ពែម៉ង់កាណាតរលាយ ហើយបង្កើតជាសូលុយស្យុង (រូប ក) ។ សូលុយស្យុងនេះ ក៏សាយចេញពីថង់កំណាត់ទៅក្នុងកែវ ធ្វើឱ្យទឹកក្នុងកែវប្ដូរទៅជាពណ៌ស្វាយ (រូប ខ គ ឃ) ។ ថង់កំណាត់មាននាទីដូចជាភ្នាសមួយ ។ ភ្នាសនេះហៅថា ភ្នាសជ្រាប ។ វាមានរន្ធតូចៗជាច្រើនដែលឱ្យម៉ូលេគុលតូចៗសាយចេញតាមនោះ ។ ដូចនេះបន្សាយក៏អាចឆ្លងតាមរយៈភ្នាសដែរ ។

## ខ. បន្សាយចំពោះកោសិការុក្ខជាតិ




*បន្សាយចំពោះកោសិការុក្ខជាតិ*

ចំពោះរុក្ខជាតិ ឧស្ម័នកាបូនិច $CO_2$ ជាវត្ថុធាតុដើមសម្រាប់ដំណើររស្មីសំយោគ ហើយឧស្ម័នអុកស៊ីសែន $O_2$ គឺជាផលិតផលចុងក្រោយដែលត្រូវបញ្ចេញចោល ។ ដូចនេះបណ្តូរឧស្ម័នចំពោះរុក្ខជាតិ គឺការស្រូបយកឧស្ម័នកាបូនិចនិងការបញ្ចេញឧស្ម័នអុកស៊ីសែនទៅក្រៅ ។ បណ្តូរនេះកើតឡើងបានតែនៅក្នុងសរីរាង្គដែលធ្វើរស្មីសំយោគនៅពេលដែលមានពន្លឺប៉ុណ្ណោះ ។

ដូចនេះនៅពេលដែលរុក្ខជាតិប្រើប្រាស់ឧស្ម័នកាបូនិចសម្រាប់ធ្វើរស្មីសំយោគ កំហាប់ឧស្ម័នកាបូនិចក្នុងបរិយាកាសខ្ពស់ជាងកំហាប់ឧស្ម័នកាបូនិចក្នុងកោសិកា ។ ភាពខុសគ្នានៃកំហាប់ធ្វើឱ្យឧស្ម័នកាបូនិចនៃបរិយាកាសចូលទៅក្នុងកោសិកា ។ ដោយសារកោសិកាផលិតអុកស៊ីសែននៅពេលធ្វើរស្មីសំយោគ បណ្តាលឱ្យកំហាប់អុកស៊ីសែនក្នុងកោសិកាកើនឡើង ឯកំហាប់នៅក្រៅកោសិកានៅដដែល ។ ភាពខុសគ្នានៃកំហាប់នេះធ្វើឱ្យអុកស៊ីសែនភាយចេញពីកោសិការុក្ខជាតិទៅក្នុងបរិយាកាស ។

## 2. អូស្មូស




*ការបង្ហាញពីដំណើរអូស្មូសដោយប្រើបំពង់ទឹកស្ករ*

បំពង់ទឹកស្ករអាចប្រើជាភ្នាសកោសិកាអឌ្ឍជ្រាបបាន ។ យកបំពង់ទឹកស្ករមានផ្ទុកសូលុយស្យុងស្ករខាប់ទៅត្រាំក្នុងទឹក (រូប ក) ។ ប្រហែល 30 នាទីក្រោយមកយើងឃើញនីវ៉ូសូលុយស្យុងស្ករក្នុងកូនបំពង់កើនឡើង ។ ហេតុអ្វី ?

យើងដឹងហើយថា ទោះបីនៅក្នុងបំពង់មានផ្ទុកសូលុយស្យុងស្ករខាប់ក៏ដោយ ម៉ូលេគុលស្ករមិនអាចសាយចេញដោយឆ្លងកាត់បំពង់នេះបានទេ ព្រោះបំពង់ទឹកស្ករមានរន្ធតូចៗដែលអាចឱ្យតែម៉ូលេគុលទឹកឆ្លងកាត់ប៉ុណ្ណោះ ។ ចំណែកម៉ូលេគុលទឹកក៏សាយពីកែវទៅក្នុងបំពង់ទឹកស្ករ ដែលធ្វើឱ្យនីវ៉ូសូលុយស្យុងស្ករកើនឡើង (រូប ខ) ។



*ទឹកចូលទៅក្នុងបំពង់ទឹកស្ករតាមអូស្មូស*

ដូចនេះអូស្មូស គឺជាបន្សាយនៃម៉ូលេគុលឆ្លងកាត់តាមភ្នាសអន្តរជ្រាបមួយ ។ ភ្នាសអន្តរជ្រាបអាចឱ្យឆ្លងកាត់តែសារធាតុខ្លះប៉ុណ្ណោះ ។ *ឧទាហរណ៍* ភ្នាសកោសិកា (រូបគ)

## 3. បណ្តូរទឹកក្នុងកោសិកា

រុក្ខជាតិមានសភាពធម្មតានៅក្នុងមជ្ឈដ្ឋានដែលមានម៉ូលេគុលសារធាតុតិច (កំហាប់ទាប) ។ ផ្ទុយទៅវិញ នៅក្នុងមជ្ឈដ្ឋានដែលមានម៉ូលេគុលសារធាតុច្រើន (កំហាប់ខ្ពស់) រុក្ខជាតិនោះស្រពោន ឬអាចងាប់ទៅបាន ។ ហេតុអ្វីបានជាភាពខុសគ្នានៃកំហាប់បណ្តាលឱ្យរុក្ខជាតិងាប់បាន ?

### ក. ទួរសេសង់

នៅពេលដែលវ៉ាគុលអូលរបស់កោសិការុក្ខជាតិផ្ទុករុក្ខរសពេញ គេហៅថា**ទួរសេសង់** ។ ទួរសេសង់ជាសភាពរបស់កោសិការស់ ។ (រូប ក)

### ខ. ប្លាស្មូលីស

គេយកការ៉ុតដែលកាត់ជាដុំៗដាក់នៅក្នុងថានមួយដែលមានសូលុយស្យុងកំហាប់អំបិលខ្ពស់ ។ មួយម៉ោងក្រោយមក យើងពិនិត្យឃើញដុំការ៉ុតឡើងស្វិតហើយរួមតូច ព្រោះកំហាប់រុក្ខរសក្នុងកោសិកាទាបជាងបណ្តាលឱ្យទឹកចេញពីកោសិកាការ៉ុតតាមអូស្មូស ពេលនោះគេហៅថា កោសិកាប្លាស្មូលីស (រូប ខ) ។



*បាតុភូតទឹកចេញពីកោសិកា*

## គ. ដេប្លាស្មូលីស




ប្រសិនបើគេយកដុំការ៉ុតស្វិត រួមតូចខាងលើនេះទៅដាក់ក្នុងចានទឹកវិញ ។ មួយម៉ោងក្រោយមក គេពិនិត្យឃើញដុំការ៉ុតបានជក់ទឹក ហើយរឹងដូចដើមវិញ ព្រោះកំហាប់ទឹកក្នុងចានខ្ពស់ជាងកំហាប់ទឹកក្នុងកោសិកាការ៉ុត បណ្តាលឱ្យទឹកក្នុងចានចូលទៅក្នុងកោសិកាការ៉ុតតាមអូស្មូស ។ ពេលនេះគេហៅថា កោសិកាដេប្លាស្មូលីស (រូបគ) ។

ដូចនេះអូស្មូស គឺជាចលនានៃម៉ូលេគុលទឹកពីតំបន់ដែលមានកំហាប់ទឹកខ្ពស់ទៅកាន់តំបន់ដែលមានកំហាប់ទឹកទាប ។

## មេរៀនសង្ខេប

- បន្សាយ គឺជាចលនានៃម៉ូលេគុលពីតំបន់ដែលមានកំហាប់ខ្ពស់ទៅកាន់តំបន់ដែលមានកំហាប់ទាប ។
- សារធាតុភាគច្រើនធ្វើចលនាចេញ និងចូលក្នុងកោសិកាតាមបន្សាយ ។
- អូស្មូស គឺជាចលនានៃម៉ូលេគុលទឹកពីតំបន់ដែលមានកំហាប់ទឹកខ្ពស់ ទៅកាន់តំបន់ដែលមានកំហាប់ទឹកទាបតាមរយៈភ្នាសអន្តរជ្រាប ។ ភ្នាសអន្តរជ្រាបអនុញ្ញាតឱ្យសារធាតុខ្លះឆ្លងកាត់ ប៉ុន្តែវាមិនអនុញ្ញាតឱ្យសារធាតុផ្សេងឆ្លងកាត់ទេ ។
- បណ្តូរឧស្ម័នចំពោះរុក្ខជាតិបៃតងត្រូវពន្លឺ គឺការស្រូបយកឧស្ម័នកាបូនិច $CO_2$ ពីបរិយាកាសនិងការបញ្ចេញឧស្ម័នអុកស៊ីសែន $O_2$ ទៅបរិយាកាសវិញ ។
- ទឹកធ្វើចលនាចេញពីកោសិកាតាមអូស្មូស ពេលនោះហៅថា កោសិកាប្លាស្មូលីស ។
- ទឹកធ្វើចលនាចូលក្នុងកោសិកាវិញតាមអូស្មូស ពេលនោះហៅថា កោសិកាដេប្លាស្មូលីស ។
- កោសិកាទួរសេសង់ជាកោសិកាដែលវ៉ាគុយអូលរបស់វាផ្ទុកពេញទៅដោយរុក្ខរស ។ ទួរសេសង់ជាសភាពរបស់កោសិការស់ ។

## សំណួរ

1. ដូចម្តេចហៅថាបន្សាយ ?
2. ចូររកឧទាហរណ៍ពីបន្សាយដែលមានជុំវិញប្អូន ។
3. ដូចម្តេចហៅថាភ្នាសអន្តរជ្រាប ?
4. ដូចម្តេចហៅថាអូស្មូស ?
5. តើក្នុងដំណើរឧស្ម័នចំពោះរុក្ខជាតិបៃតងត្រូវពន្លឺ គឺអាចត្រូវនឹងការបញ្ចេញនូវឧស្ម័នអ្វី ?
6. ចំពោះសារធាតុអុកស៊ីសែន និងឧស្ម័នកាបូនិចនៅពេលដែលធ្វើរស្មីសំយោគ តើសារធាតុណាសាយចេញ ហើយសារធាតុណាសាយចូលក្នុងកោសិការុក្ខជាតិ ? ហេតុអ្វី ?
7. តើបន្សាយខុសពីអូស្មូសដូចម្តេចខ្លះ ?

មេរៀនទី

# 2 ដំណឹកនាំក្នុងរុក្ខជាតិមានសរសៃនាំ

**ចប់មេរៀននេះ សិស្សអាច**

- ❑ ពន្យល់ពាក្យដំណឹកនាំ
- ❑ រៀបរាប់ពីប្រព័ន្ធដឹកនាំរបស់រុក្ខជាតិមានសរសៃនាំ
- ❑ ពណ៌នាពីដំណឹកនាំរបស់រុក្ខជាតិគ្មានសរសៃនាំ
- ❑ ពណ៌នាពីដំណឹកនាំរបស់រុក្ខជាតិមានសរសៃនាំ
- ❑ បង្ហាញពីបាតុភូតសំរូបទឹក និងអំបិលខនិជរបស់រុក្ខជាតិមានសរសៃនាំ
- ❑ ពន្យល់ពីតម្រូវការរំភាយចំហាយទឹករបស់រុក្ខជាតិមានសរសៃនាំ
- ❑ ពណ៌នាពីដំណឹកនាំអាហារដែលរុក្ខជាតិផលិតបាន
- ❑ បង្ហាញពីផលប្រយោជន៍នៃបាតុភូតរំភាយចំហាយទឹក ។

កោសិកាទាំងអស់ត្រូវការសារធាតុដែលបានពីបរិស្ថាន ដើម្បីនាំយកទៅប្រើការក្នុងដំណើរជីវិតរបស់វា ។ សារធាតុទាំងនេះត្រូវផ្លាស់ទីឆ្លងកាត់ភ្នាសកោសិកា ។ ពេលនៅក្នុងកោសិកា សារធាតុទាំងនេះ ត្រូវផ្លាស់ទីទៅកន្លែងណាដែលត្រូវការវា ឬស្តុកទុកក្នុងកោសិកា ។ ការបំលាស់ទីនៃសារធាតុហៅថាដំណឹកនាំ ។ ដូចនេះដំណឹកនាំជាដំណើរមួយដែលកើតឡើងដោយបំលាស់ទីនៃសារធាតុជាច្រើនចូលទៅក្នុង ឬក្រៅកោសិកា ឬចែកចាយក្នុងកោសិកា ។

## 1. ដំណឹកនាំក្នុងរុក្ខជាតិគ្មានសរសៃនាំ






រុក្ខជាតិគ្មានសរសៃនាំគ្មានជាលិកាដឹកនាំ និងបណ្ដូរឧស្ម័នទេ ។ កោសិកានីមួយៗរបស់វាបំពេញមុខងារដាច់ដោយឡែកពីគ្នា និងស្ថិតនៅជិតស្និតជាមួយមជ្ឈដ្ឋានខាងក្រៅ ។ ទឹក សារធាតុខនិជ និងឧស្ម័នកាបូនិចចូលទៅក្នុងកោសិការបស់រុក្ខជាតិដោយផ្ទាល់ ។ កោសិកាភាគច្រើនផលិតអាហារតាមរស្មីសំយោគ ។ ដូចនេះដំណឹកនាំអាហារទៅក្នុងកោសិកាប្រព្រឹត្តតាមបន្សាយ ។

***ឧទាហរណ៍ :*** សារាយ ។

ចំពោះស្លែព្រៃដែលជារុក្ខជាតិបៃតងតូចៗដុះនៅលើដី ហើយគ្មានជាលិកានាំទេ មានតែរីសូអ៊ីត (ស្ថិតនៅផ្នែកគល់នៃដើមរបស់ស្លែព្រៃ) ស្រូបយកទឹក និងអំបិលខនិជ ហើយត្រូវដឹកនាំទៅផ្នែកផ្សេងៗទៀតតាមអូស្មូស ។ អាហារដែលផលិតបានធ្វើដំណើរពីកោសិកាដែលធ្វើរស្មីសំយោគទៅកោសិកាទាំងអស់តាមបន្សាយ ។

## 2. ដំណឹកនាំក្នុងរុក្ខជាតិមានសរសៃនាំ

ចំពោះសារពាង្គកាយសាំញ៉ាំដូចជារុក្ខជាតិមានសរសៃនាំ កោសិកាដែលនៅជ្រៅក្នុងសារពាង្គកាយ វាស្ថិតនៅឆ្ងាយពីផ្ទៃខាងក្រៅនៃសារពាង្គកាយ ។ បន្សាយជាលំនាំយ៉ាងយឺតដែលមិនអាចដឹកនាំសារធាតុផ្សេងៗឆ្លងកាត់ទីឆ្ងាយៗបានទេ ។ ដូចនេះវាត្រូវការប្រព័ន្ធពិសេសមួយហៅថា ប្រព័ន្ធដំណឹកនាំ សម្រាប់ផ្លាស់ទីសារធាតុទាំងឡាយនៅក្នុងរុក្ខជាតិ ។

### 2.1. ប្រព័ន្ធដឹកនាំរបស់រុក្ខជាតិមានសរសៃនាំ



*ផ្នាតទទឹងរបស់ដងដើមរុក្ខជាតិមានសរសៃនាំបង្ហាញពីបាច់សរសៃនាំ*

ប្រព័ន្ធដឹកនាំរបស់រុក្ខជាតិមានសរសៃនាំមានបំពង់តូចៗជាច្រើននៅក្នុងឫស ដើម និងស្លឹក ។ បំពង់នេះមានពីរបែប **គឺស៊ីឡែមនិងផ្លូអែម** ។

- **ស៊ីឡែម**ដឹកនាំទឹក និងអំបិលរ៉ែនិជរលាយពីឫសទៅស្លឹក ។
- **ផ្លូអែម**ដឹកនាំអាហាររលាយដែលជាផលនៃរស្មីសំយោគក្រោមរូបរាងជាស្ករពីស្លឹកទៅឱ្យគ្រប់ផ្នែកទាំងអស់នៃរុក្ខជាតិ ដើម្បីចិញ្ចឹមផ្នែកទាំងនោះ ។

ប្រព័ន្ធដឹកនាំរបស់រុក្ខជាតិតែងតែស្ថិតនៅជុំគ្នាជាបាច់សរសៃនាំ ។

## 2.2. សម្រូបទឹក និងអំបិលរ៉ែនិជក្នុងរុក្ខជាតិមានសរសៃនាំ

### ក. សម្រូបទឹក




*គំនូសបំព្រួញកោសិកាឫសដែលបង្ហាញពីសំរូបទឹកដោយឫស*

រុក្ខជាតិមានសរសៃនាំភាគច្រើនស្រូបយកទឹកពីដីតាមរយៈឫស ។ ទឹកក្នុងដីមានកំហាប់ទឹកខ្ពស់ (សូលុយស្យុងក្នុងដី) វាអាចធ្វើដំណើរចូលទៅក្នុងរោមជញ្ជក់តាមអូស្មូស ។ រោមជញ្ជក់ឆ្មារៗរាប់លានបង្កើតបានជាផ្ទៃមួយដ៏ធំសម្រាប់សម្រូបទឹក ។ ទឹកចូលទៅក្នុងរោមជញ្ជក់ធ្វើឱ្យម៉ូលេគុលទឹកនៅទីនោះខ្ពស់ជាងនៅក្នុងកោសិកាឫស ។ នៅខាងក្នុងឫស ទឹកធ្វើដំណើរពីកោសិកាមួយទៅកោសិកាមួយ ដោយអូស្មូសរហូតទៅដល់ស៊ីឡែមរួចនាំទៅដល់ស្លឹក ។ មកដល់ស្លឹកក៏មានបំភាយចំហាយទឹក ។ ទឹកមួយចំនួនអាចចូលទៅក្នុងឫសដោយមិនបាច់ឆ្លងកាត់កោសិកាតាមអូស្មូសទេ ។ ប៉ុន្តែវាអាចឆ្លងកាត់ចន្លោះកោសិកាឫសរហូតដល់ស៊ីឡែម ។

## ខ. ស្រូបអំបិលខនិជ

រោមជញ្ជក់ស្រូបអំបិលខនិជរលាយក្នុងទឹកដែលនៅក្នុងដី ប៉ុន្តែអំបិលខនិជមិនស្រូបទៅក្នុងរោមជញ្ជក់ដូចទឹកទេ ។ រុក្ខជាតិស្រូបយកអំបិលខនិជដោយប្រើប្រាស់ថាមពលដែលបានមកពីដង្ហើម ។ ដំណឹកនាំនេះហៅថា ដំណឹកនាំសកម្ម ។ ក្នុងរោមជញ្ជក់ អំបិលខនិជធ្វើដំណើរពីកោសិកាមួយទៅកោសិកាមួយដោយបន្សាយរហូតដល់បំពង់ស៊ីឡែម ។ អំបិលខនិជមួយចំនួនត្រូវប្រើប្រាស់ និងស្តុកទុកក្នុងឫសហើយមួយចំនួនទៀតត្រូវដឹកនាំតាមស៊ីឡែមពីឫសរហូតដល់ដើម និងស្លឹក ។ ព្រមជាមួយគ្នានេះទឹក និងអំបិលខនិជរលាយក៏ត្រូវដឹកនាំទៅកាន់ដើម និងស្លឹកតាមបំពង់ស៊ីឡែមនេះដែរ ។

## គ. រំភាយចំហាយទឹក

ទឹកដែលឫសស្រូបបានមកហូរចូលទៅក្នុងដើម និងមែកតាមស៊ីឡែម រួចទៅដល់ស្លឹក ។ មកដល់ស្លឹកក៏មានរំភាយចំហាយទឹក ។ ទឹកភាយចេញតាមរន្ធតូចៗនៃស្លឹកដែលហៅថា **ស្តូម៉ាត** ។ តាមធម្មតាផ្ទៃក្រោមស្លឹកមានស្តូម៉ាតច្រើនជាងផ្ទៃលើស្លឹក ។ បរិមាណទឹកដែលភាយចេញតាមស្តូម៉ាតត្រូវបាត់បង់ ។ បាតុភូតបាត់បង់ទឹកតាមស្តូម៉ាតហៅថា **រំភាយចំហាយទឹក** ។ រំភាយចំហាយទឹកពីស្លឹកបង្កើតបានជាកម្លាំងស្រូបនៃរុក្ខជាតិ ។ នៅពេលដែលទឹកភាយចេញពីស្លឹក ទឹកផ្សេងទៀតក៏ស្រូបតាមស៊ីឡែមទៅស្លឹកដើម្បីជំនួសកន្លែងដែលបាត់បង់ ។ កម្លាំងស្រូបជាកម្លាំងសំខាន់ដែលធ្វើឱ្យទឹកឡើងពីឫសមកស្លឹក ។ ការបាត់បង់បរិមាណទឹកដោយរំភាយចំហាយទឹកមានសារប្រយោជន៍សម្រាប់ដំណឹកនាំទឹកពីឫស ។




ទឹកដែលឫស (1) ស្រូបបានហូរចូលទៅក្នុងដើម (2) និងមែកតាមស៊ីឡែម រួចទៅដល់ស្លឹក (3) ទឹកក៏ភាយតាមស្តូម៉ាត




*ទឹកភាយចេញតាមស្តូម៉ាត*



*ស្តូម៉ាត*

*បាតុភូតរំភាយទឹកតាមស្តូម៉ាត*

### ឃ. ដំណើកនាំអាហារ

ក្នុងដំណើររស្មីសំយោគ រុក្ខជាតិប្រើប្រាស់ក្លរ៉ូភីល ដែលជាជាតិពណ៌បៃតងនៅក្នុងស្លឹកសម្រាប់ស្រូបយកថាមពលព្រះអាទិត្យ ។ បន្ទាប់មកថាមពលនេះត្រូវប្រើប្រាស់ជួយដល់ការភ្ជាប់ឧស្ម័នកាបូនិចនៃបរិយាកាស ដែលចូលផ្សំក្នុងស្លឹកជាមួយទឹកក្នុងដីដែលស្រូបយកដោយឫស ដើម្បីផលិតអាហារក្រោមរូបរាងជាស្ករ គឺគ្លុយកូសនិងអុកស៊ីសែន ។

អាហារក្រោមរូបរាងជាស្ករដែលជាផលនៃរស្មីសំយោគត្រូវដឹកនាំដោយផ្លូវអែម ។ ពេលដែលអាហារត្រូវបង្កើតនៅក្នុងស្លឹក វារលាយនៅក្នុងទឹក ។ អាហាររលាយចូលទៅក្នុងកោសិកាផ្លូវអែមទ្រនុងស្លឹក ។ អាហារត្រូវដឹកនាំទៅគ្រប់ទីកន្លែងនៃដើមរុក្ខជាតិ ។ តាមធម្មតាអាហារធ្វើដំណើរចុះក្រោមតាមផ្លូវអែមនៃដើម ចូលទៅក្នុងឫស រួចចូលទៅក្នុងសំបក ។ នៅក្នុងសំបក ស្ករត្រូវផ្លែងជាអាមីដុង ហើយស្តុកទុកនៅទីនោះ ។

**មេរៀនសង្ខេប**

- ដំនឹកនាំជាដំណើរមួយដែលកើតឡើងដោយបំលាស់ទីនៃសារធាតុជាច្រើនចូលទៅក្នុង ឬចេញទៅក្រៅកោសិកា ។
- រុក្ខជាតិគ្មានសរសៃនាំគ្មានប្រព័ន្ធដឹកនាំ និងបណ្តូរឧស្ម័នទេ ។ ទឹក សារធាតុខនិជ និង ឧស្ម័នចូលទៅក្នុងកោសិកានីមួយៗដោយផ្ទាល់តាមអូស្មូស ។
- ប្រព័ន្ធដឹកនាំរុក្ខជាតិមានសរសៃនាំកើតឡើងដោយបំពង់ពីរប្រភេទ គឺស៊ីឡែមនិងផ្លូវអែម ។
  - ស៊ីឡែមដឹកនាំទឹក និងអំបិលខនិជរលាយពីឫសទៅស្លឹក ។
  - ផ្លូវអែមដឹកនាំស្ករពីស្លឹកទៅផ្នែកដទៃទៀតនៃរុក្ខជាតិ ។
- ទឹកធ្វើដំណើរក្នុងរុក្ខជាតិមានសរសៃនាំតាមដំណាក់ផ្សេងៗដូចតទៅ
  - វាចូលទៅក្នុងរុក្ខជាតិដោយអូស្មូសតាមរោមជញ្ជក់ ។
  - វាឆ្លងកាត់ពីកោសិកាមួយទៅកោសិកាមួយក្នុងឫសដោយអូស្មូស ។
  - វាត្រូវដឹកនាំពីឫសទៅគ្រប់ផ្នែកទាំងអស់នៃរុក្ខជាតិតាមស៊ីឡែមដោយកម្លាំងស្រូប ។
  - វាធ្វើចលនានៅក្នុងឫស ទៅដើមរហូតដល់ស្លឹកតាមស៊ីឡែម ។ ទឹកមួយចំនួនត្រូវប្រើប្រាស់ដោយស្លឹកក្នុងដំណើររស្មីសំយោគ ។ ប៉ុន្តែទឹកភាគច្រើនត្រូវបានភាយចេញពីស្លឹកហៅថារំភាយចំហាយទឹក ។ រំភាយចំហាយទឹកជាបាតុភូតដែលទឹកចេញពីស្លឹកតាមស្តូម៉ាត ។
- ស្ករដែលផលិតនៅក្នុងស្លឹកដោយរស្មីសំយោគត្រូវដឹកឡើងនិងចុះតាមផ្លូវអែម ។

វេជ្ជបណ្ឌិតបានប្រើប្រាស់វេធ្លិចនៃការកន្ត្រាក់ជង្គង់និងវេធ្លិចប្តូរទំហំរន្ធប្រស្រីភ្នែកក្នុងតំណប ទៅនឹងពន្លឺ ដើម្បីត្រួតពិនិត្យលក្ខខណ្ឌនៃប្រព័ន្ធប្រសាទ ។ ប្រសិនបើគ្មានតំណបទៅនឹងវេធ្លិចឬតំណប យឺតបង្ហាញថាប្រព័ន្ធប្រសាទមានភាពមិនប្រក្រតី ។

## 3. សារធាតុញៀននិងប្រព័ន្ធប្រសាទ


រូបទី 3.6 : មនុស្សញៀនស្រា

សារធាតុញៀនមួយចំនួន មានគ្រោះថ្នាក់ខ្លាំងចំពោះសុខភាព ពីព្រោះវាមានឥទ្ធិពលភ្លាមៗទៅលើប្រព័ន្ធប្រសាទ ។ នីកូទីនជាសារធាតុញៀននៅក្នុងថ្នាំជក់ ។ វាបង្កើនអត្រាចង្វាក់បេះដូង សម្ពាធឈាម អត្រាដង្ហើម ធ្វើឱ្យបញ្ញាធ្លាក់ចុះដូចជាមិនសូវមានការចងចាំ មិនហ៊ានធ្វើការសម្រេចចិត្ត ឬការវិនិច្ឆ័យមានការយឺតយ៉ាវ ខួរក្បាលហាក់ដូចជាស្ពឹកស្រពន់ ។

អាល់កុលជាសារធាតុញៀននៅក្នុងស្រា ។ នៅពេលផឹក អាល់កុលជ្រាបចូលដោយផ្ទាល់ទៅក្នុងចរន្តឈាមតាមភ្នាសពោះវៀនតូច ។ ប្រសិនបើផឹកច្រើន អាល់កុលបន្ថយសកម្មភាពនៃមជ្ឈមណ្ឌលប្រសាទ ការវិនិច្ឆ័យ ការពិចារណា និងការប្រមូលអារម្មណ៍ត្រូវថយចុះ ។ ការផឹករយៈពេលយូរអាចប៉ះពាល់ដល់សុខភាពដូចជា បាត់បង់ការចងចាំ វង្វេងវង្វាន់ បាត់បង់លំនឹង និងកើតជំងឺមហារីកនៅលើសរីរាង្គជាច្រើន ។

ភេសជ្ជៈមួយចំនួនមានក្លិនឈ្ងុយឆ្ងាញ់ដូចជាកាហ្វេ តែជាដើម ។ ប្រសិនបើយើងផឹកវាក្នុងបរិមាណតិចតួចគឺ 1 ឬ 2 ពែងក្នុងមួយថ្ងៃ កាហ្វេ និងតែ នឹងភ្ញោចប្រព័ន្ធប្រសាទដោយជួយសម្រួលការគិតផ្នែកបញ្ញា ។ ប៉ុន្តែប្រសិនបើយើងផឹកហួសកំណត់ វានឹងបណ្តាលឱ្យមានវិបត្តិផ្នែកប្រព័ន្ធប្រសាទដូចជាដេកមិនលក់ បង្កើនអត្រាចង្វាក់បេះដូង បណ្តាលឱ្យរសាប់រសល់ ដំណើរញ័រៗ ។ កាហ្វេអ៊ីនជាសារធាតុភ្ញោចប្រព័ន្ធប្រសាទយ៉ាងខ្លាំង ។ សារធាតុនេះមាននៅក្នុងភេសជ្ជៈដូចជា កាហ្វេ តែ កូកាកូឡា ហើយធ្វើឱ្យមានបញ្ហាដល់សុខភាព ។

## 4. ជំងឺប្រព័ន្ធប្រសាទ

ជំងឺគ្រុនស្វិតដៃជើង ជាជំងឺមួយដែលបង្កឡើងដោយវីរុសគ្រុនស្វិតដៃជើង ។ វីរុសនេះមាននៅក្នុងខ្យល់ ជាពិសេសនៅកន្លែងគ្មានអនាម័យ ។ ភាគច្រើន ជំងឺនេះតែងកើតឡើងនៅលើកុមារ ។ មនុស្សអាចឆ្លងជំងឺនេះបានតាមរយៈការប៉ះពាល់គ្នា ។ វីរុសគ្រុនស្វិតដៃជើងចូលទៅក្នុងឈាមតាមអាហារនិងផ្លូវដង្ហើម ហើយទៅបំផ្លាញមជ្ឈមណ្ឌលប្រសាទ ។ នៅទីនោះជាពិសេសនៅក្នុងខួរឆ្អឹងខ្នង វាបំផ្លាញណឺរ៉ូនចលករ ដែលបញ្ជាសាច់ដុំឱ្យធ្វើចលនា ។ ក្រោយពេលបំផ្លាញហើយ ណឺរ៉ូននេះមិន

**II. ចូរបំពេញល្បះខាងក្រោម**

1. ទឹកធ្វើចលនាចេញពីកោសិកាតាមអូស្មូស ពេលនោះគេហៅកោសិកាថា កោសិកា .............. ។
2. កោសិកា .............. ជាកោសិកាដែលវាគុយអូលរបស់វាផ្ទុកពេញទៅដោយរុក្ខរស ។
3. បាតុភូតនៃការបាត់បង់ទឹកតាមស្តូម៉ាតហៅថា ........................ ។
4. .............. គឺជាចលនារបស់ម៉ូលេគុលពីតំបន់ដែលមានកំហាប់ម៉ូលេគុលខ្ពស់ទៅតំបន់ដែលមានកំហាប់ម៉ូលេគុលទាប ។
5. .......... គឺជាចលនានៃម៉ូលេគុលទឹកពីតំបន់ដែលមានកំហាប់ទឹកខ្ពស់ទៅកាន់តំបន់ដែលមានកំហាប់ទឹកទាបតាមរយៈភ្នាសអឌ្ឍជ្រាបមួយ ។

**III. សំណួរ**

1. ហេតុអ្វីបានជាគេចូលចិត្តដាំដើមឈើនៅទីដែលមានពន្លឺគ្រប់គ្រាន់ ?
2. ហេតុអ្វីបានជានៅពេលដែលគេចិញ្ចឹមត្រីក្នុងអាងសម្រាប់តាំងលំអផ្ទះ គេតែងតែដាក់សារាយក្នុងអាងនោះ ?
3. បាតុភូតអ្វីបានជាគេនិយាយថា បើគ្មានរុក្ខជាតិបៃតងនោះ នៅលើផែនដីក៏គ្មានជីវិតដែរ ?
4. តើបាតុភូតរំភាយចំហាយទឹកមានសារប្រយោជន៍អ្វីចំពោះរុក្ខជាតិ ?
5. តើទឹកធ្វើដំណើរក្នុងរុក្ខជាតិមានសរសៃនាំយ៉ាងដូចម្តេច ?

# ជំពូកទី 4 ដង្ហើមនិងដំណឹកនាំ




នៅពេលប្រកួតប្រជែង កីឡាកររត់ប្រណាំងត្រូវការដកដង្ហើមចូលយ៉ាងខ្លាំង ហើយទៀងទាត់ផងដែរ ។ ចង្វាក់បេះដូងរបស់ពួកគេកើនឡើងជាលំដាប់ ។ ពួកគេមានអារម្មណ៍ក្តៅ ហើយបែកញើសច្រើនទៀតផង ។ ការប្រែប្រួលទាំងអស់នេះ ត្រៀមបំរុងផ្តល់ថាមពលចាំបាច់ដល់សកម្មភាពរត់ប្រណាំងនេះ ។

មេរៀនទី

# 1 ប្រដាប់ដង្ហើម

**ចប់មេរៀននេះ សិស្សអាច**

- ប្រាប់ពីនាទីនៃប្រដាប់ដង្ហើម
- គូររូបផ្គុំប្រដាប់ដង្ហើម
- រៀបរាប់ពីផ្នែកនីមួយៗនៃប្រដាប់ដង្ហើម ។

មនុស្សស្រូបយកខ្យល់ពីបរិយាកាសដូចផនិកសត្វដែរ ។ ទោះបីជាធ្វើសកម្មភាពឬសម្រាកក៏ដោយ  សរីរាង្គទាំងអស់នៃសារពាង្គកាយប្រើប្រាស់ឧស្ម័នអុកស៊ីសែន ($O_2$) និងបោះបង់ចោលឧស្ម័នកាបូនឌីអុកស៊ីត ($CO_2$) ។ ដង្ហើមរ៉ាប់រងនូវបណ្តូរឧស្ម័ន ។

## 1. តម្រូវការប្រើប្រាស់ $O_2$

(រូបក)



*កែវចិញ្ចឹមត្រីដោយបញ្ចូល $O_2$*

(រូបខ)



*អ្នកអវកាស*

(រូបគ)



*អ្នកមុជទឹកនៅបាតសមុទ្រ*

(រូបឃ)



*កែវដាក់ចង្រិត*

ខ្យល់ជាឧស្ម័នមិនអាចមើលឃើញ ។ វាជាធាតុបង្កសំខាន់នៃបរិយាកាសដែលព័ទ្ធជុំវិញផែនដី ។ ពពុះខ្យល់នៅក្នុងអាងចិញ្ចឹមត្រី (រូបក) បង្ហាញថា  ត្រីត្រូវការខ្យល់  ដើម្បីដកដង្ហើម ។  ប៉ុន្តែផ្ទុយពីមនុស្សនិងសត្វលើគោក  សត្វក្នុងទឹកអាចប្រើប្រាស់បានតែខ្យល់រលាយក្នុងទឹកប៉ុណ្ណោះ ។  ឧស្ម័នចាំបាច់បំផុតនៅក្នុងខ្យល់ជា $O_2$ ។ ដើម្បីមានជីវិតរស់នៅ មនុស្សក៏ត្រូវការប្រើប្រាស់ $O_2$ នៅក្នុងខ្យល់ដែរ ។ នៅក្នុងអវកាស(រូបខ) គ្មាន $O_2$ ឯនៅក្នុងជម្រៅនៃទឹកសមុទ្រ មានតែ $O_2$ រលាយក្នុងទឹក (រូបគ)ដូចនេះមនុស្សត្រូវប្រើប្រាស់ប្រដាប់ផ្ទុក $O_2$ ដើម្បីដកដង្ហើម ។

ប្រសិនបើគ្មានខ្យល់ទេ ភាវៈរស់ទាំងអស់មាន រុក្ខជាតិ សត្វ និងមនុស្សមិនអាចមានជីវិតរស់នៅបានទេ ។ ដូចនេះខ្យល់មានសារៈសំខាន់សម្រាប់ជីវិត ។ ជីវិតអាចមាននៅលើផែនដីបាន កាលណាមានវត្តមាននៃ $O_2$ ។

កុមារសាននិងកុមារីធីតាបានចាប់សត្វចង្រិតចំនួនបីក្បាល(រូបយ) ដើម្បីយកទៅជូនគ្រូសម្រាប់បង្រៀននៅថ្ងៃស្អែក ។ កុមារទាំងពីរបានដាក់ចង្រិតនៅក្នុងដបមួយបិទជិត ។

ធីតាចង់ចោះរន្ធតូចៗនៅលើឆ្នុកដបនោះ ប៉ុន្តែសានជំទាស់មិនឱ្យធីតាចោះរន្ធលើឆ្នុកដបនោះទេ ។ ព្រឹកឡើងកុមារទាំងពីរបានយកដបដាក់ចង្រិតទៅថ្នាក់រៀន ។ ពេលបើកឆ្នុកដបចេញ គេឃើញចង្រិតទាំងបីនោះងាប់ ។ ហេតុអ្វីបានជាចង្រិតងាប់ ? តើធីតាមានហេតុផលអ្វីដែរ ក្នុងបញ្ហានេះ ?

## 2. នាទីប្រដាប់ដង្ហើម

### ក. ការចាប់យក $O_2$ និងការបោះបង់ $CO_2$

$O_2$ ដែលសារពាង្គកាយត្រូវការ បានមកពីបរិយាកាស ។ ក្នុងបរិយាកាសមានល្បាយឧស្ម័នច្រើនប្រភេទ តែសារពាង្គកាយ មិនប្រើប្រាស់ឧស្ម័នទាំងអស់នៅក្នុងខ្យល់ដង្ហើមចូលនោះទេ ។ នៅពេលដកដង្ហើមចេញ ឧស្ម័នស្ទើរទាំងអស់ត្រឡប់ចូលទៅក្នុងបរិយាកាសវិញ ។

$O_2$ ចាំបាច់ណាស់សម្រាប់ចំហេះអាហារនៅក្នុងសារពាង្គកាយ ដោយមានការបញ្ចេញថាមពលដែលកើតឡើងនៅក្នុងកោសិការបស់សារពាង្គកាយ ។ អាហារមិនឆេះក្នុងសារពាង្គកាយដូចជា ធ្យូងទេ ។ ដំបូង អាហារប្លែងជាស្ករងាយហៅថា គ្លុយកូស ។ ដោយមានការចូលរួមពីឧស្ម័នអុកស៊ីសែន គ្លុយកូសត្រូវបានបំបែកទៅជាឧស្ម័នកាបូនឌីអុកស៊ីត ទឹក និងថាមពលយ៉ាងច្រើន ។ ថាមពលមួយចំនួន ត្រូវបានបញ្ចេញពីសារពាង្គកាយក្រោមរូបរាងជាកម្តៅ ។ ប្រដាប់ដង្ហើមបំបាត់ចោល $CO_2$ និងទឹកខ្លះតាមសួត ។ "ចំហេះ" គ្លុយកូសប្រព្រឹត្តក្នុងសារពាង្គកាយហៅថា "ដង្ហើម" ។

### ខ. ប្រព័ន្ធធ្វើការរួមគ្នា

ប្រដាប់ដង្ហើម ជាប្រព័ន្ធមួយក្នុងចំណោមប្រព័ន្ធទាំងអស់នៃសារពាង្គកាយ ។ ដង្ហើមមិនអាចកើតឡើងបាន ដោយពុំមានប្រដាប់រំលាយអាហារនិងប្រដាប់របត់ឈាមទេ ។ ប្រដាប់ដង្ហើមចាប់យក $O_2$ បញ្ចូលទៅក្នុងសួត ។ នៅពេលនោះ ប្រដាប់រំលាយអាហារស្រូបយកគ្លុយកូសពីអាហារដែលអ្នកបរិភោគ ។ បន្ទាប់មកប្រដាប់របត់ឈាមដឹកនាំ $O_2$ និងគ្លុយកូសទៅកាន់កោសិកានៃសារពាង្គកាយដែលនៅទីនោះដង្ហើមកើតឡើង ។

# 3. ប្រដាប់ដង្ហើម

## 3.1. រូបផ្តុំ

មនុស្សដកដង្ហើមបានតាមរយៈប្រដាប់ដង្ហើម ។ រូប(ក)បង្ហាញពីរូបផ្តុំនៃប្រដាប់ដង្ហើមមនុស្ស ។

## 3.2. ផ្នែកផ្សេងៗនៃប្រដាប់ដង្ហើម

ប្រដាប់ដង្ហើមមនុស្សមានផ្លូវដង្ហើមនិងសួត ។ ផ្លូវដង្ហើមមានរន្ធច្រមុះ ដើមក បំពង់សំឡេង បំពង់ខ្យល់ និងទងសួត ។

- **រន្ធច្រមុះ :** ជាប្រហោង ដែលគ្របដណ្តប់ដោយភ្នាសសើម សម្បូរសរសៃឈាម ។ នៅលើភ្នាសសើម មានរោមល្អិតៗជាច្រើន ។ រោមច្រមុះមាននាទីចាប់យកធូលីនិងមីក្រូសារពាង្គកាយ ដែលចូលមកជាមួយខ្យល់កុំឱ្យចូលទៅក្នុងសួត ហើយធ្វើឱ្យខ្យល់ក្តៅនិងសើម ។
- **ដើមក :** ជាកន្លែងកាត់ខ្វែងរវាងផ្លូវអាហារនិងផ្លូវដង្ហើម ។
- **បំពង់សំឡេង :** ជាប្រអប់ឆ្អឹងខ្ចី ដែលមានគំពកមួយលយចេញមកខាងក្រៅបំពង់កហៅថា "គ្រាប់ពោធ" ។ គេមើលឃើញគ្រាប់ពោធច្បាស់ចំពោះមនុស្សប្រុស ។
- **បំពង់ខ្យល់ :** ជាបំពង់មួយមានប្រវែងប្រហែល 12cm ដែលកើតឡើងពីឆ្អឹងកងខ្ចី ។ ផ្ទៃខាងក្នុងនៃបំពង់ខ្យល់មានរោមល្អិតៗជាច្រើន ដុះកប់នៅក្នុងស្លេស្ម ។ រោមនេះបញ្ឈប់ធូលីនិងកម្ទេចកម្ទីផ្សេងៗកុំឱ្យចូលទៅក្នុងសួត ហើយបញ្ជូនវត្ថុទាំងអស់នេះឡើងច្រាលទៅក្នុងមាត់វិញ ដែលហៅថា "កំហាក" ។



រូប(ក) : រូបផ្តុំប្រដាប់ដង្ហើម



រូប(ខ) : ដើមក



រូប(គ) : កំណាត់បំពង់ខ្យល់និងទងសួត



រូប(ឃ): ទម្រង់ខាងក្នុងសួត

នៅខាងចុងបំពង់ខ្យល់មានបំពង់ខ្ចីពីរ គឺទងសួត ដែលដឹកនាំខ្យល់ចូលទៅក្នុងសួត ។ នៅក្នុងសួត ទងសួតនីមួយៗចែកជាកូនទងសួតរាប់ពាន់ ដែលនៅខាងចុងមានថង់សួត ។ ទីនេះជាកន្លែងដែលសារពាង្គកាយទទួលយក $O_2$ និងបញ្ចេញ $CO_2$ ទៅវិញ ។

## ៣.៣. ទម្រង់បន្ទាប់បន្សំជួយចលនាដង្ហើម

ក្រៅពីសរីរាង្គ ដែលរៀបរាប់ខាងលើ មានទម្រង់មួយចំនួនទៀតដែលចូលរួមក្នុងចលនាដង្ហើម ។ ទម្រង់ទាំងនោះមាន :

- ឆ្អឹងជំនីរការពារសួត ។
- សាច់ដុំចន្លោះឆ្អឹងជំនីរ ចូលរួមក្នុងចលនាដង្ហើមចេញនិងដង្ហើមចូល ។
- ស្រោមសួតជាស្បែកស្ដើងនៅចន្លោះសួតនិងឆ្អឹងទ្រូង ។ ស្រោមសួតកើតឡើងពីភ្នាសពីរស្រទាប់ ។ ស្រទាប់ក្នុងជាប់និងសួត ឯស្រទាប់ក្រៅជាប់នឹងផ្ទៃនៃប្រអប់ទ្រូង ។ នៅចន្លោះភ្នាសទាំងពីរមានទឹកសួត ។ ស្រោមសួតការពារសួតកុំឱ្យប៉ះនឹងឆ្អឹងជំនីរ ។
- សន្ទះទ្រូង ជាបន្ទះសាច់ដុំទ្រពីក្រោមសួត ។ សន្ទះទ្រូងក៏ចូលរួមក្នុងចលនាដង្ហើមចូលនិងចេញផងដែរ ។



សាច់ដុំនិងឆ្អឹងជំនី

### មេរៀនសង្ខេប

- ខ្យល់មានសារៈសំខាន់សម្រាប់ជីវិត ។ គ្រប់ភាវៈរស់ត្រូវការដកដង្ហើម ។
- ប្រដាប់ដង្ហើមស្រូបយក $O_2$ ពីបរិយាកាសខាងក្រៅ ចូលទៅក្នុងសារពាង្គកាយ ។ វាបញ្ចេញឧស្ម័ន $CO_2$ និងទឹកពីសារពាង្គកាយ ។
- ប្រដាប់ដង្ហើមមនុស្សមានផ្លូវដង្ហើមនិងសួត ។ ផ្លូវដង្ហើមមានរន្ធច្រមុះ ដើមក បំពង់សំឡេង បំពង់ខ្យល់ និងទងសួត ។
- ទម្រង់បន្ទាប់បន្សំ ដែលចូលរួមក្នុងចលនាដង្ហើមមាន ឆ្អឹងជំនីរ សាច់ដុំចន្លោះឆ្អឹងជំនីរ ស្រោមសួត និងសន្ទះទ្រូង ។

### សំណួរ

1 តើឧស្ម័នសំខាន់ដែលភាវៈរស់ត្រូវការចាំបាច់ជាអ្វី ?

2 តើនាទីសំខាន់របស់ប្រដាប់ដង្ហើមមានអ្វីខ្លះ ?

3 តើរូបធាតុប្រដាប់ដង្ហើមមនុស្សមានអ្វីខ្លះ ? តើផ្លូវដង្ហើមមានផ្នែកអ្វីខ្លះ ?

4 តើទម្រង់បន្ទាប់បន្សំដែលជួយក្នុងចលនាដង្ហើមមានអ្វីខ្លះ ?

មេរៀនទី

# 2 ដង្ហើម

**ចប់មេរៀននេះ សិស្សអាច**

- ពន្យល់ពាក្យដំណកដង្ហើម
- ពណ៌នាពីចលនាដង្ហើមចូលនិងដង្ហើមចេញ
- បកស្រាយពីទម្រង់លំអិតរបស់ថង់សួត
- បង្ហាញពីបណ្តូរឧស្ម័នរវាងកូនថង់សួតនិងបរិយាកាស ។

វាជាការចាំបាច់បំផុត ដែលត្រូវតែមានខ្យល់ចូលនិងចេញពីសារពាង្គកាយ ។ ខ្យល់នេះត្រូវបានផ្លាស់ប្តូរនៅពេលឆ្លងកាត់ក្នុងសារពាង្គកាយ ។ ដើម្បីដឹងច្បាស់ គេត្រូវប្រៀបធៀបសមាសភាពខ្យល់ចូលនិងចេញពីសារពាង្គកាយ ។

## 1. ភាវៈរស់បញ្ចេញ $CO_2$

ចូរពិនិត្យការពិសោធមួយចំនួនខាងក្រោមនេះ :




*រូប(ក) : ទឹកកំបោរថ្លានិង $CO_2$*




*រូប(ខ): ដង្ហើមនិងចំហាយទឹក*

នៅពេលអ្នកផ្លុំខ្យល់ចូលទៅក្នុងកែវមានទឹកកំបោរថ្លា អ្នកសង្កេតឃើញកែវ ដែលមានទឹកកំបោរថ្លាប្រែជាល្អក់ ។ លក្ខណៈនេះបញ្ជាក់ថា នៅក្នុងខ្យល់ដង្ហើមមានវត្តមានឧស្ម័ន $CO_2$ (រូបក) ។

កុមារីកុលាប កំពុងឆ្លុះកញ្ចក់ ដោយផ្លុំខ្យល់ដង្ហើមយ៉ាងខ្លាំងតាមមាត់ទៅលើកញ្ចក់។ នៅពេលនោះ នាងសង្កេតឃើញកញ្ចក់ឆ្លុះមុខឡើងស្រអាប់បន្តិចម្តងៗ។ សភាពស្រអាប់នេះ ជាតំណក់ទឹកល្អិតៗដែលធ្វើឱ្យកញ្ចក់ឆ្លុះមុខសើម។ តំណក់ទឹកល្អិតៗនេះជាចំហាយទឹក ដែលមាននៅក្នុងខ្យល់ដង្ហើម(រូបខ)។

ការវិភាគខ្យល់បង្ហាញឱ្យឃើញថា ភាវៈរស់ប្រើប្រាស់ $O_2$ ដែលមាននៅក្នុងខ្យល់ ឬក្នុងទឹក ហើយបញ្ចេញឧស្ម័ន $CO_2$ ពីសារពាង្គកាយ ដោយនាំមកជាមួយនូវចំហាយទឹកផងដែរ។

## 2. ដំណកដង្ហើម

ដំណាកដង្ហើម ជាចលនាខ្យល់ចូលនិងចេញពីសួត។ ដំណាកដង្ហើមបែបនេះមានឈ្មោះថា "ដង្ហើមក្រៅ" ព្រោះវាប្រព្រឹត្តទៅក្រៅកោសិកា។

### 2.1. ចង្វាក់ដង្ហើម



*ប្រអប់ទ្រូង*

ប្រអប់ទ្រូងកើតឡើងពីឆ្អឹងជំនីរ ឆ្អឹងខ្នង និងឆ្អឹងទ្រូង។ នៅចន្លោះឆ្អឹងជំនីរ មានសាច់ដុំចន្លោះឆ្អឹងជំនីរ។ សន្ទះទ្រូង ជាសាច់ដុំសំប៉ែត រាងកោងបន្តិច ភ្ជាប់នឹងឆ្អឹងជំនីរចុងក្រោយបីគូ។ សួតជិតជាប់នឹងប្រអប់ទ្រូង ហើយនឹងសន្ទះទ្រូង តាមរយៈស្រោមសួត។ ដូចនេះ នៅពេលប្រអប់ទ្រូងកើនមាឌ សួតក៏រីកមាឌតាមដែរ។ កំណើនមាឌនេះ ធ្វើឱ្យខ្យល់ចូល។ ចលនាដង្ហើម បង្ហាញឱ្យឃើញយ៉ាងច្បាស់តាមចលនាជាចង្វាក់របស់ប្រអប់ទ្រូងនិងចរន្តខ្យល់ដែលចូល តាមច្រមុះ ឬមាត់។ ចង្វាក់ដង្ហើមមានពីរដំណាក់ គឺដង្ហើមចូល និងដង្ហើមចេញ។

#### ក. ដង្ហើមចូល

នៅពេលដង្ហើមចូល សន្ទះទ្រូងកន្ត្រាក់និងទាញចុះក្រោម ដោយទាញប្រអប់ទ្រូងឡើងលើ ដែលធ្វើឱ្យវាកើនមាឌ។ កាលណាប្រអប់ទ្រូងកើនមាឌ សម្ពាធខ្យល់ក្នុងប្រអប់ទ្រូងទាប ដែលធ្វើឱ្យខ្យល់ពីក្រៅចូលទៅក្នុងសួត។

#### ខ. ដង្ហើមចេញ

ពេលដង្ហើមចេញ សន្ទះទ្រូងរលានិងទាញឡើងលើ ដែលធ្វើឱ្យមាឌប្រអប់ទ្រូងរួមតូច។ ដូចនេះសម្ពាធខ្យល់នៅក្នុងប្រអប់ទ្រូងកើន ដែលជំរុញឱ្យខ្យល់ចេញពីសួត។




*ចលនាដង្ហើមចូល*




*ចលនាដង្ហើមចេញ*

## 2.2. ប្រៀបធៀបដង្ហើមចេញនិងចូល

នៅក្នុងបន្ទប់ពិសោធន៍ គេអាចថ្លឹងឧស្ម័នដែលមានក្នុងខ្យល់។ គេដាក់កណ្ដុរមួយនៅក្រោមកណ្ដឹងមួយបិទជិតរយៈពេល 15នាទី។ គេថ្លឹងខ្យល់មុននិងក្រោយពិសោធន៍។ លទ្ធផលត្រូវបានបង្ហាញនៅតារាងទី 1 ។

ដោយធ្វើការប្រៀបធៀបសមាសភាពខ្យល់ដង្ហើមចូលនិងចេញ យើងសង្កេតឃើញថា ខ្យល់ប្រែប្រួលនៅពេលឆ្លងកាត់ចូលទៅក្នុងសួត។ បណ្ដូរឧស្ម័នកើតឡើងរវាងកូនថង់សួតនៃសារពាង្គកាយនិងបរិយាកាស។

គេថ្លឹងឧស្ម័នដែលមានក្នុងខ្យល់ដង្ហើមចូលនិងខ្យល់ដង្ហើមចេញរបស់មនុស្ស។ លទ្ធផលបង្ហាញក្នុងតារាងទី 2 ។

តារាងទី 1: លទ្ធផលក្នុង 1 000$cm^3$

| សមាសភាពខ្យល់ | មុនពិសោធន៍ | ក្រោយពិសោធន៍ |
|---|---|---|
| $N_2$ | 781 | 781 |
| $O_2$ | 209 | 197 7 |
| $CO_2$ | 9 7 | 21 |
| ឧស្ម័នផ្សេងៗ | 0.3 | 0.3 |

តារាងទី 2: សមាសភាពដង្ហើមចូលនិងចេញ

| សមាសភាពខ្យល់ | $O_2$ % | $CO_2$ % | $N_2$ % | ចំហាយទឹក |
|---|---|---|---|---|
| ដង្ហើមចូល | 21 | 0.03 | 79 | ប្រែប្រួល |
| ដង្ហើមចេញ | 16 | 4 | 79 | ឆ្អែត |

ដូចនេះ ខ្យល់ដែលអ្នកស្រូបចូលជាល្បាយឧស្ម័ន ។ ក្នុងល្បាយនេះបរិមាណ $O_2$ មានច្រើន ហើយបរិមាណ$CO_2$ មានតិចតួចនិងមានចំហាយទឹក ហើយក្រៅពីនេះជាអាសូត ។ ចំពោះខ្យល់ដង្ហើមចេញ បរិមាណ $O_2$ មានតិចនិងបរិមាណ $CO_2$ មានច្រើនជាងនៅក្នុងខ្យល់ត្រជាក់ ។ ក្រៅពីនេះជាអាសូត ។

# 3. បណ្តូរឧស្ម័ន

ក្រោយពេលខ្យល់ចូលទៅក្នុងកូនថង់សួត $O_2$ សាយចេញពីកូនថង់សួត ហើយជ្រាបចូលទៅក្នុងឈាម ។ $CO_2$ និងទឹកសាយចេញពីឈាមចូលទៅក្នុងកូនថង់សួតវិញ ។ លំនាំទាំងមូលនេះ ហៅថាបណ្តូរឧស្ម័ន ។ បណ្តូរឧស្ម័នកើតមានក្រៅកោសិកាហៅថា "ដង្ហើមក្រៅ" ។

## 3.1. ទម្រង់លំអិតនៃថង់សួត

នៅពេលដកដង្ហើម ខ្យល់ចូលតាមច្រមុះ ឬមាត់ បន្ទាប់មកវាឆ្លងកាត់តាមបំពង់សំឡេងទៅកាន់បំពង់ខ្យល់ ។ ផ្នែកខាងចុងនៃបំពង់ខ្យល់ចែកជា ទងសួតធំពីរ ហើយខ្លី ។ ទងសួតនីមួយៗភ្ជាប់នឹងសួតមួយ ។




ទម្រង់ក្នុងរបស់សួត

ក. ខ្នាត់ថង់សួត

ខ. ថង់សួតទាំងមូល

សួតជាសរីរាង្គទន់ ស្ពោត យឺត ហើយស្រាល ។ ទងសួតនីមួយៗចូលទៅក្នុងសួតមួយ ហើយបែកមែកជាងតូចៗជាបន្តបន្ទាប់ ហៅថាកូន**ទងសួត** ។ នៅចុងកូនទងសួតតូចបំផុតនីមួយៗមានថង់សួតមួយ ។ ថង់សួតនីមួយៗមានផ្លែជាច្រើន ដែលចងភ្ជាប់គ្នាជាចង្កោម ។ ផ្លែនីមួយៗហៅថា **កូនថង់សួត** ។ កូនថង់សួតនីមួយៗមានទំហំតូចនិងមានចំនួនប្រហែល 300 លាននៅក្នុងសួតម្ខាងៗ ។ កូនថង់សួតមាន

ភ្នាសស្តើង ហើយសើមដែលអាចធ្វើឱ្យឧស្ម័នឆ្លងកាត់បានយ៉ាងងាយស្រួល ។ សរសៃឈាមតូចៗដែលជាសរសៃប្លូរ មានភ្នាសស្តើងបំផុត ស្ថិតនៅជាប់នឹងផ្ទៃរបស់កូនថង់សួតនីមួយៗ ។ បណ្តូរឧស្ម័នដង្ហើមកើតមានរវាងកូនថង់សួតជាមួយឈាមនៅក្នុងសរសៃប្លូររបស់សួត ។

## ៣.២. បណ្តូរឧស្ម័ននៃកូនថង់សួត

រាល់ពេលដង្ហើមចូល កូនថង់សួតពេញដោយខ្យល់សម្បូរ $O_2$ ។ ឈាមនៅក្នុងសរសៃប្លូរជុំវិញ កូនថង់សួត មានកំហាប់ $O_2$ ទាប ។ ដូចនេះ $O_2$ ចាកចេញពីកូនថង់សួត ចូលទៅក្នុងឈាមនៃសរសៃប្លូរ ។ ចលនារបស់ $O_2$ ចូលក្នុងឈាមតាមបន្សាយ ។

នៅក្នុងឈាម $O_2$ ភ្ជាប់ជាមួយកោសិកាឈាមក្រហម ដែលដឹកនាំទៅគ្រប់កោសិកាទាំងអស់នៃសារពាង្គកាយ ។ ក្នុងកោសិកា $O_2$ ដែលសាយចូលទៅ ត្រូវបានប្រើប្រាស់តាមតម្រូវការរបស់វា ។ កោសិការាប់លានរបស់សារពាង្គកាយប្រើប្រាស់ $O_2$ ។

គ្រប់ពេលដែលឈាមចាប់យក $O_2$ ពីកូនថង់សួត ឈាមក៏បានបោះបង់ $CO_2$ ទៅក្នុងកូនថង់សួតវិញដែរ ។ តើ $CO_2$ បានមកពីណាដែរ ? កោសិការបស់សារពាង្គកាយផលិត $CO_2$ ដែលត្រូវសាយចូលទៅក្នុងឈាម ។ កោសិកាឈាមក្រហមដឹកនាំ $CO_2$ ទៅកាន់សួត ដែលនៅទីនោះ $CO_2$ សាយចូលក្នុងថង់សួត ។



*បណ្តូរឧស្ម័ននៃកូនថង់សួត*

ឈាមចេញពីកោសិកាទៅកាន់សួត សម្បូរ $CO_2$ ចំណែកខ្យល់នៅក្នុងកូនថង់សួត មានកំហាប់ $CO_2$ ទាបជាងក្នុងសរសៃឈាម ដូចនេះ $CO_2$ ត្រូវសាយចេញពីឈាមក្នុងសរសៃប្លូរ ចូលទៅក្នុងកូនថង់សួត ។ បន្ទាប់មក $CO_2$ ត្រូវបានបញ្ចេញពីសួតទៅក្នុងបរិយាកាសតាមចលនាដង្ហើមចេញ ។

## មេរៀនសង្ខេប

- ដំណកដង្ហើមជាចលនាខ្យល់ចូលនិងចេញពីសួត ។ ដំណកដង្ហើមបែបនេះហៅថា ដង្ហើមក្រៅ ព្រោះវាប្រព្រឹត្តទៅក្រៅកោសិកា ។
- ពេលដកដង្ហើមចូល សាច់ដុំឆ្អឹងជំនីរនិងសន្ទះទ្រូងកន្ត្រាក់ដែលធ្វើឱ្យខ្យល់ចូលទៅក្នុងសួត ពេលដកដង្ហើមចេញ សាច់ដុំឆ្អឹងជំនីរនិងសន្ទះទ្រូងរលា ដែលធ្វើឱ្យខ្យល់ចេញពីសួត ។
- ខ្យល់ក្នុងបរិយាកាស ជាល្បាយឧស្ម័ន ។ ក្នុងដង្ហើមចូលមានបរិមាណ $O_2$ ច្រើន ហើយបរិមាណ $CO_2$ តិចតួចនិងចំហាយទឹក ។ ក្រៅពីនេះមានឧស្ម័នអាសូត ។ ក្នុងខ្យល់ដង្ហើមចេញបរិមាណ $O_2$ តិច ហើយបរិមាណ $CO_2$ ច្រើនជាងក្នុងខ្យល់បរិសុទ្ធ ។ ក្រៅពីនេះជាអាសូត ។
- បណ្ដូរឧស្ម័នដង្ហើមកើតមានរវាងខ្យល់ក្នុងកូនថង់សួតជាមួយឈាមនៅក្នុងសរសៃប្ដូររបស់សួត ។ បណ្ដូរឧស្ម័នកើតឡើងយ៉ាងងាយស្រួល ពីព្រោះភ្នាសកូនថង់សួតនិងភ្នាសសរសៃប្ដូរស្ដើង ។

## ? សំណួរ

1. ដូចម្ដេចហៅថា ដំណកដង្ហើម ?
2. តើប្រអប់ទ្រូងបង្កឡើងពីផ្នែកណាខ្លះ ?
3. តើខ្យល់ដែលយើងស្រូបចូលមានឧស្ម័នអ្វីខ្លះ ?
4. តើសាច់ដុំណាខ្លះជួយក្នុងចលនាដង្ហើម ?
5. នៅពេលដង្ហើមចូលនិងចេញ តើសន្ទះទ្រូងធ្វើចលនាដូចម្ដេច ?
6. តើ $O_2$ សម្បូរក្នុងខ្យល់ដង្ហើមចូលឬចេញ ?
7. ចូរប្រៀបធៀបចលនាដង្ហើមចូលនិងដង្ហើមចេញ ?
8. តើបណ្ដូរឧស្ម័នក្នុងសួតប្រព្រឹត្តទៅនៅកន្លែងណា ?

មេរៀនទី

# 3 ដង្ហើមកោសិកា

**ចប់មេរៀននេះ សិស្សអាច**

- ពន្យល់ពាក្យ "ដង្ហើមកោសិកា"
- បកស្រាយពីការផលិតថាមពលនៅក្នុងកោសិកា
- រៀបរាប់ពីអនាម័យប្រដាប់ដង្ហើម
- រាប់ឈ្មោះជំងឺប្រដាប់ដង្ហើម ។

ការបំបែកអាហារ ដោយមានការចូលរួមពីឧស្ម័ន $O_2$ ដើម្បីផលិត $CO_2$ ទឹកនិងថាមពលហៅថា ដង្ហើមកោសិកា ។ ដង្ហើមកោសិកាប្រព្រឹត្តទៅនៅក្នុងកោសិកា ។

## 1. តម្រូវការថាមពល



*ការបំបែកអាហាររលាយ*



*តម្រូវការថាមពល*

ដង្ហើមជាលំនាំមួយសំខាន់ណាស់ ពីព្រោះវាបញ្ចេញថាមពលសម្រាប់គ្រប់សកម្មភាពទាំងអស់ដែលសារពាង្គកាយត្រូវការក្នុងការរស់រានមានជីវិតដូចជា ការដកដង្ហើម ការរំលាយអាហារ ការលូតលាស់ធំធាត់ ការធ្វើចលនា ... ។

## 2. ការផលិតថាមពលនៅក្នុងកោសិកា

សារពាង្គកាយត្រូវការថាមពល ដើម្បីរ៉ាប់រងនូវសកម្មភាពផ្សេងៗនៃជីវិត ។ ថាមពលនេះបានមកពីអាហារដែលអ្នកបរិភោគ ។ ចំពោះមនុស្ស បំលែងថាមពលពីអាហារទៅជាថាមពលដែលអាចប្រើប្រាស់បានដោយសារពាង្គកាយ ចាំបាច់ត្រូវប្រើប្រាស់ $O_2$ ។

ដើម្បីបំពេញតម្រូវការថាមពលទាំងនេះ តើសារពាង្គកាយត្រូវធ្វើដូចម្តេច ?




សារធាតុចិញ្ចឹមបានមកពីការបំបែកអាហារនៅពេលរំលាយអាហារ ហើយ $O_2$ ត្រូវបានចែកចាយតាមរយៈឈាមទៅឱ្យកោសិកាទាំងអស់ ។ កោសិកានីមួយៗបំពេញតម្រូវការផ្នែកថាមពលបានគ្រប់គ្រាន់ ដោយចេញពីសារធាតុទាំងនេះ ។

នៅក្នុងកោសិកា សារធាតុចិញ្ចឹមត្រូវបានបំបែកដោយសារវត្តមាន $O_2$ ។ ការបំបែកនេះតែងតែកើនឡើងជាលំដាប់ តាមរយៈប្រតិកម្មគីមីជាច្រើន ដោយមានជំនួយពីអង់ស៊ីមយថាប្រភេទ ។ នៅក្នុងរយៈពេលនៃប្រតិកម្មទាំងនេះ សារធាតុចិញ្ចឹមប្លែងជាថាមពលដែលប្រើប្រាស់បានដោយកោសិកា ។

សាច់ដុំកំពុងធ្វើចលនា ប្រើប្រាស់គ្លុយកូស ច្រើនជាងសាច់ដុំសម្រាក ។ ថាមពល ដែលផលិតបានតាមរយៈការបំបែកគ្លុយកូស អាចធ្វើឱ្យកោសិកាសាច់ដុំដំណើរការបាន ។ តម្រូវការថាមពលនៅក្នុងខ្លួនខ្ពស់ ដើម្បីថែរក្សាសីតុណ្ហភាពក្នុងសារពាង្គកាយក្នុងកម្រិត 37°C ដែលថេរជាងសីតុណ្ហភាពទាបខាងក្រៅសារពាង្គកាយ ។

ដូចនេះ ថាមពលមួយផ្នែកដែលរំដោះចេញ ត្រូវបានបំបែកក្រោមរូបរាងជាកម្តៅ ហើយប្រើប្រាស់ ដើម្បីរក្សាសីតុណ្ហភាពសារពាង្គកាយរបស់អ្នកឱ្យនៅក្នុងកម្រិតថេរ 37°C ។ ប្រតិកម្មគីមីទាំងឡាយកើតឡើងជាបន្តបន្ទាប់ ដូចនេះកោសិកាត្រូវការថាមពលជាប្រចាំ ដើម្បីបំពេញដំណើរការផ្សេងៗ ។ ការបំបែកសារធាតុចិញ្ចឹម ជាពិសេសស្ករគ្លុយកូសនិងអាស៊ីតខ្លាញ់ ហើយលទ្ធផលបានជាថាមពល ឧស្ម័នកាបូនិច ($CO_2$) និងទឹក (កាកសំណល់ត្រូវបានបំបាត់ចោលដោយសួត) ។

## 3. អនាម័យប្រដាប់ដង្ហើម

ដើម្បីឱ្យប្រដាប់ដង្ហើមបំពេញមុខងារបានប្រសើរ យើងត្រូវធ្វើតាមក្បួនអនាម័យដូចខាងក្រោម :

- ត្រូវដកដង្ហើមតាមច្រមុះ មិនមែនតាមមាត់ទេ ។ ខ្យល់ដែលចូលតាមច្រមុះស្អាតនិងមានកម្តៅទៀតផង ។
- ត្រូវចៀសវាងទម្លាប់អាក្រក់ទាំងឡាយណា ដែលធ្វើឱ្យប្រអប់ទ្រូងរឹតតឹងនិងរំខានដល់ការលូតលាស់របស់វា ដូចជាអង្គុយពិតទ្រូងលើតុជាដើម ។
- ត្រូវធ្វើលំហាត់ប្រាណឱ្យបានទៀងទាត់ ព្រោះវានាំឱ្យប្រអប់ទ្រូងកើនមាឌនិងអាចផ្ទុកខ្យល់ក្នុងសួតឱ្យកាន់តែប្រសើរឡើង ។
- ត្រូវនៅកន្លែងមានខ្យល់ច្រើន ហើយមានភាពបរិសុទ្ធ ខ្យល់បែបនេះសម្បូរ $O_2$ ច្រើន ។ ខ្យល់នៅវាលស្រែ គ្មានផ្សែងនិងឧស្ម័នពុលផ្សេងៗ ដូចខ្យល់នៅទីក្រុងទេ ។ ដូចនេះ ការរស់នៅក្នុងកន្លែងសម្បូរខ្យល់ ជាលក្ខណៈមួយប្រសើរបំផុតដល់សុខភាព ។

## 4. ជំងឺប្រដាប់ដង្ហើម

ជាទូទៅផ្សែងបារីបង្កគ្រោះថ្នាក់ដល់ប្រដាប់ដង្ហើម ។ ជំងឺផ្លូវដង្ហើមធ្ងន់ធ្ងរជាច្រើនបណ្តាលមកពីផ្សែងបារី ។ នៅក្បែរអ្នកជក់បារី ក៏អាចទទួលផលអាក្រក់ដល់ប្រដាប់ដង្ហើមដែរ ។ ផ្សែងបារី ខ្យល់កខ្វក់ កម្ទេចកម្ទីធូលី និងមេរោគមួយចំនួនអាចបង្កជំងឺដល់ប្រដាប់ដង្ហើម ។

- ជំងឺផ្តាសាយ ជាជំងឺរលាកភ្នាសស្លេមច្រមុះដែលបណ្តាលមកពីវីរុស ។ បើកាលណាមានជំងឺនេះគេមិនត្រូវធ្វេសប្រហែសទេ ពីព្រោះវាអាចបណ្តាលឱ្យមានជំងឺធ្ងន់ផ្សេងៗ ដូចជា រលាកដើមក រលាកបំពង់សំឡេង រលាកបំពង់ខ្យល់ រលាកទងសួតនិងសួត ហើមសួត រលាកស្រោមសួត ។

- ជំងឺរលាកសួត កាលណាធ្ងន់ធ្ងរ អាចបណ្ដាលឱ្យស្ទះសរសៃឈាម ។ ជំងឺរលាកទងសួតនិងសួត ហើមសួតនិងរលាកសួតសុទ្ធតែជាជំងឺធ្ងន់ធ្ងរ ព្រោះជំងឺនេះធ្វើឱ្យសួតហើម ខ្សោយ ហើយ អាចនាំឱ្យមានរបេងសួតទៀតផង ។
- សព្វថ្ងៃនេះមានជំងឺផ្ដាសាយថ្មី $AH_1N_1$ ដែលមានលក្ខណៈស្រដៀងនឹងជំងឺផ្ដាសាយតាមរដូវ ដែរ ។ មនុស្សភាគច្រើនធ្លាក់ខ្លួនឈឺ បានជាសះស្បើយក្នុងពេលមួយសប្ដាហ៍ បន្ទាប់ពីចាប់ផ្ដើម ចេញរោគសញ្ញាជំងឺនេះ ។ ក្នុងករណីខ្លះ ជំងឺនេះអាចក្លាយជាធ្ងន់ធ្ងរ ។ ចំពោះអ្នកជំងឺផ្ដាសាយ ថ្មីកម្រិតស្រាល ការព្យាបាលដូចគ្នានឹងជំងឺផ្ដាសាយធម្មតាដែរ ។
- ជំងឺប្រដាប់ដង្ហើមភាគច្រើនឆ្លងតាមខ្យល់ ។ ដើម្បីចៀសវាងការឆ្លងជំងឺ យើងត្រូវមានអនាម័យ ផ្ទាល់ខ្លួននិងពាក់ម៉ាសការពារនៅពេលនៅក្បែរអ្នកជំងឺ ឬនៅទីប្រជុំជន ។

**មេរៀនសង្ខេប**

- ការបំបែកអាហារដោយមានការចូលរួមពីឧស្ម័ន $O_2$ ដើម្បីផលិត $CO_2$ ទឹកនិងថាមពលហៅ ថា "ដង្ហើមកោសិកា" ។
- នៅក្នុងកោសិកា សារធាតុចិញ្ចឹមជាពិសេសគ្លុយកូស ត្រូវបានបំបែកដោយសារវត្តមាននៃ $O_2$ ។ ប្រតិកម្មគីមីប្រព្រឹត្តទៅជាបន្តបន្ទាប់ ដោយមានជំនួយពីអង់ស៊ីមយ៉ាងប្រភេទ ។ នៅក្នុង រយៈពេលនៃប្រតិកម្មទាំងនេះ សារធាតុចិញ្ចឹមប្ដូរជាថាមពល អាចប្រើប្រាស់បានដោយ កោសិកា ។
- ដើម្បីឱ្យប្រដាប់ដង្ហើមមានសុខភាពល្អ អ្នកត្រូវដកដង្ហើមតាមច្រមុះ រស់នៅក្នុងបរិស្ថានមាន ខ្យល់បរិសុទ្ធ ធ្វើលំហាត់ប្រាណជាប្រចាំនិងទៀងទាត់ កុំអង្គុយពិតទ្រូងលើតុ កុំដេកផ្កាប់មុខ ជាពិសេសចៀសវាងការជក់បារី ។ ផ្សែងបារី បង្កជំងឺផ្លូវដង្ហើមធ្ងន់ធ្ងរឬបណ្ដាលឱ្យស្លាប់ ។
- ជំងឺប្រដាប់ដង្ហើមមាន រលាកដើមក រលាកបំពង់សំឡេង រលាកបំពង់ខ្យល់ រលាកទងសួត និងសួត ហើមសួត រលាកស្រោមសួត មហារីកសួត ។

## ? សំណួរ

1. ដូចម្ដេចហៅថា ដង្ហើមកោសិកា ?
2. ហេតុអ្វីបានជាសារពាង្គកាយត្រូវការថាមពល ?
3. តើថាមពលផលិតឡើងនៅកន្លែងណា ?
4. ចូររាប់ឈ្មោះជំងឺប្រដាប់ដង្ហើម ។

# 4 ប្រព័ន្ធដំណឹកនាំ

**ចប់មេរៀននេះ សិស្សអាច**

- ❑ ប្រាប់ពីផ្នែកផ្សេងៗនៃប្រដាប់របត់ឈាម
- ❑ បង្ហាញពីនាទីរបត់ឈាមក្នុងសារពាង្គកាយ
- ❑ រាប់ឈ្មោះនិងពណ៌នាពីកោសិកាឈាមនីមួយៗ
- ❑ បកស្រាយពីដំណើរកំណកឈាម
- ❑ ពណ៌នាពីជំងឺឈាម ។

គ្រប់ភាវៈរស់ទាំងអស់ ត្រូវការសារធាតុចិញ្ចឹម ដើម្បីប្រើប្រាស់ក្នុងការដឹកនាំសកម្មភាពផ្សេងៗទៀតនៃជីវិត ។

## 1. តម្រូវការប្រព័ន្ធដំណឹកនាំ

### 1.1. សារពាង្គកាយតូច




សារពាង្គកាយតូចដូចជា ប្រូទីសឯកកោសិកា សារាយ ស្លែព្រៃនិងសត្វពហុកោសិកាងាយ (អ៊ីត) រស់នៅក្នុងទឹក ដែលកោសិកាទាំងអស់នៃសារពាង្គកាយស្ថិតនៅត្រាំក្នុងទឹក ។ $O_2$ នៅក្នុងទឹកសាយចូលក្នុងកោសិកានីមួយៗ ។ ឯកាកសំណល់ សាយចេញពីកោសិកានីមួយៗដែរ ។ អាហាររលាយនៅក្នុងប្រហោងនៃសារពាង្គកាយ (អ៊ីត) សាយចូលក្នុងកោសិកាទាំងអស់ ។ ទឹកដែលជាមជ្ឈដ្ឋានរស់នៅរបស់វា មាននាទីជាអ្នកចាប់យកនិងបញ្ចេញសារធាតុទាំងនេះ ។

### 1.2. សារពាង្គកាយធំ




ចំពោះសត្វពហុកោសិកាថ្នាក់ខ្ពស់មានសារពាង្គកាយធំៗ ។ កោសិការបស់វាស្ថិតនៅក្នុងទីជម្រៅឆ្ងាយពីផ្ទៃខាងលើនៃសារពាង្គកាយ ។ បន្សាយជាលំនាំមួយយឺត ដែលមិនអាចដឹកនាំសារធាតុផ្សេងៗឆ្លងកាត់ទីដ៏ឆ្ងាយបានទេ ។ ដូចនេះ សារពាង្គកាយពហុកោសិកាត្រូវការប្រព័ន្ធដំណឹកនាំសម្រាប់ដឹកនាំសារធាតុរលាយទៅពាសពេញសារពាង្គកាយទាំងមូលបានយ៉ាងរហ័ស ។

## 2. ប្រព័ន្ធដំណឹកនាំក្នុងខ្លួនមនុស្ស

សារពាង្គកាយមនុស្ស កើតឡើងពីកោសិការាប់ពាន់លាន ។ កោសិកានីមួយៗ ប្រៀបដូចជារោងចក្រតូចមួយ ដែលចាំបាច់ត្រូវទទួលបានការផ្គត់ផ្គង់នូវសារធាតុគីមីមួយចំនួន ។ ប្រព័ន្ធដំណឹកនាំឬប្រដាប់របត់ឈាម ផ្តល់ឱ្យកោសិកានូវអាហារនិង $O_2$ ហើយយកពីកោសិកាមកវិញនូវផលិតផលកាកសំណល់និង $CO_2$ ។ ប្រដាប់របត់ឈាមមានបេះដូង សរសៃឈាម និងឈាម ។

### 2.1. សកម្មភាព

ចូរធ្វើសកម្មភាពដូចក្នុងរូបនេះ :

តើអ្នកមានអារម្មណ៍ដូចម្តេចនៅពេលស្ទង់ជីពចរកដៃនិងបំពង់ក ? ចូររាប់ចង្វាក់ជីពចរក្នុងមួយនាទី ។ ចង្វាក់ជីពចរជាមធ្យមមាន 75 ដងក្នុងមួយវិនាទី ។


ការស្ទង់ជីពចរកដៃ


ការស្ទង់ជីពចរក

## 2.2. បេះដូង

ឈាមដែលដឹកនាំឧស្ម័នដង្ហើម សារធាតុចិញ្ចឹម និងកាកសំណល់ត្រូវបានធ្វើឱ្យមានចលនាដោយសារបេះដូង ។ បេះដូង ជាសរីរាង្គសំខាន់បំផុតក្នុងសារពាង្គកាយ ។ បេះដូងចាប់ផ្ដើមកន្ត្រាក់តាំងពីមុនពេលប្រសូតមកម្ល៉េះ ហើយវាកន្ត្រាក់ទៀងទាត់ជាប់ជានិច្ច ពេញមួយជីវិតរបស់យើង ។



*ប្រអប់ទ្រូង*



*កំនុះបណ្ដោយបេះដូង*

បេះដូងស្ថិតក្នុងប្រអប់ទ្រូង នៅចន្លោះសួតទាំងពីរ ។ វាជាសាច់ដុំបេះដូងមានពណ៌ក្រហមប្រហោងក្នុង ដែលមានទំហំប៉ុនក្ដាប់ដៃ ។ បេះដូងចែកជាពីរចំហៀងដាច់ពីគ្នា ដោយសន្ទះខណ្ឌ គឺបេះដូងឆ្វេងនិងបេះដូងស្ដាំ ។ បេះដូងមួយចំហៀងមានថតពីរ គឺថតលើមួយនិងថតក្រោមមួយ ដែលទាក់ទងគ្នាតាមរយៈរន្ធមួយ ។ នៅត្រង់រន្ធនោះមានប្រិសបេះដូង ។ ផ្ទៃជញ្ជាំងបេះដូងថតក្រោមក្រាស់ឯថតលើស្ដើង ។

## 2.3. សរសៃឈាម

នៅក្នុងសរីរាង្គនីមួយៗ អាកទែបែកមែកសាខាជាសរសៃតូចៗហៅថា កូនអាកទែ ។ កូនអាកទែនីមួយៗ ចែកជាបន្តបន្ទាប់បានជាសរសៃតូចៗ ហើយឆ្មារហៅថា សរសៃឫស ។ បន្ទាប់មកសរសៃឫសរួមបញ្ចូលគ្នាជាសរសៃឈាមធំៗហៅថា កូនវ៉ែន ។ កូនវ៉ែនរួមបញ្ចូលធំទៅៗហើយតិចទៅៗហៅថា **វ៉ែន** ។

- អាកទែជាសរសៃឈាមមួយបែប ដែលយឺតនិងអាចកន្ត្រាក់បាន ។ អាកទែដឹកនាំឈាមចេញឆ្ងាយពីបេះដូង ទៅកាន់គ្រប់ផ្នែកទាំងអស់នៃសារពាង្គកាយ ។ អាកទែដឹកនាំឈាមសម្បូរ $O_2$ ។




*ប្រភេទផ្សេងៗនៃសរសៃឈាម*

- សរសៃប្ចូរជាសរសៃឈាមឆ្មារៗ ។ ភ្នាសរបស់សរសៃប្ចូរស្ដើង ដែលអាចឱ្យធាតុរាវនៃឈាមជ្រាបឆ្លងកាត់វាបាន ។ ធាតុរាវនេះដឹកនាំសារធាតុចិញ្ចឹមនិង $O_2$ ទៅឱ្យកោសិកានិងនាំមកវិញនូវកាកសំណល់និង $CO_2$ ពីកោសិកានៃសារពាង្គកាយ ។
- វ៉ែនដឹកនាំឈាមពីគ្រប់ផ្នែកទាំងអស់នៃសារពាង្គកាយទៅកាន់បេះដូង ។ វាមានភ្នាសស្ដើងហើយទន់រយាក ។ ឈាមឆ្លងកាត់វ៉ែនក្នុងល្បឿនយឺតៗ ។ នៅក្នុងវ៉ែនមានប្រិសសម្រាប់ទប់ឈាមមិនឱ្យហូរបញ្ច្រាស ។ វ៉ែនស្ទើរតែទាំងអស់ដឹកនាំឈាមខ្សត់ $O_2$ ។ វ៉ែនដែលនៅក្បែរសាច់ដុំជាប់ឆ្អឹងត្រូវបានគាបនៅពេលសាច់ដុំកន្ត្រាក់ម្ដងៗ ។ សកម្មភាពនេះជួយចលនាឈាមឆ្ពោះទៅកាន់បេះដូង ។

## 2.4. នាទីរបស់របត់ឈាម




*គំនូសបំប្រួញរបត់ឈាម*

ឈាមធ្វើចលនាជាប់រហូតទៅពាសពេញសារពាង្គកាយនៅក្នុងប្រព័ន្ធបិទជិតមួយ ។ អ្នកវិទ្យាសាស្ត្រចែករបត់ឈាមជាពីរផ្នែក :

- **របត់ឈាមខ្លីឬរបត់ឈាមសួត** : ឈាមចេញពីបេះដូងទៅកាន់សួត ដោយដឹកនាំកាកសំណល់និង $CO_2$ នៃកោសិកាទៅឱ្យសួត ។ បន្ទាប់មកឈាមចេញពីសួត ដោយដឹកនាំ $O_2$ ទៅបេះដូងវិញ ។

- **របត់ឈាមវែង** : ឈាមចេញពីបេះដូង ដោយដឹកនាំអាហារនិង $O_2$ ទៅឱ្យកោសិកានៃសារពាង្គកាយ ។ បន្ទាប់មកឈាមដឹកនាំកាកសំណល់និង $CO_2$ ពីកោសិកាចូលទៅបេះដូងវិញ ។
- **របត់ឈាមក្លូរ៉ូណែ** : បេះដូងមានសរសៃឈាមផ្សេងទៀតសម្រាប់ផ្គត់ផ្គង់សារធាតុចិញ្ចឹមនិង $O_2$ ដល់កោសិកាបេះដូងនិងដកយកកាកសំណល់មកវិញ ។ សរសៃឈាមនេះទាក់ទងនិងរបត់ឈាមក្លូរ៉ូណែ ។

## 3. ឈាម

នៅក្នុងសារពាង្គកាយមនុស្ស ជាមធ្យមឈាមមានប្រហែល 5.5 លីត្រ ។ ឈាមជាជាលិកាមួយបែប ដែលបង្កឡើងពីគោលិកាក្រហម គោលិកាស ប្លាកែត និងប្លាស្មា ។ ឈាមមានប្រហែល 8% នៃម៉ាសរបស់សារពាង្គកាយទាំងមូល ។ ប្រសិនបើអ្នកមានទម្ងន់ 45kg ឈាមដែលធ្វើចលនានៅក្នុងសារពាង្គកាយមានប្រហែល 3.6 kg ។

### 3.1. ប្លាស្មា

ប្លាស្មាជាធាតុរាវពណ៌លឿងខ្ចី ដែលភាគច្រើនជាទឹកនិងសារធាតុរលាយ រួមមានសារធាតុចិញ្ចឹម សារធាតុខនិជ ឧស្ម័ន និងកាកសំណល់រលាយ ។

### 3.2. គោលិកាក្រហម



*ពិនិត្យក្រោមមីក្រូទស្សន៍*

ឈាមមួយតំណក់តូចមានគោលិកាក្រហមប្រហែល 5លានកោសិកា ។ គោលិកាក្រហមមានរាងជាកូនថាសផតសងខាង ។ វាគ្មានណ្វៃយ៉ូទេ ។ វាមានពណ៌ក្រហម ព្រោះវាមានអេម៉ូក្លូប៊ីន ។

អេម៉ូក្លូប៊ីនជាធាតុគីមី ដែលអាចដឹកនាំ $O_2$ និង $CO_2$ ។ គោលិកាក្រហមដឹកនាំ $O_2$ ពីសួតទៅឱ្យកោសិកាទាំងអស់នៃ សារពាង្គកាយ ហើយដឹកនាំ $CO_2$ ពីកោសិកាទៅកាន់សួតវិញ ។ គោលិកាក្រហមអាចរស់បានរយៈពេលប្រហែល 120 ថ្ងៃ ។វាកើតឡើងនៅក្នុងខួរឆ្អឹងវែង (ឆ្អឹងវែងភ្លៅនិងដើមដៃ) ចំនួនពី 2-3 លានក្នុងមួយវិនាទី ។ កោសិកាចាស់រេចរិលងាប់ទៅវិញក្នុងចំនួនស្មើគ្នា នៅពេលតែមួយ ។

## ៣.៣. គោលិកាស

មនុស្សមានសុខភាពល្អមានចំនួនគោលិកាសប្រហែល 8000 ក្នុងឈាមមួយតំណក់តូច ។ គោលិកាសមានទំហំធំជាងគោលិកាក្រហម ។ គោលិកាសទាំងអស់មានណ្វៃយ៉ូ ។ ប្រសិនបើមានបាក់តេរីច្រើនជ្រៀតចូលមក ចំនួនគោលិកាសអាចកើនឡើងរហូតដល់ 20 000 ក្នុងឈាមមួយតំណក់ ។ កំណើននេះមានរយៈពេលប្រហែល 2-3 ម៉ោង ។ គោលិកាសផ្លាស់ទីចូលទៅក្នុងកន្លែងមានដំបៅក្លាយដែលកជាខ្ទុះដោយសារបាក់តេរី ។ ខ្ទុះជាសារធាតុពណ៌ស ដែលកើតឡើងពីរាប់លានគោលិកាសរស់ គោលិកាសងាប់ កោសិកាងាប់របស់សារពាង្គកាយនិងបាក់តេរីងាប់ ។ ចំនួនគោលិកាសកើននៅពេលមានដំបៅក្លាយ ហើយចំនួននេះ ត្រឡប់មកធម្មតាវិញនៅពេលដំបៅជា ។

## ៣.៤. ប្លាកែត

ប្លាកែតជាបំណែកតូចៗនៃកោសិកា ដែលមានកំណើតនៅក្នុងខួរឆ្អឹង ។ ក្នុងឈាមមួយតំណក់តូចមានប្លាកែតប្រហែល 250 000 ។ រយៈពេលនៃជីវិតរបស់វាខ្លីណាស់ប្រហែលពី 5-10 ថ្ងៃ ។ នាទីសំខាន់របស់វា គឺចូលរួមក្នុងដំណើរកំណកឈាម ។

# 4. កំណកឈាម



*កំណកឈាម*

ក. ឈាមហូរចេញពីមុខរបួស ។

ខ. ប្លាកែតភ្ជិតកន្លែងរបួសនិងបញ្ចេញសារធាតុគីមី ដែលធ្វើឱ្យប្លាកែតនៅក្បែរនោះស្អិតនិងផលិតភីប្រ៊ីនច្រើន ដើម្បីរាំងគោលិកាស គោលិកាក្រហម និងប្លាកែត ។បន្ទាប់មកឈាមក្លាយជាទាប់អន្ទិលហៅថាកំណកឈាម ។

គ. កំណកឈាមរឹង ហើយក្លាយជាក្រមរ ។ គោលិកាសបំផ្លាញបាក់តេរីដែលជ្រៀតចូលតាមមុខរបួស ។

ឃ. ក្រមរមាននាទីថែរក្សាមុខរបួសឱ្យស្អាត ទន្ទឹមនោះស្បែកថ្មីក៏លូតលាស់ បន្ទាប់មកក្រមរគឺរបើកចេញ ។

# 5. ជំងឺឈាម

អេម៉ូក្លូប៊ីនមានផ្ទុកធាតុដែក ។ ប្រសិនបើក្នុងរបបអាហារមានធាតុដែកមិនគ្រប់គ្រាន់ វានឹងមានអេម៉ូក្លូប៊ីនតិចតួចនៅក្នុងគោលិកាក្រហម ។ ដោយសារបរិមាណអេម៉ូក្លូប៊ីនតិច ធ្វើឱ្យគោលិកាក្រហមគ្មានលទ្ធភាពដឹកនាំ $O_2$ ឱ្យបានគ្រប់គ្រាន់សម្រាប់តម្រូវការរបស់កោសិកានៃសារពាង្គកាយ ។ លក្ខខណ្ឌនេះបណ្ដាលឱ្យមានជំងឺស្លេក ។ អ្នកជំងឺមានអារម្មណ៍អស់កម្លាំង ។ ដើម្បីព្យាបាលជំងឺ ជាទូទៅត្រូវផ្ដល់ធាតុដែកទៅក្នុងរបបអាហារ ។ វីតាមីនភាគច្រើនមានផ្ទុកធាតុដែក ។ ជំងឺមហារីកឈាមជាជំងឺមួយដែលចំនួនគោលិកាសកើនឡើងមិនធម្មតា ។ កំណើននេះមានចំនួនច្រើនជាងនៅពេលមានជំងឺបៅក្លាយ ហើយចំនួននេះមិនត្រឡប់មកធម្មតាវិញទេ ។ អ្នកមានជំងឺអាចមានគោលិកាសចំនួនពី 30 000 ទៅ 50 000 ក្នុងឈាមមួយតំណក់ ។ ដើម្បីព្យាបាលជំងឺនេះ គេត្រូវបញ្ចូលឈាម ឬផ្សាំខួរឆ្អឹង ។

**មេរៀនសង្ខេប**

- សារពាង្គកាយងាយ គ្មានប្រព័ន្ធដំណឹកនាំទេ ។ សារធាតុចិញ្ចឹមនិង $O_2$ សាយចូលក្នុងកោសិកាដោយផ្ទាល់ ហើយកាកសំណល់និង $CO_2$ សាយចេញពីកោសិកាទៅក្នុងមជ្ឈដ្ឋានជុំវិញ ។ ចំពោះសារពាង្គកាយធំៗ ប្រព័ន្ធដំណឹកនាំជាប្រដាប់របត់ឈាម ដែលដឹកនាំអាហារនិង $O_2$ ទៅឱ្យកោសិកាទាំងអស់នៃសារពាង្គកាយ ហើយដឹកនាំកាកសំណល់និង $CO_2$ ពីកោសិកាមកវិញ ។
- ប្រដាប់របត់ឈាមមានបេះដូង សរសៃឈាមនិងឈាម ។ សន្ទះខណ្ឌចែកបេះដូងជាពីរចំហៀង គឺបេះដូងឆ្វេងនិងបេះដូងស្ដាំ ។ បេះដូងមួយចំហៀងៗមានថតលើមួយនិងថតក្រោមមួយ ។ ថតលើទាក់ទងថតក្រោមតាមរយៈរន្ធមួយ ។ នៅត្រង់រន្ធនោះមានប្រឹសបេះដូង ។
- អាកទែជាសរសៃឈាម ដែលដឹកនាំឈាម ទៅឆ្ងាយពីបេះដូង ។ សរសៃប្អូរជាចំណុចប្រសព្វរវាងអាកទែនិងវ៉ែន ។ វ៉ែនជាសរសៃឈាមដែលដឹកនាំឈាមចូលទៅក្នុងបេះដូងវិញ ។
- របត់ឈាមខ្លីជាដំណើរឈាមរវាងបេះដូងនិងសួត ។ របត់ឈាមវែងជាដំណើរឈាមរវាងបេះដូងនិងកោសិកានៃសារពាង្គកាយ ។
- ឈាម ជាជាលិកាមួយបែបដែលបង្កឡើងដោយប្លាស្មា គោលិកាក្រហម គោលិកាស និងប្លាកែត ។

## ? សំណួរ

1. តើប្រដាប់របត់ឈាមមានសរីរាង្គអ្វីខ្លះ ?
2. តើឈាមធ្វើចលនានៅក្នុងខ្លួនមនុស្សដោយសារអ្វី ?
3. តើសរសៃឈាមមានប៉ុន្មានបែប ? អ្វីខ្លះ ?
4. តើប្រិសមាននាទីដូចម្ដេច ?
5. តើធាតុបង្ករបស់ឈាមមានអ្វីខ្លះ ?
6. តើកោសិកាឈាមណាមួយដែលផ្ទុកអេម៉ូក្លូប៊ីន ?
7. តើប្លាស្មាជាអ្វី ?

## ? សំណួរបញ្ចប់ជំពូកទី៤

**I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវ**

1. បណ្ដូរឧស្ម័នកើតឡើងរវាងសរសៃបួរនិង

☐ក. ទងសួត ☐ខ. កូនថង់សួត ☐គ. កូនទងសួត ☐ឃ. បំពង់ខ្យល់ ។

2. ខ្យល់សើមត្រូវបានច្រោះនិងកម្ដៅនៅក្នុង

☐ក. ដើមក ☐ខ. បំពង់សំឡេង ☐គ. រន្ធច្រមុះ ☐ឃ. បំពង់ខ្យល់ ។

3. ប្រហោងនៅផ្នែកខាងលើនៃបេះដូងជា

☐ក. ថតលើ ☐ខ. ថតក្រោម ☐គ. ប្រិស ☐ឃ. អាកទែ ។

4. ប្រតិកម្មដែលកើតឡើងក្នុងកោសិការវាង $O_2$ និងគ្លុយកូស ដោយបញ្ចេញថាមពលហៅថា

☐ក. ដង្ហើម ☐ខ. រលាកទងសួត ☐គ. ហើមសួត ☐ឃ. បញ្ចេញចោល ។

5. ធាតុបង្កនៃឈាមចូលរួមក្នុងដំណើរកំណកឈាមជា

☐ក. ប្លាកែត ☐ខ. គោលិកាក្រហម ☐គ. គោលិកាស ☐ឃ. អេម៉ូក្លូប៊ីន ។

6. របត់ឈាមដែលធ្វើដំណើរទៅគ្រប់សរីរាង្គទាំងអស់ជា

☐ក. កូរ៉ូណែ ☐ខ. របត់ឈាមខ្លី ☐គ. របត់ឈាមវែង ☐ឃ. សរីរាង្គ ។

II. ចូរបំពេញចន្លោះនៃឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ

1. ចង្កោមថង់ខ្យល់ នៅក្នុងសួតហៅថា ................ ។
2. នៅក្នុងសួត បន្សាយ $O_2$ និង $CO_2$ កើតឡើងដោយឆ្លងកាត់ភ្នាសរបស់ ................ ។
3. សរសៃឈាមដែលមានប្រឹសជា ................ ។
4. សារធាតុដែលផ្ទុកធាតុដែកនៅក្នុងគោលិកាក្រហមជា ................ ។
5. កោសិកាឈាមមួយបែប ដែលប្រឆាំងនឹងភ្នាក់ងារបង្កជំងឺជា ................ ។
6. គោលិកាប្រហមចាប់យក ................ នៅក្នុងសួត ។
7. ឈាមដឹកនាំអាហារនិង ................ ទៅកាន់កោសិកា ។
8. សរសៃឈាមដែលភ្ជាប់អាកទែទៅវ៉ែនជា ................ ។
9. ជាលិកាពិសេស ដែលត្រួតពិនិត្យចង្វាក់បេះដូងជា ................ ។
10. កូនថង់សួតត្រូវបានព័ទ្ធជុំវិញដោយបណ្តាញ ................ ដែលកើតមានបណ្តូរឧស្ម័ន ។

III. ចូរឆ្លើយនឹងសំណួរខាងក្រោម

1. ចូរពន្យល់ពីលក្ខណៈខុសគ្នារវាងដំណកដង្ហើមនិងដង្ហើម ។
2. ហេតុអ្វីបានជាការដកដង្ហើមតាមច្រមុះមានលក្ខណៈប្រសើរ ?
3. តើនាទីសំខាន់នៃប្រដាប់ដង្ហើមជាអ្វី ?
4. តើនឹងមានអ្វីកើតឡើង នៅពេលមានបណ្តូរ $O_2$ និង $CO_2$ នៅក្នុងសួត ?
5. តើខ្យល់ចូលនិងចេញពីសួតបណ្តាលមកពីអ្វី ?
6. តើឈាមជាអ្វី ?
7. ចូរប្រៀបធៀបគោលិកាស គោលិកាក្រហម ប្លាកែត និងប្លាស្មា ។
8. ប្រសិនបើគោលិកាក្រហមមិនអាចចាប់យក $CO_2$ និងកាកសំណល់ពីកោសិកា តើវានឹងមានបញ្ហាអ្វីកើតឡើងចំពោះជាលិកា ?
9. ហេតុអ្វីបានជាបំពង់ខ្យល់មានឆ្អឹងខ្ចី ឯបំពង់អាហារគ្មាន ?
10. ចំពោះសួតដែលមានកូនថង់ខ្យល់ច្រើនជំនួសដោយថង់ខ្យល់ធំពីរ តើវាមានអត្ថប្រយោជន៍អ្វីខ្លះ ?
11. តើប្រដាប់រំលាយអាហារ ប្រដាប់របត់ឈាមមានទំនាក់ទំនងនឹងប្រដាប់ដង្ហើមដូចម្តេចដែរ ?
12. តើជំងឺស្លេកជាអ្វី ? តើវាមានទំនាក់ទំនងនឹងកោសិកាសួតយ៉ាងដូចម្តេច ?
13. ប្រសិនបើប្រឹសក្នុងសរសៃវ៉ែនសំខាន់ៗមិនដំណើរការ តើវានឹងមានអ្វីកើតឡើង ?
14. នៅពេលបេះដូងគ្មានលទ្ធភាពសប់ឈាម តើផលិតផលកាកសំណល់ដង្ហើមកើតឡើងក្នុងឈាមនិងកោសិកាជាអ្វី ?

# ជំពូកទី 5 ការថែរក្សាសុខភាព




ដើម្បីទទួលបានសុខភាពល្អ យើងត្រូវការសារធាតុចិញ្ចឹមនៅក្នុងអាហារ ។ តើសុខភាពអាចប្រែប្រួលឬទេ នៅពេលយើងផ្លាស់ប្តូរប្រភេទនិងបរិមាណអាហារដែលយើងបរិភោគ ? ពិតមែនហើយ ប្រភេទនិងបរិមាណអាហារដែលយើងបរិភោគ មានសារៈសំខាន់ខ្លាំងណាស់ ព្រោះសរីរាង្គកាយទទួលបាននូវរូបធាតុដើមពីអាហារ ។ បើសរីរាង្គកាយទទួលបាននូវរូបធាតុដើមត្រឹមត្រូវ នោះយើងនឹងមានសុខភាពល្អ ។ ដូចនេះ តើយើងត្រូវបរិភោគអ្វីខ្លះ ?

មេរៀនទី

# 1 អាហារ

**ចប់មេរៀននេះ សិស្សអាច**

- ❑ ប្រាប់ឈ្មោះអាហារបីប្រភេទដែលសារពាង្គកាយត្រូវការ
- ❑ បង្ហាញពីសារធាតុចិញ្ចឹមសំខាន់ៗដែលផ្តល់ថាមពល
- ❑ ពណ៌នាពីសារធាតុចិញ្ចឹមសម្រាប់ការលូតលាស់និងជួសជុល
- ❑ ពន្យល់ពីសារៈសំខាន់នៃទឹកចំពោះសារពាង្គកាយ ។

យើងទាំងអស់គ្នាត្រូវការអាហារ ។ យើងបរិភោគអាហារដែលផ្តល់នូវសារធាតុចិញ្ចឹមសំខាន់ៗសម្រាប់ជាប្រភពថាមពលនៃសារពាង្គកាយ ។ តើថាមពលនេះមានសារៈសំខាន់អ្វីខ្លះដល់សារពាង្គកាយ ?

## 1. ការប្រើប្រាស់ថាមពល

សារពាង្គកាយប្រើប្រាស់ថាមពលដើម្បីលូតលាស់ ធំធាត់ ធ្វើសកម្មភាពផ្សេងៗ ... ។




*តម្រូវការអាហារ*

## 2. ប្រភេទផ្សេងៗនៃអាហារ

អាហារដែលយើងបរិភោគរៀងរាល់ថ្ងៃ ជារបបអាហារ ។ យើងត្រូវការអាហារផ្សេងៗជាច្រើនសម្រាប់តម្រូវការខុសៗគ្នា ។ អាហារសំខាន់ៗមានបីប្រភេទគឺ អាហារថាមពល អាហារសាងសង់ និងអាហារការពារ ។

### 2.1. អាហារថាមពល

អាហារថាមពលផ្តល់ឱ្យយើងនូវថាមពលសម្រាប់ធ្វើសកម្មភាពផ្សេងៗនិងរក្សាកម្តៅក្នុងខ្លួន ។ អាហារថាមពលសំខាន់មានគ្លុយស៊ីតនិងលីពីត ។

#### ក. គ្លុយស៊ីត



គ្លុយកូសមាននៅក្នុង ផ្លែឈើ បន្លែខ្លះៗ ទឹកឃ្មុំ



អាមីដុងមានក្នុងបាយ ដំឡូង ចេក ...



សែលុយឡូសមាននៅ ក្នុងបន្លែនិងផ្លែឈើ

នៅក្នុងគ្រាប់ធញ្ញជាតិ សារធាតុចិញ្ចឹមសំខាន់ជាងគេជាគ្លុយស៊ីត ។ គ្លុយស៊ីតផ្តល់នូវប្រភពថាមពលយ៉ាងសំខាន់ដល់សារពាង្គកាយ ។ នៅពេលយើងបរិភោគអាហារដែលមានជាតិស្ករឬអាមីដុងខ្ពស់ សារពាង្គកាយបំបែកអាហារទាំងនេះយ៉ាងរហ័សឱ្យទៅជាគ្លុយកូស ។ គ្លុយកូសលើសពីតម្រូវការរបស់សារពាង្គកាយ ប្លែងជាគ្លីកូសែន ហើយស្តុកទុកក្នុងថ្លើមនិងសាច់ដុំ ។ នៅពេលយើងបរិភោគមិនគ្រប់គ្រាន់ គ្លីកូសែនប្លែងជាគ្លុយកូសវិញ ។ ដូចនេះយើងត្រូវការគ្លុយស៊ីតដើម្បីផ្តល់ថាមពលដល់យើង ។ ប៉ុន្តែប្រសិនបើយើងបរិភោគគ្លុយស៊ីតច្រើនពេក សារពាង្គកាយយើងនឹងបំប្លែងវាឱ្យទៅជាលីពីតវិញ ។

អាហារប្រភេទគ្លុយស៊ីត មានអាមីដុង ស្ករងាយ សែលុយឡូស ។ គ្លុយកូសជាស្ករងាយដែលផ្តល់ថាមពលភ្លាមៗដល់សារពាង្គកាយ ។ នៅពេលរំលាយអាហារ អាមីដុងប្លែងជាស្ករងាយ ។ ចំណែកសែលុយឡូសមិនផ្តល់ថាមពលទេ ប៉ុន្តែវាជួយក្នុងដំណើររំលាយអាហារប្រព្រឹត្តទៅបានល្អ ។

## ២. លីពីត



*ខ្លាញ់ឆ្អែត*



*ខ្លាញ់មិនឆ្អែត*

សារពាង្គកាយអាចប្រើប្រាស់លីពីតដើម្បីផលិតថាមពល ។ លីពីតផ្តល់ថាមពលពីរដងច្រើនជាងគ្លុយស៊ីត ។ម្យ៉ាងទៀត លីពីតអាចស្តុកទុកក្នុងសារពាង្គកាយបានយូរនិងជួយរក្សាកម្តៅនៅក្នុងខ្លួន ។ នៅពេលយើងបរិភោគអាហារច្រើនជាងតម្រូវការរបស់សារពាង្គកាយ អាហារលើសត្រូវបានប្លែងជាគ្លីកូសែន ហើយស្តុកទុកក្នុងថ្លើមនិងសាច់ដុំ ។ ប៉ុន្តែ សារពាង្គកាយអាចស្តុកទុក នូវបរិមាណគ្លីកូសែនបានតិចតួចប៉ុណ្ណោះ ។ ដូចនេះ ក្រៅពីការស្តុកទុកនិងប្រើប្រាស់ជាថាមពល អាហារដែលនៅសល់ត្រូវបានប្លែងជាលីពីត ហើយស្តុកទុកក្រោមស្បែកនិងជុំវិញសរីរាង្គ ។ នៅពេលយើងបរិភោគមិនគ្រប់គ្រាន់តាមតម្រូវការរបស់សារពាង្គកាយ លីពីតស្តុកទុកនេះនឹងបំបែកទៅជាថាមពលវិញ ។ ក្នុងករណីដែលយើងបរិភោគលីពីតច្រើនពេក ជួនកាលធ្វើឱ្យសរសៃឈាមស្ទះ ហើយឈាមមិនអាចធ្វើដំណើរទៅដល់បេះដូងបាន ដែលបណ្តាលឱ្យមានជំងឺបេះដូង ។

- លីពីតមួយចំនួន(ខ្លាញ់ឆ្អែត)មានប្រភពពីសត្វដូចជាខ្លាញ់សត្វ ប៊ឺរ ទឹកដោះ... ។ នៅសីតុណ្ហភាពទាប ខ្លាញ់ឆ្អែតកក ។ ដូចនេះ កាលណាបរិភោគអាហារដែលផ្ទុកខ្លាញ់ឆ្អែតច្រើនអាចបណ្តាលឱ្យស្ទះសរសៃឈាម មានសម្ពាធឈាមខ្ពស់និងមានវិបត្តិបេះដូង ។
- លីពីតផ្សេងទៀត(ខ្លាញ់មិនឆ្អែត)បានពីរុក្ខជាតិដូចជាប្រេងឆា ប្រេងសណ្តែក... ។ នៅក្នុងសីតុណ្ហភាពទាប ខ្លាញ់មិនឆ្អែតនៅតែរាវ (មិនកក) ។ ដូចនេះខ្លាញ់មិនឆ្អែតក្នុងរបបអាហារអាចបំបែកទៅជាសារធាតុងាយបាន ។

## 2.2. អាហារស្ថាបនា (សាងសង់)

អាហារសាងសង់ ផ្តល់នូវសារធាតុគីមីសំខាន់ៗ ដែលត្រូវការសម្រាប់ការលូតលាស់(ជួយក្នុងការបង្កើតកោសិកាថ្មីៗ)និងជួសជុលឡើងវិញនូវផ្នែកដែលបាត់បង់ ។ អាហារសាងសង់សំខាន់ជាប្រូតេអ៊ីន ។ សារពាង្គកាយក៏ប្រើប្រាស់ប្រូតេអ៊ីនជាប្រភពថាមពលដែរនៅពេលដែលរបបអាហារមានបរិមាណគ្លុយស៊ីតនិងលីពីតមិនគ្រប់គ្រាន់ ។



អាហារផ្ទុកប្រូតេអ៊ីន

កាលណាក្នុងអាហារគ្មានប្រូតេអ៊ីនគ្រប់គ្រាន់ យើងមិនអាចលូតលាស់បានទេ សាច់ដុំនឹងចុះខ្សោយ ។ អាហារដែលផ្ទុកប្រូតេអ៊ីនច្រើនគឺ សាច់ ត្រី មាន់ ទឹកដោះ ស៊ុត សណ្តែកសៀង ... ។

## 2.3. អាហារការពារ

អាហារការពារត្រូវការក្នុងបរិមាណតិចតួចប៉ុណ្ណោះ ដើម្បីត្រួតពិនិត្យមេតាបូលីស និងដំណើរការប្រព្រឹត្តទៅល្អនៃសកម្មភាពផ្សេងៗក្នុងសារពាង្គកាយ ។ អាហារការពារសំខាន់គឺ វីតាមីន និង អំបិលខនិជ ។

### ក. វីតាមីន

វីតាមីន មិនផ្តល់ថាមពលទេ ប៉ុន្តែវាមាននាទីសំខាន់នៅក្នុងសារពាង្គកាយ ។ ជាទូទៅ វីតាមីនធ្វើឱ្យការលូតលាស់កាន់តែប្រសើរ ជួយក្នុងដំណើរការបញ្ចេញថាមពលពីអាហារ និងតម្រូវនាទីរបស់សារពាង្គកាយ ។

យើងត្រូវការវីតាមីនក្នុងបរិមាណតិចតួចប៉ុណ្ណោះ ដើម្បីបង្ការជំងឺ និងទ្រទ្រង់សុខភាពឱ្យបានល្អ ។ វីតាមីនមានច្រើនប្រភេទ ហើយប្រភេទនីមួយៗមាននាទីខុសៗគ្នាក្នុងសារពាង្គកាយ ។ កង្វះវីតាមីនណាមួយអាចប៉ះពាល់យ៉ាងខ្លាំងដល់សុខភាព ។



ផ្លែឈើនិងបន្លែជាប្រភពវីតាមីន

ផ្លែឈើនិងបន្លែជាច្រើនដូចជា ក្រូច ល្ហុង ប៉េងប៉ោះ បន្លែបៃតង ... មានផ្ទុកវីតាមីន C ។ យើងត្រូវការវីតាមីន C ដើម្បីធ្វើឱ្យស្បែក និងអញ្ចាញធ្មេញមានសុខភាពល្អ ។ ដូចនេះកាលណាចំអិនបន្លែយូរពេក ធ្វើឱ្យបាត់បង់វីតាមីន C ។

យើងត្រូវការវីតាមីន D ដើម្បីជួយឱ្យឆ្អឹងនិងធ្មេញរឹងមាំ ។ ស្បែករបស់យើងអាចបង្កើតវីតាមីន D កាលណាយើងស្ថិតនៅក្រោមកម្ដៅថ្ងៃ ។ ប៉ុន្តែបើនៅក្រោមកម្ដៅថ្ងៃយូរពេក គឺបណ្ដាលឱ្យមានគ្រោះថ្នាក់ផងដែរ ។ យើងអាចទទួលវីតាមីន D បាន កាលណាយើងបរិភោគត្រី ទឹកដោះ ប៊ឺរ ថ្លើម ត្រី ប្រេងឆា ... ។

## ១. អំបិលខនិជ

សារពាង្គកាយត្រូវការអំបិលខនិជក្នុងបរិមាណតិចតួចបំផុត ។ អំបិលខនិជតម្រូវប្រតិកម្មគីមីជាច្រើនក្នុងសារពាង្គកាយ ។ វាមានប្រយោជន៍យ៉ាងខ្លាំងចំពោះសុខភាព ។ សារពាង្គកាយប្រើប្រាស់អំបិលខនិជទាំងនេះ ដើម្បីបង្កើតកោសិកាថ្មីៗ ចូលរួមប្រតិកម្មគីមីក្នុងកោសិកានិងដឹកនាំ $O_2$ ទៅកាន់កោសិការបស់សារពាង្គកាយ ។ ក្នុងចំណោមអំបិលខនិជទាំងអស់ កាល់ស្យូមនិងផូស្វ័រ ត្រូវបានប្រើប្រាស់ច្រើនជាងគេ សម្រាប់បំពេញនាទីផ្សេងៗក្នុងសារពាង្គកាយ ។ នាទីសំខាន់ជាងគេរបស់វា គឺចូលរួមក្នុងកំណនិងតំហែរក្សាឆ្អឹងនិងធ្មេញរឹងមាំល្អ ។

ថ្លើម តម្រងនោម លឿងស៊ុត និងបន្លែបៃតងមានផ្ទុកជាតិដែកច្រើន ។ ទឹកដោះ ប្រូម៉ាស សណ្ដែក ត្រីសមុទ្រ បន្លែបៃតង ... មានជាតិកាល់ស្យូមច្រើន ។

## 3. ទឹក

ទឹកជាសារធាតុសំខាន់ដែលរក្សាសីតុណ្ហភាពសារពាង្គកាយឱ្យនៅធម្មតា ។ មនុស្សភាគច្រើនអាចរស់បានដោយមិនបរិភោគអាហាររយៈពេល 2-3 អាទិត្យ ប៉ុន្តែគេអាចរស់បានតែ 2-3 ថ្ងៃដោយមិនផឹកទឹក ។ ក្នុងសារពាង្គកាយ មានទឹក 70% នៃទម្ងន់ខ្លួន ។ សារពាង្គកាយផ្សេងៗគ្នា ត្រូវការបរិមាណទឹកខុសៗគ្នា ដើម្បីរស់រានមានជីវិត ។ ទឹកមាននៅក្នុងនិងជុំវិញកោសិកា ក្នុងប្លាស្មានិងទឹករងៃ ។ កាកសំណល់រលាយក្នុងទឹក ចាកចេញពីសារពាង្គកាយក្រោមទម្រង់ជាទឹកនោមឬញើស ។ ដូចនេះទឹកជាធាតុបង្កសំខាន់នៃឈាម ដែលដឹកនាំអាហារទៅគ្រប់កោសិកាទាំងអស់នៃសារពាង្គកាយ ។ កាលណាគ្មានទឹក យើងមិនអាចរំលាយអាហារនិងបញ្ចេញកាកសំណល់បានឡើយ ។

សូមអភ័យទោសចំពោះ

ទំព័រទី២២៥

អត់មាន

មូលហេតុគឺ

ទឹញចំសៀវភៅខ្វះទំព័រ

សូមអគុណា

មេរៀនទី

# 2 របបអាហារនិងថាមពល

**ចប់មេរៀននេះ សិស្សអាច**

- ប្រាប់បានពីសារធាតុចិញ្ចឹមទាំង 6 នៅក្នុងអាហារ
- ពន្យល់បានពីតុល្យភាពនៃអាហារ
- ពណ៌នាពីតម្រូវការថាមពលចំពោះមនុស្ស
- ជ្រើសរើសអាហារដើម្បីសុខភាព ។

របបអាហារ មានន័យថា អាហារដែលយើងបរិភោគរៀងរាល់ថ្ងៃ ។ តាមធម្មតា របបអាហារមានអាហារប្រភេទខុសៗគ្នា ។ ប៉ុន្តែតើយើងបរិភោគអាហារច្រើនតាមចំណង់បានឬទេ ?

## 1. តុល្យភាពនៃអាហារ

ប្រភេទនិងបរិមាណអាហារដែលយើងបរិភោគមានសារៈសំខាន់ណាស់ ។ សារពាង្គកាយត្រូវការអាហារដើម្បីលូតលាស់ ធ្វើសកម្មភាពផ្សេងៗនិងមានសុខភាពល្អ ។

អាហារមានតុល្យភាព កាលណាយើងបរិភោគអាហារដែលមានផ្ទុកគ្លុយស៊ីត លីពីត ប្រូតេអ៊ីន វីតាមីន អំបិលខនិជ និងទឹក(ដែលជាសារធាតុចិញ្ចឹម) ក្នុងបរិមាណត្រឹមត្រូវ ។ អាហារតែមួយប្រភេទមិនផ្ទុកសារធាតុចិញ្ចឹមទាំងអស់នេះទេ ដូចនេះយើងត្រូវបរិភោគអាហារខុសៗគ្នាច្រើនយ៉ាង ទើបយើងទទួលបានអាហារដែលមានតុល្យភាពនិងនាំឱ្យសារពាង្គកាយមានសុខភាពមាំមួន ។

តារាងទី 1 : តម្រូវការបរិមាណសារធាតុចិញ្ចឹមបួនបែបសម្រាប់មនុស្សមានអាយុនិងភេទខុសគ្នា

| **ប្រភេទមនុស្ស** | **ប្រូតេអ៊ីន** / g | **វីតាមីន** C / mg | **ដែក** / mg | **កាល់ស្យូម** / mg |
|---|---|---|---|---|
| អាយុ 1ឆ្នាំ | 30 | 20 | 7 | 600 |
| អាយុ 6ឆ្នាំ | 43 | 20 | 10 | 600 |
| ក្មេងប្រុសអាយុ 14ឆ្នាំ | 66 | 25 | 12 | 700 |
| ក្មេងស្រីអាយុ 14ឆ្នាំ | 53 | 25 | 13 | 700 |
| បុរសអាយុ30ឆ្នាំ | 70 | 30 | 10 | 500 |
| ស្ត្រីអាយុ 30ឆ្នាំ | 55 | 30 | 12 | 500 |

## 2. របៀបវាស់ថាមពលក្នុងអាហារ

សារពាង្គកាយរស់ត្រូវការថាមពលសម្រាប់សកម្មភាពផ្សេងៗ សម្រាប់ដំណើរការនៃជីវិត ។ ថាមពលទាំងនោះ បានមកពីការបំបែកបែបគីមីនៃគ្លុយស៊ីត លីពីត និងប្រូតេអ៊ីន ។ តើគេអាចវាស់ថាមពលដែលបានមកពីអាហារយ៉ាងដូចម្ដេច ?

កាឡូរីជាឯកតារង្វាស់នៃថាមពល ។ មួយកាឡូរី (1cal) ជាបរិមាណកម្ដៅដែលបញ្ចេញដោយចំហេះអាហារ ។ កម្ដៅនេះអាចតម្លើងសីតុណ្ហភាពទឹក 1g បាន 1°C ។ អាហារភាគច្រើនផ្ទុកថាមពលច្រើនពាន់គីឡូកាឡូរី (1kcal = 1000cal) ។ អាហារមានកាឡូរីខ្ពស់ ផ្ដល់ឱ្យសារពាង្គកាយនូវថាមពលច្រើន ។ អាហារមានកាឡូរីទាប ផ្ដល់ថាមពលតិចដល់សារពាង្គកាយ ។ ក្នុងសារពាង្គកាយថាមពលត្រូវបានប្រើប្រាស់ ដើម្បីរក្សាសីតុណ្ហភាពសារពាង្គកាយក្បែរ 37°C ។ យើងប្រើប្រាស់ថាមពលសម្រាប់ធ្វើឱ្យសាច់ដុំមានចលនា សប់ឈាមទៅកាន់សរីរាង្គផ្សេងៗ ឬបញ្ជូនពត៌មានតាមសរសៃប្រសាទ ។

ស៊ូលជាខ្នាតក្នុងប្រព័ន្ធអន្តរជាតិ ប្រើសម្រាប់វាស់ថាមពល ។ រីឯកាឡូរីជាខ្នាតប្រើទូទៅសម្រាប់វាស់ថាមពលក្នុងអាហារ ។ ជាទូទៅ 1 កាឡូរី (cal) = 4.2 ស៊ូល ( J)

## 3. តម្រូវការអាហាររបស់មនុស្ស

### 3.1. ថាមពលក្នុងអាហារ

អាហារខុសៗគ្នា មានបរិមាណថាមពលដែលវាផ្ទុកខុសគ្នាដែរ ។ លីពីតមានកាឡូរីខ្ពស់ ។ ប្រូតេអ៊ីន និងគ្លុយស៊ីតមានកាឡូរីទាបជាងលីពីតនៅពេលប្រៀបធៀបម៉ាសស្មើគ្នា ។




### 3.2. តម្រូវការកាឡូរីរបស់សារពាង្គកាយ

មនុស្សខុសៗគ្នា មានរបបអាហារផ្សេងៗគ្នា ព្រោះពួកគេមានតម្រូវការខុសៗគ្នា ។ ក្មេងជំទង់ និងយុវវ័យ ត្រូវការថាមពលពេញលេញ ពីព្រោះពួកគេលូតលាស់លឿន ហើយសកម្មច្រើនជាង ។ ពួកគេត្រូវការអាហារ សម្បូរជាតិប្រូតេអ៊ីននិងគ្លុយស៊ីតច្រើន ។ មនុស្សវ័យចាស់មិនសូវសកម្មទេ ។ ដូចនេះពួកគេត្រូវការអាហារសម្បូរជាតិប្រូតេអ៊ីននិងគ្លុយស៊ីតតិចជាង ។ មនុស្សប្រើកម្លាំងកាយច្រើន ដូចជាកម្មករជាដើម ត្រូវការថាមពលច្រើន ដើម្បីបំពេញការងារធ្ងន់ៗ ។ ពួកគេត្រូវការអាហារសម្បូរ

ជាតិខ្លាញ់ស៊ិតច្រើន ។ អ្នកធ្វើការនៅក្នុងការិយាល័យមិនសូវសកម្មទេ ដូចនេះគេត្រូវការអាហារសម្បូរជាតិខ្លាញ់ស៊ិតតិច ។ ចំពោះមនុស្សភេទខុសគ្នាក៏ត្រូវការថាមពលខុសគ្នាដែរ ភាគច្រើនមនុស្សប្រុសត្រូវការថាមពលខ្ពស់ជាងមនុស្សស្រី ។

ក្រាបខាងក្រោមនេះបង្ហាញពីតម្រូវការថាមពលប្រចាំថ្ងៃតាមអាយុរបស់មនុស្សម្នាក់ៗ ។




## ៣.៣. ការប្រើប្រាស់ថាមពល

នៅពេលធ្វើសកម្មភាពដូចគ្នា មនុស្សធំឬធាត់ប្រើប្រាស់កាឡូរីច្រើនជាងមនុស្សតូច ឬស្គម ។ មនុស្សដែលមានទម្ងន់ 72kg ប្រើប្រាស់ 240kcal នៅពេលគេដើររយៈពេល 1 ម៉ោង ។ ប៉ុន្តែមនុស្សដែលមានទម្ងន់ 54kg ប្រើប្រាស់តែ 180kcal ដើម្បីដើរក្នុងរយៈពេល 1 ម៉ោងដូចគ្នា ។

តារាងទី 2 : កាឡូរីប្រើប្រាស់រយៈពេល 1 ម៉ោងសម្រាប់មនុស្សដែលមានទម្ងន់ខ្លួនខុសៗគ្នា

| ប្រភេទសកម្មភាព | ទម្ងន់ខ្លួន | | |
|---|---|---|---|
| | 54kg | 63kg | 73kg |
| ដេក | 48 | 56 | 64 |
| អង្គុយ | 72 | 84 | 96 |
| បរិភោគ | 84 | 98 | 112 |
| ឈរ | 96 | 112 | 123 |
| ដើរ | 180 | 210 | 240 |
| លេងតេនីស | 380 | 420 | 460 |
| ធាក់កង់ លឿន | 500 | 600 | 700 |
| រត់ | 700 | 850 | 1000 |

ចំពោះសកម្មភាពមួយ ដែលត្រូវការថាមពលច្រើន មនុស្សក៏ត្រូវប្រើប្រាស់កាឡូរីច្រើនសម្រាប់សកម្មភាពនោះដែរ ។ ឧទាហរណ៍មនុស្សទម្ងន់ 63kg ប្រើប្រាស់ 112kcal នៅពេលគេឈររយៈពេល 1 ម៉ោង ។ តែមនុស្សដដែលនេះប្រើប្រាស់ 420kcal ក្នុងរយៈពេល 1 ម៉ោង នៅពេលលេងតេនីស ។ ការលេងតេនីសជាសកម្មភាពខ្លាំងក្លាជាងការឈរ ។ ពិតមែនហើយ សកម្មភាពណាមួយដែលមិនសូវសកម្ម(ឈរ)ឬងាយស្រួល ថាមពលដែលត្រូវបានប្រើប្រាស់ក៏តិចដែរ ។




បើពិនិត្យពីចំនួនកាឡូរីដែលត្រូវបានប្រើប្រាស់ អាចជួយឱ្យយើងដឹងថា តើទម្ងន់ខ្លួនថយចុះឬកើនឡើង ។ *ឧទាហរណ៍* បើយើងបរិភោគអាហារមាន 2000 kcal ក្នុងមួយថ្ងៃ ។ នៅថ្ងៃដដែលនោះដែរ យើងប្រើប្រាស់តែ 1800 kcal តែប៉ុណ្ណោះ ។ ដូចនេះនៅសល់ពីការប្រើប្រាស់គឺ 200 kcal ។ កាឡូរីលើសនេះត្រូវបានបំលែងជាខ្លាញ់ ដែលស្តុកទុកនៅក្នុងសារពាង្គកាយ ។

ដើម្បីរក្សាទម្ងន់ខ្លួនឱ្យបានត្រឹមត្រូវ គឺត្រូវរក្សាតុល្យភាពរវាងកាឡូរីដែលទទួលបាននិងកាឡូរីដែលប្រើប្រាស់ ។ ប្រសិនបើចំនួនកាឡូរីដែលអ្នកទទួលបានស្មើនឹងចំនួនកាឡូរីដែលប្រើប្រាស់ នោះទម្ងន់ខ្លួននៅដដែល ។ ប្រសិនបើចំនួនកាឡូរីដែលយើងទទួលបានច្រើនជាងចំនួនកាឡូរីដែលប្រើប្រាស់ នោះទម្ងន់ខ្លួននឹងកើនឡើង ។ ប្រសិនបើកាឡូរីដែលទទួលបាន តិចជាងកាឡូរីដែលប្រើប្រាស់ នោះទម្ងន់ខ្លួននឹងថយចុះ ។

## មេរៀនសង្ខេប

- អាហារមានតុល្យភាពនៅពេលយើងបរិភោគអាហារណាដែលមានផ្ទុក (សារធាតុចិញ្ចឹម)ស្ករ ស៊ុត លីពីត ប្រូតេអ៊ីន វីតាមីន អំបិលខនិជ និងទឹកក្នុងបរិមាណត្រឹមត្រូវ ។
- កាឡូរីជាឯកតារង្វាស់នៃថាមពល ។ 1 កាឡូរី ជាថាមពលកម្ដៅដែលត្រូវការ ដើម្បីដំឡើងសីតុណ្ហភាពទឹក 1g បាន 1°C ។
- អាហារប្រភេទខុសគ្នាមានបរិមាណថាមពលដែលវាផ្ទុកក៏ខុសគ្នាដែរ ។ លីពីតមានកាឡូរីខ្ពស់ ។ ប្រូតេអ៊ីននិងស្ករស៊ុតមានកាឡូរីទាបជាងលីពីតនៅពេលប្រៀបធៀបម៉ាសស្មើគ្នា ។
- មនុស្សខុសគ្នា មានរបបអាហារផ្សេងៗគ្នា ព្រោះពួកគេមានតម្រូវការខុសគ្នា ដោយអាស្រ័យទៅនឹងអាយុ ភេទ នាទីការងារ... ។
- ដើម្បីរក្សាទម្ងន់ខ្លួនឱ្យបានត្រឹមត្រូវ យើងត្រូវរក្សាតុល្យភាពរវាងកាឡូរីដែលទទួលបាននិងកាឡូរីដែលប្រើប្រាស់ ។

## ? សំណួរ

1. ដូចម្ដេចហៅថាតុល្យភាពនៃអាហារ ?
2. តើកាឡូរីជាអ្វី ?
3. តើអាហារទាំងអស់មានបរិមាណថាមពលដូចគ្នាទេ ?
4. បើធៀបម៉ាសស្មើគ្នាតើអាហារប្រភេទណាមានកាឡូរីខ្ពស់ ?

## ប្រតិបត្តិ

**តើរបបអាហាររបស់អ្នកគ្រប់គ្រាន់ឬទេ ?**

1. ចូរធ្វើរបាយការណ៍ពីរបបអាហារដែលអ្នកបរិភោគពីម្សិលមិញ ។
2. ដោយមើលតារាងទី3 ចូរអ្នកកត់ត្រាថាមពលរបស់ប្រូតេអ៊ីននិងខ្លាញ់ក្នុងអាហារដែលអ្នកបានបរិភោគ ។
3. អ្នកវិទ្យាសាស្ត្រប៉ាន់ប្រមាណថាក្មេងប្រុសអាយុ 15-19ឆ្នាំត្រូវការថាមពលប្រហែល 270kJ ក្នុង 1kg នៃទម្ងន់ខ្លួន ។ ក្មេងស្រីអាយុ 15-19ឆ្នាំត្រូវការថាមពលប្រហែល 200 kJ ។ ចូរគណនាថាមពលដែលត្រូវការក្នុងមួយថ្ងៃដោយប្រើថាមពលក្នុងតារាងទី 3 (ទំព័រ 231) ។

**ទម្ងន់ (Kg)x ថាមពលត្រូវការជាមធ្យម = kJ / 1 ថ្ងៃ**

## ✍ វិភាគ

1. ប្រៀបធៀបថាមពលដែលទទួលបាននិងថាមពលក្នុងតារាងទី 3 ។
2. សិស្សនៅមធ្យមសិក្សាកំពុងលូតលាស់ខ្លាំង ដូចនេះពួកគេត្រូវការប្រូតេអ៊ីនច្រើនសម្រាប់បង្កើតកោសិកាថ្មី ។ តើអាហារប្រភេទណាសម្បូរប្រូតេអ៊ីនច្រើនជាងគេ ?

### តារាងទី 3 : ថាមពលមានក្នុងអាហារ

| អាហារ | បរិមាណ | ថាមពល (kJ) | ប្រូតេអ៊ីន (g) | ខ្លាញ់ (g) |
|---|---|---|---|---|
| បាយឆ្អិន | 1 ចាន | 2800 | 4 | 0 |
| បាយឆា | 1 ចាន | 3100 | 4 | 10 |
| គុយទាវ | 1 ចាន | 440 | 7 | 3 |
| នំប៉័ង | 1 ដុំ | 630 | 5 | 2 |
| សាច់ : ជ្រូក , គោ | 50g | 700 | 18 | 10 |
| សាច់មាន់ | 50g | 600 | 12 | 6 |
| ត្រីចៀន | 50g | 200 | 12 | 2 |
| ស៊ុតចៀន | 1 | 415 | 6 | 7 |
| ស៊ុតស្ងោរ | 1 | 350 | 6 | 6 |
| បន្លែ : ស្លឹកបៃតង ប៉េងប៉ោះ | 1 ពែងកាផែ | 100 | 1 | 0 |
| សណ្តែក | 1 ពែងកាផែ | 140 | 3 | 0 |
| ត្រសក់ | 1 ពែងកាផែ | 50 | តិច | 0 |
| បាយស្រូប | 1 ចាន | 360 | 23 | 10 |
| ផ្លែឈើ ល្ហុង ម្នាស់ | 1 ចាន | 300 | 1 | 0 |
| ទឹកសណ្តែក | 1 កែវ | 400 | 9 | 5 |
| កូកាកូឡា | 1 កំប៉ុង | 660 | 0 | 0 |
| ទឹកក្រូចឆ្មារ + ស្ករ | 1 កែវ | 200 | 1 | 0 |
| កាផែ | 1 ពែង | 200 | 0 | 0 |
| ស៊ុបសាច់ | 1 ចាន | 700 | 18 | 7 |
| ស៊ុបត្រី | 1 ចាន | 200 | 12 | 2 |

# 3 អាហារមានសុវត្ថិភាព

**ចប់មេរៀននេះ សិស្សអាច**

- ❑ ពណ៌នាពីវិធីមួយចំនួនដែលធ្វើឱ្យអាហារមានសុវត្ថិភាព
- ❑ រៀបរាប់ពីការថែរក្សាសុខភាពគុមារ
- ❑ បណ្តុះគំនិតឱ្យចេះអនាម័យក្នុងការរស់នៅប្រចាំថ្ងៃ ។

ដើម្បីជីវិតរស់នៅប្រកបដោយសុខុមាលភាព មនុស្សត្រូវការបរិភោគអាហារ ដែលមានអនាម័យជាប្រចាំ ។ អាហារជាតម្រូវការចាំបាច់សម្រាប់ឱ្យមនុស្សរស់រានមានជីវិត ដែលក្នុងនោះមានអាហារថាមពល អាហារសាងសង់ និងអាហារការពារ ។

## 1. អនាម័យអាហារ

អាហារស្អាតហើយថ្មីស្រស់ៗមានសារៈសំខាន់ណាស់សម្រាប់សុខភាព ។ អាហារដែលមានផ្ទុកមេរោគ អាចបន្ថយគុណភាពនៃសារធាតុចិញ្ចឹមក្នុងអាហារនោះ និងបង្កឱ្យមានជំងឺទៀតផង ។ ជំងឺបង្កឡើងដោយអាហារនិងទឹកមិនស្អាតមាន ជំងឺរាក គ្រុនពោះវៀន អាសន្នរោគ និងថ្លើម ។ ដើម្បីបង្ការជំងឺខាងលើនេះ និងជួយកាត់បន្ថយការខ្ជះខ្ជាយអាហារ យើងត្រូវអនុវត្តដូចតទៅ :

- បោះចោលអាហារដែលជូរ ផ្អូម ឬរុយរោម
- លាងសម្អាតដៃឱ្យបានស្អាត មុននឹងចាប់កាន់អាហារមកបរិភោគ
- ចំអិនអាហារឱ្យបានឆ្អិនល្អ ហើយបរិភោគភ្លាម
- ចៀសវាងកុំភ្លក ឬកណ្តាសក្បែរអាហារ ឬកណ្តាសដាក់អាហារ



*អាហារគ្រឹងគ្របឱ្យបានជិត*

- កុំយកដៃទៅប៉ះ ឬស្ទាបសក់ក្បាល មាត់ ច្រមុះ ឬអ្វីផ្សេងទៀតដែលទំនងជាកខ្វក់ ក្នុងពេលកំពុងរៀបចំចំអិនម្ហូបអាហារ
- គ្របអាហារឱ្យជិត ដើម្បីការពារកុំឱ្យសត្វរុយ ឬសត្វល្អិតផ្សេងៗទុំលើ និងធូលីហុយចូល

- កុំបរិភោគអាហារកំប៉ុងណាដែលសំបកកំប៉ុងចាស់ខ្លាំងពេក ឬកំពិតខ្លាំងពេក ឬហួសកាលបរិច្ឆេទ
- អាហារកំប៉ុង ត្រូវបរិភោគអាហារនោះភ្លាមៗ ឬផ្ទេរដាក់ក្នុងចានស្អាតដែលមានគម្របបិទជិតល្អ ហើយដាក់នៅកន្លែងត្រជាក់ ។ អាហារមិនត្រូវទុកក្នុងកំប៉ុងដែលបើកហើយនោះទេ ។
- ដាក់អាហារចំអិនរួចដោយឡែកពីអាហារឆៅ
- លាងសម្អាតផ្លែឈើនិងបន្លែដែលត្រូវបរិភោគឆៅ ឱ្យស្អាតត្រឹមត្រូវជាមួយទឹកស្អាត ។ ផ្លែឈើនិងបន្លែដែលត្រូវបរិភោគឆៅ ត្រូវតែលាងសម្អាតមុនបន្លែផ្សេងទៀត ដែលចាំបាច់ត្រូវយកទៅចំអិន
- ទឹកចំអិននិង លាងសម្អាតអាហារ ជាទឹកសាបស្អាតមានសុវត្ថិភាព
- ត្រី សាច់ត្រូវចំអិនឱ្យឆ្អិនល្អមិនត្រូវបរិភោគសាច់ឬត្រីឆៅទេ ។ ផ្អក ឬប្រហុកក៏ត្រូវចំអិនឱ្យឆ្អិនល្អសម្រាប់បរិភោគ
- ចំអិនអាហាររួចហើយ បើទុកលើសពីពីរម៉ោងត្រូវកម្តៅឡើងវិញ
- លាងសម្អាតសម្ភារៈសម្រាប់ចំអិនអាហារនិងបរិភោគឱ្យបានស្អាតល្អនិងទុកដាក់ឱ្យមានគម្របត្រឹមត្រូវ បន្ទាប់ពីប្រើប្រាស់រួច ។
- សម្អាតផ្ទះបាយឱ្យស្អាតជានិច្ច ដើម្បីចៀសវាងឬការពារកុំឱ្យមានសត្វល្អិត និងរុយ ។

## 2. ការថែរក្សាសុខភាពកុមារ

កុមារត្រូវតែអនុវត្តអនាម័យឱ្យបានខ្ជាប់ខ្ជួន ដើម្បីធានាសុខភាពឱ្យបានល្អ ក្នុងការរស់នៅប្រចាំថ្ងៃ ។

### 2.1. ការផ្តល់អាហារល្អ



មិនត្រូវបរិភោគអាហារកំប៉ុងផុតកាលបរិច្ឆេទ

អាហារល្អ គឺសំដៅលើអាហារប្រកបដោយគុណភាពនិងអនាម័យល្អ :

- ចំអិនអាហារឱ្យបានឆ្អិនល្អ ជាពិសេសសាច់និងស៊ុតបក្សី
- ផ្តល់អាហារមានជាតិអ៊ីយ៉ូត ជាតិដែក វីតាមីនអា និងវីតាមីនផ្សេងទៀតដែលមាននៅក្នុងប្រភេទអាហារទាំងបីក្រុម
- មិនផ្តល់អាហារមានជាតិគីមីពុល អាហារផ្អូម ឬខូចគុណភាព

- ចៀសវាងអាហារកំប៉ុង ឬកញ្ចប់ដែលផុតនិងជិតផុតកំណត់កាលបរិច្ឆេទប្រើប្រាស់
- ផ្តល់អាហារដែលទុកដាក់ត្រឹមត្រូវ មានគម្របបិទជិត
- ផ្តល់បន្លែ ផ្លែឈើថ្មីស្រស់ៗដែលគ្មានជាតិគីមីពុល
- ចៀសវាងបរិភោគសាច់បក្សីឈឺ ឬងាប់
- ផ្តល់អាហារដល់កុមារឱ្យបានត្រឹមត្រូវល្អ។

## 2.2. អនាម័យខ្លួនប្រាណ




*របៀបលាងសំអាតដៃឱ្យបានត្រឹមត្រូវ*

កុមារត្រូវដឹងថា លទ្ធផលនៃការមិនសំអាតខ្លួនដូចជា នាំឱ្យខ្លួនប្រាណកខ្វក់មានជំងឺ។ ដូចនេះ កុមារត្រូវតែ លាងដៃនឹងសាប៊ូ ៖

- ក្រោយពេលចេញពីបង្គន់ មុនពេលនិងក្រោយពេលញ៉ាំអាហារ មុនពេលកាន់ ឬញ៉ាំនំចំណី ក្រោយពេលប៉ះពាល់សំរាម នៅពេលដៃកខ្វក់
- មុនពេលរៀបចំអាហារ
- ត្រូវកាត់ក្រចកដៃ ក្រចកជើងឱ្យខ្លី(ភាពកខ្វក់មិនអាចជាប់នឹងក្រចក)
- លាងសម្អាតមុខនឹងសាប៊ូរៀងរាល់ថ្ងៃ
- ដុសសម្អាតធ្មេញយ៉ាងតិចណាស់ 2ដងក្នុងមួយថ្ងៃ មុនពេលញ៉ាំអាហារព្រឹកនិងមុនចូលគេង
- លាងសម្អាតមាត់រៀងរាល់ពេលញ៉ាំអាហាររួច
- កក់សក់នឹងសាប៊ូឱ្យបានញឹកញាប់ ហើយសិតសក់ឱ្យមានរបៀបរៀបរយ
- ត្រូវប្រើបង្គន់អនាម័យ
- សំលៀកបំពាក់ត្រូវឱ្យបានស្អាត ហើយទុកដាក់ឱ្យមានរបៀបរៀបរយល្អ។

## ២.៣. សុវត្ថិភាពលំនៅឋាន

- ទ្វារ បង្អួចត្រូវបើកចំហឱ្យធំទូលាយ ដើម្បីឱ្យមានពន្លឺនិងខ្យល់ចេញចូលបានគ្រប់គ្រាន់
- ត្រូវសម្អាត
  - បរិវេណផ្ទះ (ក្រោមផ្ទះ មុខផ្ទះ ក្រោយផ្ទះ ...)
  - បន្ទប់ដេក (រៀបចំគ្រែ មុង ភួយ ខ្នើយ... ឱ្យស្អាតនិងរៀបរយ)
  - ផ្ទះបាយ (ទូចាន ទូដាក់ម្ហូប ឆ្នាំង ស្លាបព្រា ...) បន្ទប់ទឹក បង្គន់ (មានទឹកគ្រប់គ្រាន់ សាប៊ូ ច្រាសសម្រាប់ប្រើប្រាស់ ...)
- ប្រើប្រាស់បង្គន់ដោយចាក់ទឹកមុននិងក្រោយបន្ទោរបង់
- លប់បំបាត់ជម្រកមូស (ជ្រាំ ព្រៃក្បែរផ្ទះ សំបកកំប៉ុង សំបកកង់ឡានដែលមានទឹកដក់)
- ជីកកប់សំរាមឱ្យបានជិតត្រឹមត្រូវ
- បង្គន់ គំនរសំរាមឬរណ្តៅសំរាម ត្រូវដាក់ឱ្យឆ្ងាយពីប្រភពទឹកស្អាតដែលប្រើប្រាស់ ។

### មេរៀនសង្ខេប

- មនុស្សម្នាក់ៗត្រូវការអាហារ ។ តែយ៉ាងណាក៏ដោយមានមនុស្សខ្លះមានប្រតិកម្មតបទៅនឹងអាហារមួយចំនួន ។ មនុស្សខ្លះធ្លាក់ខ្លួនឈឺ ក្រោយពេលបរិភោគអាហារឬផឹកភេសជ្ជៈដែលមានផ្ទុកមេរោគ ។ ដើម្បីបង្ការបញ្ហានេះ អ្នកត្រូវបរិភោគអាហារមានសុវត្ថិភាព ។
- កុមារត្រូវអនុវត្តអនាម័យឱ្យបានខ្ជាប់ខ្ជួន ដើម្បីធានាសុខភាពឱ្យបានល្អក្នុងការរស់នៅប្រចាំថ្ងៃ ដូចជា ការផ្តល់អាហារល្អ អនាម័យខ្លួនប្រាណនិងសុវត្ថិភាពលំនៅឋាន ។

### ? សំណួរ

1. ដើម្បីឱ្យមានសុខភាពល្អ តើអ្នកត្រូវធ្វើដូចម្តេច?
2. តើធ្វើដូចម្តេចដើម្បីឱ្យកុមារមានសុខភាពល្អ?

## ? សំណួរបញ្ចប់ជំពូកទី៥

**I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់នៅខាងមុខចម្លើយដែលត្រឹមត្រូវ**

1. សារពាង្គកាយទាញយកថាមពលចេញពី

☐ ក. គ្លុយស៊ីត ☐ ខ. ទឹក ☐ គ. វីតាមីន ☐ ឃ. អំបិលខនិជ ។

2. សារធាតុដែលទទួលបានពីអាហារ តម្រូវនាទីរបស់សារពាង្គកាយ ប៉ុន្តែមិនផ្តត់ផ្គង់ថាមពលជា

☐ ក. ប្រូតេអ៊ីន ☐ ខ. គ្លុយស៊ីត ☐ គ. វីតាមីន ☐ ឃ. លីពីត ។

3. សារធាតុចិញ្ចឹមពីរប្រភេទដែលសារពាង្គកាយប្រើប្រាស់ជាថាមពល គឺ

☐ ក. គ្លុយស៊ីតនិងលីពីត ☐ ខ. គ្លុយស៊ីតនិងប្រូតេអ៊ីន

☐ គ. លីពីតនិងប្រូតេអ៊ីន ☐ ឃ. ប្រូតេអ៊ីននិងវីតាមីន ។

4. ឯកតានៃរង្វាស់ថាមពលជា

☐ ក. $m^2$ ☐ ខ. cal ☐ គ. Kg ☐ ឃ. ml ។

**II. ចូរបំពេញចន្លោះនៃឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ**

1. គ្លុយស៊ីតមានបីប្រភេទ គឺ .......... ស្ករងាយនិង .............. ។
2. សារធាតុចិញ្ចឹមដែលផ្តល់ថាមពលច្រើនជាងគេជា .................... ។
3. អាហារការពារសំខាន់មាន .............. និង ................ ។
4. គ្លុយស៊ីត លីពីត ប្រូតេអ៊ីន វីតាមីន អំបិលខនិជនិងទឹកជា ............ ។
5. នៅពេលយើងបរិភោគអាហារដែលមានផ្ទុកគ្រប់ ...... ក្នុងបរិមាណត្រឹមត្រូវហៅថា ....... ។

**III. ចូរឆ្លើយនឹងសំណួរខាងក្រោម**

1. តើសារធាតុចិញ្ចឹមជាអ្វី ? ចូរឱ្យឧទាហរណ៍ ។
2. សម្រាប់ការលូតលាស់និងជួសជុល តើសារពាង្គកាយប្រើប្រាស់សារធាតុចិញ្ចឹមអ្វី ?
3. ហេតុអ្វីបានជាទឹកមានសារៈសំខាន់សម្រាប់សារពាង្គកាយ ?
4. ហេតុអ្វីបានជាសារពាង្គកាយត្រូវការរបបអាហារដែលមានគ្លុយស៊ីតខ្ពស់ ?
5. ហេតុអ្វីបានជាខ្លាញ់ជាផ្នែកសំខាន់របស់សារពាង្គកាយ ?
6. តើតុល្យភាពនៃអាហារជាអ្វី ?
7. ហេតុអ្វីបានជាតុល្យភាពនៃអាហារមានសារៈសំខាន់សម្រាប់សារពាង្គកាយ ?

# ជំពូកទី 6 គ្រឿងញៀន



គ្រឿងញៀនមានច្រើនប្រភេទណាស់ដូចជា អាភៀន កញ្ឆាជាដើម ។ នៅពេលយើងនិយាយពីគ្រឿងញៀន យើងតែងគិតដល់គ្រឿងញៀនខុសច្បាប់ ប៉ុន្តែមិនមែនគ្រឿងញៀនទាំងអស់សុទ្ធតែខុសច្បាប់ទេដូចជា គ្រឿងស្រវឹង នីកូទីន(ក្នុងថ្នាំជក់) ស្លា ជាតិកាផេអ៊ីនក្នុងកាផេ តែ និងភេសជ្ជៈផ្សេងៗមានកូកាកូឡា ឬភេសជ្ជៈផ្តល់ថាមពលក៏អាចបណ្តាលឱ្យញៀន ប្រសិនបើយើងប្រើប្រាស់វាដោយបំពាន ។ ជាទូទៅ គ្រឿងញៀនជាសារធាតុគីមី ដែលមានផលប៉ះពាល់ចំពោះមុខងារទូទៅនៃសរីរាង្គកាយនិងខួរក្បាល ។ អ្នកប្រើប្រាស់បំពានលើគ្រឿងញៀនជាទូទៅមិនអាចបញ្ឈប់បានឡើយ ។

ដូចនេះ តើគ្រឿងញៀនមានឥទ្ធិពលដល់សារពាង្គកាយដូចម្តេចខ្លះ ?

មេរៀនទី

# 1 គ្រឿងញៀន

**ចប់មេរៀននេះ សិស្សអាច**

- ប្រាប់ពីប្រភេទគ្រឿងញៀនផ្សេងៗ
- រៀបរាប់ពីវិធីប្រើប្រាស់កញ្ឆានិងអាភៀនក្នុងជីវភាពជាក់ស្តែង
- ពណ៌នាពីលក្ខណៈពិសេសរបស់មនុស្សញៀន ។

មនុស្សភាគច្រើនមិនផឹកស្រា មិនជក់បារី ហើយក៏មិនប្រើប្រាស់អាភៀន ឬកញ្ឆាដែរ ។ តែទោះជាយ៉ាងណាក៏ដោយ យើងគ្រប់គ្នាត្រូវតែដឹងពីផលអាក្រក់របស់គ្រឿងញៀនចំពោះសុខភាព ។ គ្រឿងញៀនមានប្រភពពីធម្មជាតិថ្នាំជក់ កញ្ឆា អាភៀន និងជាផលិតផលសំយោគដូចជា យ៉ាម៉ា អិចស្តាស៊ី កាវបិត ... ។

## 1. ប្រភេទផ្សេងៗនៃគ្រឿងញៀន

គ្រឿងញៀនមានច្រើនប្រភេទ ។ គេចែកគ្រឿងញៀនជាក្រុមអាស្រ័យទៅលើឥទ្ធិពលរបស់វា ។

### 1.1. ថ្នាំលើកកម្លាំង

យ៉ាម៉ា (ធ្វើឱ្យមានកម្លាំងដូចសេះ)ជាថ្នាំសេះ ឬថ្នាំឆ្កួត កូកាអ៊ីន នីកូទីន(ក្នុងបារី) កាដេអ៊ីន (កាហ្វេ តែ កូកាកូឡា ភេសជ្ជៈផ្តល់ថាមពលនានា) ស្លា អិចស្តាស៊ី (ថ្នាំធ្វើឱ្យមានការស្រើបស្រាល) ។

### 1.2. ថ្នាំបន្ថយការធុញថប់និងបំបាត់ការឈឺចាប់

- គ្រឿងស្រវឹង
- ថ្នាំរំងាប់ចិត្ត ថ្នាំងងុយដេក ថ្នាំបំបាត់ការឈឺចាប់
- ហេរ៉ូអ៊ីននិងថ្នាំមានជាតិអាភៀនផ្សេងៗទៀត
- កញ្ឆា ថ្នាំស្រវឹង (ធ្វើឱ្យមានអារម្មណ៍រវើរវាយ)
- កាវបិត (ធ្វើឱ្យមានអារម្មណ៍រវើរវាយ)\

## 2. កញ្ឆា



ដើមកញ្ឆា

កញ្ឆាជារុក្ខជាតិមួយប្រភេទដែលមានពណ៌ខៀវស្រងាត់ដូចជាថ្នាំជក់ ។ ជួនកាលវាជាសារធាតុពណ៌ត្នោតដែលកើតឡើងពីផ្កាស្ងួតនិងស្លឹកនៃរុក្ខជាតិកញ្ឆា ។ ដើមកញ្ឆាត្រូវបានគេផលិតឱ្យទៅជាម្សៅ ឬភាបឱ្យកក ។ តាមបែបបច្ចេកវិទ្យា គេអាចបង្កាត់ពូជកញ្ឆាដោយបង្កើតបានពូជប្លែកៗ ដែលមានអានុភាព ហើយមានគ្រោះថ្នាក់ខ្លាំងជាងកញ្ឆាដុះតាមបែបធម្មជាតិ ។

អ្នកប្រើប្រាស់ភាគច្រើន ជក់កញ្ឆាក្រោមរូបរាងជាបារីមូដៃ ខ្លះទៀតប្រើខ្សៀ ។ ជាទូទៅគេប្រើប្រាស់កញ្ឆាលាយជាមួយថ្នាំញៀនផ្សេងទៀតដូចជា កូកាអ៊ីនជាដើម ។ ប៉ុន្តែជួនកាល គេយកវាទៅឆុងជាមួយតែ ឬលាយជាមួយអាហារ នំ ឬភេសជ្ជៈ ។

## 3. ហេរ៉ូអ៊ីន (ក្រុមអាភៀន)



ផ្លែអាភៀន

ហេរ៉ូអ៊ីន ជាគ្រឿងញៀនខុសច្បាប់ ។ វាជាថ្នាំបំបាត់ការឈឺចាប់ ។ គេប្រើហេរ៉ូអ៊ីនច្រើនជាងគ្រឿងញៀនផ្សេងៗទៀត ព្រោះវាមានឥទ្ធិពលឆាប់រហ័សជាងគេក្នុងចំណោមថ្នាំមានជាតិអាភៀន ។ គេកែច្នៃហេរ៉ូអ៊ីនចេញពីម័រហ្វីន (សារធាតុក្នុងធម្មជាតិដែលគេចម្រាញ់ចេញពីរុក្ខជាតិអាភៀន) ។ ហេរ៉ូអ៊ីនជាម្សៅពណ៌ស ។ នៅលើទីផ្សារភាគច្រើន ឧក្រិដ្ឋជនបានលាយហេរ៉ូអ៊ីនជាមួយគ្រឿងញៀន ឬសារធាតុផ្សេងទៀតដូចជា ស្ករ ម្សៅ ម្សៅទឹកដោះគោ ឬថ្នាំគីនីន ។

## 4. កាវ



កាវ

កាវជាផលិតផលដែលគេអាចទិញបានដូចជាថ្នាំលាបជ័រកាវនិងសារធាតុគីមីសម្រាប់ប្រើប្រាស់ផ្សេងៗទៀត ។ សារធាតុនេះអាចទិញបានដោយស្របច្បាប់ ប៉ុន្តែការប្រើប្រាស់ខុសឆ្គង គឺមិនស្របច្បាប់ ។

## 5. ការញៀនគ្រឿងញៀន

មនុស្សជក់កញ្ឆាមានអារម្មណ៍ច្របូកច្របល់និងធ្វើអ្វីប្រកបដោយគ្រោះថ្នាក់ បញ្ចេញភាពគឃ្លើនសាហាវដូចជា ឆក់ ឬប្លន់ លោតពីលើដំបូលអាគារខ្ពស់ៗជាដើម ។

នៅពេលមនុស្សប្រើអាភៀនលើកដំបូង គេនឹងមានអារម្មណ៍រីករាយ ។ ប៉ុន្តែមួយរយៈក្រោយគេក្លាយជារសាប់រសល់ ។ ដូចនេះ គេត្រូវប្រើអាភៀនច្រើនជាងលើកដំបូងទើបមានអារម្មណ៍រីករាយ ។ ក្រោយមកទៀត គេមិនអាចរស់នៅដោយគ្មានអាភៀនបានទេ ។



*មនុស្សប្រើស៊ីរាំងចាក់គ្រឿងញៀន*



*មនុស្សជក់អាភៀន*

មនុស្សដែលប្រើប្រាស់គ្រឿងញៀន ចេះតែចង់ប្រើបរិមាណថ្នាំញៀនកាន់តែច្រើនឡើងៗ ដើម្បីឱ្យមានអារម្មណ៍ស្កប់ស្កល់ ។ មួយរយៈក្រោយមក គេនឹងក្លាយទៅជាមនុស្សញៀន ។ មនុស្សញៀនជាមនុស្សដែលរស់នៅដោយពឹងផ្អែកតែលើថ្នាំញៀន ។ មនុស្សញៀនមិនអាចបំពេញការងារបានត្រឹមត្រូវទេ ប្រសិនបើគេប្រើគ្រឿងញៀនមិនបានទៀងទាត់ ។ មនុស្សប្រើគ្រឿងញៀនភាគច្រើនបំផុតផ្លាស់ប្តូរពីការជក់ទៅជាការចាក់ ដែលបង្កឡើងនូវគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរចំពោះការរីករាលដាលនៃជំងឺអេដស៍ តាមរយៈការប្រើប្រាស់ស៊ីរាំង មុលរួមគ្នា ។ ជំងឺថ្លើមប្រភេទ B និង C មានការរីករាលដាលធ្ងន់ធ្ងរ ហើយងាយឆ្លងតាមរបៀបនេះ ។

មនុស្សបាត់បង់បម្រុងប្រយ័ត្ននិងបណ្តាលឱ្យមានគ្រោះថ្នាក់ជាច្រើនដោយគ្រាន់តែផឹកស្រាបន្តិច ។ បើគេផឹកបន្តច្រើនទៀត គេនឹងវិលមុខ ហើយស្រវាំងភ្នែកនិយាយមិនច្បាស់ គិតមិនបានហ្មត់ចត់និងបង្កើតជម្លោះជាមួយអ្នកដទៃ ។ បើផឹកបន្ថែមទៀតគេនឹងសន្លប់ឬស្លាប់ ។ នៅពេលអ្នកជក់បារីស្រូបចូលជាតិនីកូទីនចំនួនតិច ក៏ធ្វើឱ្យអារម្មណ៍របស់អ្នកសប្បាយរីករាយ ហើយចង់ជក់

ថែមទៀត។ អ្នកជក់អាចក្លាយជាអ្នកញៀនជាតិនីកូទីន។ ពួកគេនិងទទួលរងការលំបាកទាំងកាយ ទាំងចិត្តនៅពេលពួកគេលះបង់ការជក់បារីដូចជា ឆាប់ខឹង ឈឺក្បាល ពិបាកដេក។

ក្រៅពីការញៀនថ្នាំខាងលើ មនុស្សញៀនផលិតផលមួយចំនួនទៀតដែរ ដូចជាជ័រកាវ ឬថ្នាំលាបជាដើម។ ចំពោះជ័រកាវ ឬថ្នាំលាបប្រសិនបើមនុស្សប្រើប្រាស់ត្រឹមត្រូវ វាមិនផ្តល់ទុក្ខទោសទេ។ ប៉ុន្តែបើមនុស្សហិតសារធាតុគីមីទាំងនេះ ឧស្ម័នពុលអាចចូលទៅក្នុងឈាម ហើយប៉ះពាល់ដល់ខួរក្បាល។ មនុស្សដែលហិតជ័រកាវ ឬថ្នាំលាបមានអារម្មណ៍អណ្តែតអណ្តូងនិងមមើមមាយ។



*ក្មេងហិតកាវ*

## មេរៀនសង្ខេប

- គេចែកគ្រឿងញៀនជាក្រុម : ថ្នាំលើកកម្លាំង (កូកាអ៊ីន កាថែអ៊ីន ...) ថ្នាំបំបាត់ការធុញថប់ និងបំបាត់ការឈឺចាប់ (អាភៀន កញ្ឆា ...)។
- អ្នកប្រើប្រាស់ភាគច្រើនជក់កញ្ឆាក្រោមរូបរាងជាបារីមូលដៃ ឬប្រើខ្សៀ។ ជួនកាលគេលាយកញ្ឆាជាមួយថ្នាំញៀនផ្សេងៗទៀត ឬឆុងជាមួយតែឬលាយជាមួយអាហារ នំឬភេសជ្ជៈ។ ហេរ៉ូអ៊ីនជាម្សៅពណ៌ស។ គេលាយហេរ៉ូអ៊ីនជាមួយគ្រឿងញៀន ឬជាមួយស្ករ ម្សៅទឹកដោះគោ ឬថ្នាំគីនីន។
- មនុស្សញៀនជាមនុស្សដែលរស់នៅដោយពឹងផ្អែកតែលើថ្នាំញៀន។ មនុស្សញៀនមិនអាចបំពេញការងារបានត្រឹមត្រូវទេ ប្រសិនបើគេប្រើគ្រឿងញៀនមិនបានទៀងទាត់។

## សំណួរ

1. តើគ្រឿងញៀនជាអ្វី ?
2. តើមានប្រភេទគ្រឿងញៀនអ្វីខ្លះ ?
3. តើម័រហ្វីនជាអ្វី ?
4. តើមនុស្សញៀនមានលក្ខណៈដូចម្តេចដែរ ?

មេរៀនទី

# 2 ឥទ្ធិពលនៃគ្រឿងញៀន

**ចប់មេរៀននេះ សិស្សអាច**

- ❑ រៀបរាប់ពីផលអាក្រក់នៃគ្រឿងញៀនដល់សតិបញ្ញានិងរាងកាយ
- ❑ បង្ហាញពីផលអាក្រក់នៃគ្រឿងញៀនចំពោះសង្គម
- ❑ ពណ៌នាពីឥរិយាបថនៃអ្នកញៀនគ្រឿងញៀន
- ❑ ជៀសវាងការប្រើប្រាស់គ្រឿងញៀន ។

រាល់គ្រឿងញៀនខុសច្បាប់ទាំងអស់ មានផលប៉ះពាល់ភ្លាមៗ ចំពោះសារពាង្គកាយនិងអារម្មណ៍ ។ ការចាប់ផ្ដើមប្រើប្រាស់លើកដំបូង តែងតែទទួលបានផលវិជ្ជមាន តែការប្រើរយៈពេលយូរទទួលបានផលអវិជ្ជមាន ។ អ្នកប្រើប្រាស់គ្រឿងញៀនមិនអាចបញ្ឈប់ដោយងាយបានឡើយ ។ ភាគច្រើនបំផុតនៃគ្រឿងញៀនផ្ដល់ផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់អ្នកប្រើប្រាស់ ក្រុមគ្រួសារ សហគមន៍ និងសង្គមទាំងមូល ។

## 1. ផលអាក្រក់ដល់សតិបញ្ញា



*រោគសញ្ញាញៀនហេរ៉ូអ៊ីន រយៈពេល 2-3 ម៉ោងក្រោយ*

មនុស្សញៀនគ្រឿងញៀនបង្កឱ្យមានវិបត្តិសុខភាពយ៉ាងធ្ងន់ធ្ងរ ។ ការពុលស្រវឹងនៃគ្រឿងញៀន ប៉ះពាល់ផ្លូវចិត្តជាច្រើនដូចជាមិនងងុយដេក សតិស្មារតីមិនល្អ មើលឃើញ ឬស្ដាប់ឮអ្វីមិនមែនជាការពិត សង្ស័យផ្ដេសផ្ដាស មិនទុកចិត្តគេ បាត់បង់ការចងចាំ ស្លន់ស្លោ មួម៉ៅជាដើម ។ ការថយចុះ ឬបាត់បង់ការចងចាំ អាចបន្តរហូតដល់ 2 ឬ 3 ថ្ងៃបន្ទាប់ពី ការស្រវឹងគ្រឿងញៀនបានសាបរលាប ។

## 2. ផលអាក្រក់ដល់រាងកាយ

ការប្រើគ្រឿងញៀននាំមកនូវវិបត្តិធ្ងន់ធ្ងរដល់រាងកាយ ប្រព័ន្ធស៊ាំត្រូវបាត់បង់ ។ វិធីប្រើដោយចាក់គ្រឿងញៀនតាមសរសៃឈាម ធ្វើឱ្យអ្នកប្រើប្រាស់ឆ្លងមេរោគដែលបណ្ដាលឱ្យមានជំងឺមួយចំនួន

ដូចជា ជំងឺរលាកថ្លើមប្រភេទ A ប្រភេទ B និងប្រភេទ C ជំងឺអេដស៍ ជំងឺបូស ការចុះស្គម រោគមហារីក ដាច់សរសៃឈាមក្នុងខួរក្បាល ជំងឺបេះដូង និងស្លាប់ ។

ពេលគ្រឿងញៀនជ្រាបចូលដល់ក្នុងខ្លួន សរីរាង្គដែលទទួលរងគ្រោះថ្នាក់គឺថ្លើម បេះដូង តម្រងនោម សួតដែលត្រូវបានខូចខាតដោយសារជាតិពុលនិងជំងឺឆ្លងផ្សេងៗដូចជា រលាកច្រមុះ ផ្លូវដង្ហើម ជំងឺបេះដូងរីក រលាកទងសួត មហារីកសួត ហឺត រលាកថ្លើម តម្រងនោម... ។ ធ្មេញនិងជើងធ្មេញត្រូវឈឺចាប់ ហើយនាំឱ្យជ្រុះធ្មេញ ដង្កូវស៊ីធ្មេញ បែកធ្មេញ ។



*រោគសញ្ញាញៀនហេរ៉ូអ៊ីន នេម៉ោងក្រោយ*

ក្នុងពេលមានផ្ទៃពោះ ម្ដាយប្រើគ្រឿងញៀន (កញ្ឆា កូកាអ៊ីន ហេរ៉ូអ៊ីន...) ។ ជាតិពុលមានឥទ្ធិពលផ្ទាល់លើទារកក្នុងផ្ទៃ ទាំងផ្នែករាងកាយនិងខួរក្បាល ។ ពេលកើត ក្មេងមានការលូតលាស់យឺតទាំងសតិបញ្ញានិងរូបរាង បើប្រៀបធៀបក្នុងចំណោមកូនក្មេងដែលម្ដាយមិនប្រើគ្រឿងញៀន ។ ការប្រើ ហេរ៉ូអ៊ីន កូកាអ៊ីនលើសកម្រិត បណ្ដាលឱ្យស្លាប់ ។

## ៣. ផលអាក្រក់ដល់សង្គម

ការប្រើគ្រឿងញៀន បណ្ដាលឱ្យបុគ្គលនោះឃ្លាតឆ្ងាយពីសង្គម ដោយបំផ្លាញចោល ឬរលាយបាត់បង់នូវក្រមសីលធម៌ ដោយខ្សែកពួកគេតែងគេចវេះពីភាពទទួលខុសត្រូវនូវអ្វីៗដែលគេបានប្រព្រឹត្ត ។ ការពុលស្រវឹងគ្រឿងញៀនបង្កើតគ្រោះថ្នាក់ដោយធ្វើសកម្មភាពឧក្រិដ្ឋដូចជា ដុតផ្ទះ សំបែង គំរាមទារប្រាក់ លួច ប្លន់ ធ្វើបាបអ្នកដទៃ ។ ដូចនេះគ្រឿងញៀនបង្កនូវលក្ខណៈងាយស្រួលក្នុងការធ្វើឧក្រិដ្ឋកម្ម ។

ភាពស្រុតចុះនៃក្រមសីលធម៌និងប្រពៃណីទំនៀមទំលាប់ថ្លៃថ្នូររបស់សង្គម កាន់តែដុនដាបដោយឥទ្ធិពលរបស់គ្រឿងញៀន មិនតែប៉ុណ្ណោះ អ្នកប្រើប្រាស់ទទួលរងការឈឺចាប់ទាំងផ្លូវកាយនិងផ្លូវចិត្ត ហើយឈានទៅរកជំងឺផ្លូវចិត្ត(ឆ្កួត)ការឆ្លងរោគផ្សេងៗនិងជំងឺអេដស៍ ។ ការខ្ជះខ្ជាយថវិកាផ្ទាល់ខ្លួននិងគ្រួសារដើម្បីទិញគ្រឿងញៀនសម្រាប់ព្យាបាលខ្លួន ដែលបណ្ដាលឱ្យសេដ្ឋកិច្ចគ្រួសារជួបវិបត្តិព្រមទាំងជះឥទ្ធិពលមួយយ៉ាងធ្ងន់ធ្ងរដល់សង្គមជាតិ ។

សរុបមកយើងឃើញថា រាជរដ្ឋាភិបាលទទួលរ៉ាប់រងដោះស្រាយបញ្ហាជាច្រើន ដែលបណ្ដាលមកពីឥទ្ធិពលរបស់គ្រឿងញៀន ដូចជាអំពើអសីលធម៌នានា បទល្មើស ឆក់ប្លន់ ឧក្រិដ្ឋកម្ម រកកន្លែងសម្រាប់ព្យាបាលអ្នកញៀននិងស្ដារនីតិសម្បទាឡើងវិញ ដែលត្រូវចំណាយថវិកាសន្ធឹកសន្ធាប់ គួបផ្សំនឹងការបាត់បង់កម្លាំងពលកម្មនិងធនធានមនុស្ស ។

## 4. លក្ខណៈនៃអ្នកញៀន

ពិភាក្សាពាក្យនិងសញ្ញាមួយចំនួនខាងក្រោម បញ្ជាក់ប្រាប់ថាមិត្តរបស់អ្នកញៀនថ្នាំ ។



1. ពួកគេច្រើនមានអារម្មណ៍ឡប់ៗ និងល្ងើយ ហើយគេចូលចិត្តពួនសម្ងំនៅទីស្ងាត់កំបាំង ។



2. គេចេញទឹកភ្នែក ហើយរន្ធប្រស្រីភ្នែករីកធំ ។



3. គេតែងតែអវត្តមាននៅថ្នាក់រៀន ហើយមិនសូវចូលសាលារៀនទេ ។



4. គេចូលចិត្តខ្ចីលុយមិត្តភក្តិ ឬលួចលុយអ្នកដទៃ ។



5. ពួកគេលែងគិតគូរពីខ្លួនឯង គ្រួសារនិងមិត្តភក្តិ ។

ឧទាហរណ៍ខាងលើ អាចជួយអ្នកឱ្យស្គាល់ពីលក្ខណៈនៃមនុស្សញៀនថ្នាំ ។ ប៉ុន្តែសញ្ញាខ្លះទៀតបង្ហាញពីអារម្មណ៍របស់យុវវ័យដែលកំពុងលូតលាស់ ។ ទោះយ៉ាងណាក៏ដោយ បើមិត្តភក្តិអ្នកមានលក្ខណៈដូចខាងលើ អ្នកត្រូវប្រាប់គ្រូរបស់អ្នក មាតាបិតាដើម្បីរកវិធីអប់រំគេ ។ តាមវិធីនេះអ្នកនឹងអាចជួយកាត់បន្ថយអ្នកញៀនថ្នាំ ។

## 5. មូលហេតុនៃការប្រើគ្រឿងញៀន

យុវវ័យខ្លះប្រើប្រាស់គ្រឿងញៀន ជក់បារី ឬផឹកស្រាដោយសារមូលហេតុមួយចំនួនដូចជា បំបាត់ការអផ្សុក ដើម្បីចុះសំរុងជាមួយមិត្តភក្តិ និងដើម្បីគេចវេះពីបញ្ហាផ្សេងៗ ។

សាកល្បងជួយយុវវ័យទាំងនេះឱ្យជៀសផុតពីបញ្ហាលំបាកខាងលើនេះ ដោយត្រូវឱ្យពួកគេ :



1. ចូលរួមសកម្មភាពក្នុងក្លិបយុវជន ឬការងាររបស់សហគមន៍ ។



2. ចូលរួមចំណែកក្នុង ការងាររបស់សង្គម ។



3. និយាយប្រាប់ឪពុកម្ដាយ ឬគ្រូពីបញ្ហាទាំងនេះ ។

អ្នកអាចចូលរួមក្នុងសកម្មភាពរបស់សាលារៀន ឬសហគមន៍ជំនួសឱ្យការប្រើប្រាស់គ្រឿងញៀន ផឹកស្រា ឬជក់បារី ។

## មេរៀនសង្ខេប

- ការញៀនគ្រឿងញៀនជះឥទ្ធិពលអាក្រក់ដល់សតិបញ្ញា គឺធ្វើឱ្យមនុស្សមានជំងឺសរសៃប្រសាទ បាត់ការចងចាំ មួម៉ៅជាដើម ។
- ការញៀនគ្រឿងញៀនផ្តល់ផលអាក្រក់ដល់រាងកាយដូចជា រលាកផ្លូវដង្ហើម បេះដូងរីក រលាកថ្លើម តម្រងនោម... ។
- ការញៀនថ្នាំមិនត្រឹមតែជះឥទ្ធិពលអាក្រក់ដល់មនុស្សដែលប្រើប្រាស់គ្រឿងញៀនផ្ទាល់ទេ តែវាជះឥទ្ធិពលអាក្រក់ធ្ងន់ធ្ងរដល់សង្គមទៀតផង ។

## ? សំណួរ

1. តើការញៀនថ្នាំផ្តល់ផលអាក្រក់ដល់សតិបញ្ញាដូចម្តេចខ្លះ ?
2. តើផលអាក្រក់នៃការញៀនថ្នាំបណ្តាលឱ្យខូចសុខភាពនិងបង្កើតបញ្ហាដល់សង្គមយ៉ាងណាខ្លះ ?
3. តើមូលហេតុអ្វីបានជាយុវវ័យប្រើប្រាស់គ្រឿងញៀន ?
4. ដើម្បីជៀសវាងការប្រើប្រាស់គ្រឿងញៀន តើយុវវ័យគួរធ្វើអ្វីខ្លះ ?

## ? សំណួរបញ្ចប់ជំពូកទី៦

**I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់នៅខាងមុខចម្លើយដែលត្រឹមត្រូវ**

1. គ្រឿងញៀនលើកកម្លាំងគឺ

☐ ក. កាផេអ៊ីន ☐ ខ. ថ្នាំឈឺក្បាល ☐ គ. ហេរ៉ូអ៊ីន ☐ ឃ. អង់ទីប្យូទិច ។

2. មនុស្សញៀនរស់នៅពឹងផ្អែកលើ

☐ ក. អាហារ ☐ ខ. គ្រឿងញៀន ☐ គ. សំលៀកបំពាក់ ☐ ឃ. យានយន្ត ។

3. គ្រឿងញៀនដែលបំបាត់ការឈឺចាប់គឺ

☐ ក. កូកាអ៊ីន ☐ ខ. ហេរ៉ូអ៊ីន ☐ គ. យ៉ាម៉ា ☐ ឃ. កេតាមីន ។

**II. ចូរបំពេញចន្លោះនៃឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ**

1. ជាតិញៀននៅក្នុងបារី ........................ ។
2. ជាតិញៀននៅក្នុងកាផេ តែ កូកាកូឡាជា ................ ។
3. មនុស្សរស់នៅដោយអត់ថ្នាំញៀនមិនបានជា ................ ថ្នាំ ។
4. គ្រឿងញៀនផ្តល់ឱ្យអ្នកប្រើប្រាស់នូវផលអាក្រក់ចំពោះ ............ រាងកាយ និង ............ ។

**III. ចូរឆ្លើយសំណួរខាងក្រោមនេះ**

1. តើគ្រឿងញៀន ដែលប្រើជាថ្នាំលើកកម្លាំងមានអ្វីខ្លះ ?
2. តើគ្រឿងញៀន ដែលប្រើជាថ្នាំបំបាត់ការឈឺចាប់និងបន្ថយការធុញថប់មានអ្វីខ្លះ ?
3. ជាទូទៅគេប្រើប្រាស់កញ្ឆាតាមវិធីណាខ្លះ ?
4. នៅលើទីផ្សារ តើគេលាយហេរ៉ូអ៊ីនជាមួយនឹងអ្វីខ្លះ ?
5. តើជីវកាវជាវត្ថុស្របច្បាប់ ឬមិនស្របច្បាប់ ? ហេតុអ្វី ?
6. តើមនុស្សហិតជីវកាវមានលក្ខណៈដូចម្តេច ?
7. តើមនុស្សញៀនកញ្ឆានិងញៀនអាភៀនមានលក្ខណៈដូចម្តេចដែរ ?
8. ហេតុអ្វីបានជាយើងគ្រប់គ្នាត្រូវតែដឹងពីផលអាក្រក់នៃគ្រឿងញៀនចំពោះសុខភាព ?
9. តើការចាក់គ្រឿងញៀនតាមសរសៃឈាមផ្តល់គ្រោះថ្នាក់ដល់អ្នកប្រើប្រាស់បែបណាខ្លះ ?
10. នៅពេលមានផ្ទៃពោះ តើម្តាយប្រើគ្រឿងញៀនមានឥទ្ធិពលលើទារកដូចម្តេចខ្លះ ?
11. តើឥរិយាបថបែបណាដែលបង្ហាញថាមនុស្សនោះប្រើប្រាស់គ្រឿងញៀន ?
12. ប្រសិនបើអ្នកឃើញមិត្តរបស់អ្នកមានឥរិយាបថបែបនេះ តើអ្នកគួរធ្វើដូចម្តេច ?
13. ដើម្បីជួយយុវវ័យកុំឱ្យប្រើប្រាស់គ្រឿងញៀន តើយើងគួរធ្វើដូចម្តេចខ្លះ ?